# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
# និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

## របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# ដំណើរការនៃការផ្ដល់សេវាកម្មធានារ៉ាប់រង
# លើផលិតផលអគ្គីភ័យ

កម្មសិក្សាពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ឈ្មោះស្ថាប័ន៖ **ក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ**


តាក់តែងឡើងដោយ

និស្សិតឈ្មោះ៖ **អ៊ីវ សាន់បញ្ញា**

**ចេង សេងគង់**

សាស្ត្រាចារ្យណែនាំ

លោកស្រី **ឡុង ម៉ាមីឌី**


ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍

ជំនាន់ទី ៤

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេររបាយការណ៍ ២០២០

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំ **អ៊ីវ សាន់បញ្ញា** និង**ចេង សេងគង់** ជានិស្សិតសិក្សាថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍ ឆ្នាំទី៤ ជំនាន់ទី ៤ ក្រុម D4C1 ឆ្នាំសិក្សា ២០១៩-២០២០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច សូមគោរពដឹងគុណ និងថ្លែងអំណរគុណយ៉ាងខ្ពង់ខ្ពស់បំផុតចំពោះ ៖

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនចំពោះ លោកឪពុក អ្នកម្តាយ របស់យើងខ្ញុំទាំងពីរដែលបានផ្តល់កំណើតចិញ្ចឹមបីបាច់ថែរក្សាយ៉ាងយកចិត្តទុកដាក់ចាប់តាំងពីកើតរហូតមកដល់វ័យបច្ចុប្បន្ននេះជាពិសេសសូមធ្វើការថ្លែងអំណរគុណសម្រាប់ក្តីស្រឡាញ់របស់លោកចំពោះកូនៗដែលបានជម្រុញលើកទឹកចិត្តអប់រំទូន្មាន និងបានផ្គត់ផ្គង់ទំនុកបម្រុងក្នុងការសិក្សារហូតបានបញ្ចប់ការសិក្សានេះ។

**ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង និងលោកគ្រូ អ្នកគ្រូ** ដែលជាសាស្ត្រាចារ្យ បម្រើការងារនៅ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ដែលបានប្រើប្រាស់ទាំងកម្លាំងកាយនិងកម្លាំងចិត្ត ដើម្បីផ្តល់នូវចំនេះដឹងយ៉ាងច្រើនដល់យើងខ្ញុំ និង សិស្ស និស្សិតជំនាន់ក្រោយៗទៀតចាប់តាំងពីថ្នាក់សិក្សាមូលដ្ឋាន រហូតបញ្ចប់។

សាស្ត្រាចារ្យ**ឡុង ម៉ាមីឌី** ដែលបានខិតខំប្រឹងប្រែងនិងចំណាយពេលវេលាដ៏មានតំលៃក្នុងការផ្តល់ជាអនុសាសន៍ល្អៗ និង កែសម្រួលបន្ថែមដល់ការសរសេររបាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សារបស់យើងខ្ញុំអោយកាន់តែមានភាពល្អប្រសើរ រហូតបានបញ្ចប់ដោយជោគជ័យជាស្ថាពរ។

**Mr. Youk Chamreounrith** អគ្គនាយកក្រុមហ៊ុនធានារ៉ាប់រង ហ្វតេ និង **Mr. Suy Channtharong** ប្រធានផ្នែកគ្រប់គ្រង Underwriting ដែលបានផ្តល់ការណែនាំ និងចែករំលែកបទពិសោធន៍ការងារ ក៏ដូចជាផ្តល់នូវឯកសារពាក់ព័ន្ធដែលជំរុញឲ្យការសរសេររបាយការណ៍កម្មសិក្សា ប្រព្រឹត្តិទៅដោយជោគជ័យ។

បងប្អូន និង មិត្តភក្តិទាំងអស់គ្នាដែលបានផ្តល់ជាគំនិតយោបល់ និង ការលើកទឹកចិត្តយ៉ាងខ្លាំងក្លាដល់យើងខ្ញុំ។

ជាទីបញ្ចប់យើងខ្ញុំ សូមគោរពជូនពរទៅដល់អ្នកទាំងអស់គ្នាអោយជួបប្រទះទៅនឹងសេចក្តីសុខសុភមង្គលសុខភាពល្អ សំណាងល្អ និងទទួលបានភាពជោគជ័យក្នុងជីវិតរៀងរហូតទៅ។

# អារម្ភកថា

សៀវភៅនេះគឺជា របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកសេដ្ឋអភិវឌ្ឍន៍ជំនាន់ទី៤ នៃឆ្នាំសិក្សា ២០១៩-២០២០ ក្នុងការសិក្សាពីប្រធានបទស្ដីអំពី "**ដំណើរការនៃការផ្ដល់សេវាកម្មធានារ៉ាប់រងលើអគ្គីភ័យ** " វាជាប្រភេទអត្ថបទស្រាវជ្រាវថ្មីមួយដែលបានសរសេរឡើងដោយនិស្សិត ផ្នែកសេដ្ឋកិច្ចអភិវឌ្ឍន៍នៃ សកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងគោលបំណងបង្ហាញ និងចែករំលែកនូវចំណេះដឹងជុំវិញវិស័យធានារ៉ាប់រងនៅក្នុងប្រទេសកម្ពុជា។ អត្ថបទនេះបានរំលេចឡើងនូវចំណុចសំខាន់ៗជាច្រើនដូចជាការកកើតនៃធានារ៉ាប់រងនិង ប្រវត្តិធានារ៉ាប់រងនៅក្នុងប្រទេសកម្ពុជាពត៌មានខ្លះៗអំពីក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ និងផលិតផលនានានៅក្នុងក្រុមហ៊ុនជាដើម និងការវិភាគអំពីបុព្វលាភនៅក្នុងក្រុមហ៊ុនហ្វតតេនិងក្នុងឧស្សាហកម្មធានារ៉ាប់រងទាំងមូលក្នុងប្រទេសកម្ពុជា។ អ្វីដែលពិសេសទៀតនោះគឺនៅក្នុងរបាយការណ៍មួយនេះនឹងរៀបរាប់អំពីគ្រប់នីតិវិធី និង ដំណើរការនានារបស់សេវាកម្មធានារ៉ាប់រងលើអគ្គីភ័យនិងអត្ថប្រយោជន៍ដែលទទួលបានពីសេវាកម្មមួយនេះ។

លើសពីនេះទៅទៀត វាត្រូវបានចងក្រងឡើងក្រោមការណែនាំរបស់សាស្ត្រាចារ្យ ដែលមានចំណេះដឹង ជំនាញ និងបទពិសោធន៍ជាច្រើនក្នុងការផ្ដល់ជាអនុសាសន៍ល្អៗ ក្នុងការចងក្រងអត្ថបទការប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវឯកសាពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាពនិង តម្លាភាពផងដែរ។

យ៉ាងណាមិញអត្ថបទរបាយការណ៍មួយនេះ នឹងជាជំនួយមួយផ្នែកក្នុងការជំរុញអោយប្រជាពលរដ្ឋទូទៅ ម្ចាស់អជីវកម្ម ម្ចាស់សហគ្រាសផ្សេងៗទទួលបានចំណេះដឹងបន្ថែមអំពីវិស័យនេះ ក្នុងគោលបំណងឲ្យពួកគេចេះការពារទ្រព្យសម្បត្តិ និង អជីវកម្មរបស់ខ្លួនតាមរយៈការប្រើប្រាស់សេវាកម្មធានារ៉ាប់រង។ ហើយវាក៏អាចជំនួយមួយផ្នែកសំរាប់និស្សិតជំនាន់ក្រោយៗធ្វើការសិក្សាស្រាវជ្រាវឲបានកាន់តែលំអិត និង ស៊ីជម្រៅលើប្រធានបទនេះបន្ថែមទៀត។

ជាចុងបញ្ចប់យើងខ្ញុំក៏សូមមេត្តា ខន្តី អធ្យាស្រ័យពីសំណាក់បងប្អូនជនរួមជាតិ មិត្តនិស្សិតនិងអ្នកសិក្សាស្រាវជ្រាវទាំងអស់នូវរាល់កំហុសខុសឆ្គង ដែលកើតមានឡើងដោយអចេតនានិងចំណុចខ្វះចន្លោះទាំងឡាយ ហើយយើងខ្ញុំពេញចិត្តទទួលនូវរាល់មតិយោបល់ទាំងឡាយ និងការរិះគន់ក្នុងន័យស្ថាបនាពី សំណាក់សិស្ស និស្សិត លោកគ្រូអ្នកគ្រូ និងសាធារណៈជន ពីគ្រប់មជ្ឈដ្ឋានទាំងអស់។

ដោយសេចក្ដីគោរព ស្រលាញ់ និងរាប់អានយ៉ាងខ្ពង់ខ្ពស់ពីយើងខ្ញុំ។

# មាតិកា

បញ្ជីតារាង....................v
បញ្ជីរូបភាព....................vi
បញ្ជីរូបក្រាប....................vii
បញ្ជីឧបសម្ព័ន្ធ....................viii

## សេចក្តីផ្តើម

១. លំនាំបញ្ហា .................... ០១
២. ចំណោទបញ្ហា .................... ០២
៣. គោលបំណងនៃការស្រាវជ្រាវ .................... ០២
៤. វិសាលភាពនិងដែនកំណត់នៃការស្រាវជ្រាវ .................... ០៣
៥. វិធីសាស្ត្រនៃការស្រាវជ្រាវ .................... ០៣
ក. ប្រភពទិន្នន័យ .................... ០៣
ខ. ការប្រមូលទិន្នន័យ .................... ០៤
គ. ប្រភេទនៃវិធីសាស្ត្រក្នុងការស្រាវជ្រាវ .................... ០៤
៦. សារៈសំខាន់នៃការស្រាវជ្រាវ .................... ០៥
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ .................... ០៦

## ជំពូកទី១
## រំលឹកទ្រឹស្តី

១.១. លក្ខណៈទូទៅ .................... ០៧
១.១.១. និយមន័យ .................... ០៧
១.១.២. ប្រវត្តិធានារ៉ាប់រង .................... ០៨
១.១.៣. ប្រវត្តិធានារ៉ាប់រងក្នុងប្រទេសកម្ពុជា .................... ០៩
១.១.៤. ចំណាត់ថ្នាក់ប្រភេទនៃសេវាធានារ៉ាប់រង .................... ១២
១.១.៥ ប្រភេទធានាក្រុមហ៊ុនធានារ៉ាប់រង .................... ១៣

# ជំពូកទី២

## ស្ថានភាពទូទៅរបស់ក្រុមហ៊ុនធានារ៉ាប់រង ហ្វតតេ


២.១. ប្រវត្តិសង្ខេបរបស់ក្រុមហ៊ុន ..... ១៦

២.២. អត្តសញ្ញាណ( ទីតាំងអាជីវកម្ម និងនិមិត្តសញ្ញា) ..... ១៧

២.២.១. និមិត្តសញ្ញា ..... ១៧

២.២.២. ទីតាំងអាជីវកម្ម ..... ១៧

២.៣. បេសកកម្ម និងចក្ខុវិស័យ ..... ១៨

២.៣.១. បេសកកម្ម ..... ១៨

២.៣.២. ចក្ខុវិស័យ ..... ១៩

២.៤. រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន ..... ១៩

២.៥. ដៃគូរពាណិជ្ជកម្ម ..... ២០

២.៦. ទំនួលខុសត្រូវក្នុងសង្គម ..... ២៣

២.៨. ភាពច្នៃប្រឌិត ..... ២៣

២.៩. ធនធានមនុស្សនៅក្នុងសហគ្រាស ..... ២៣

២.១០. ផលិតផលរបស់ក្រុមហ៊ុន ..... ២៤

២.១០.១. ផលិតផលធានារ៉ាប់រងមេឌីគ្រីធីខល សាកល ..... ២៤

២.១០.២. ផលិតផលធានារ៉ាប់រង សុខភាពអន្តរជាតិ ..... ២៦

២.១០.៣. ផលិតផលធានារ៉ាប់រងគាំពារមហារីក CANCKOAMPEA ..... ២៦

២.១០.៤. ផលិតផលធានារ៉ាប់រងគ្រោះថ្នាក់បុគ្គល ..... ២៩

២.១០.៥. ផលិតផលធានារ៉ាប់រងលើអ្នកដំណើរ ..... ២៩

២.១០.៦. ផលិតផលធានារ៉ាប់រងលើយានយន្ត ..... ៣០

២.១០.៧. ផលិតផលធានារ៉ាប់រងលើអគ្គីភ័យ ..... ៣២

២.១០.៨. ផលិតផលធានារ៉ាប់រងសុខភាពអន្តរជាតិ ..... ៣២

២.១០.៩. ផលិតផលធានារ៉ាប់រងអាកាសចរណ៍ ..... ៣២

២.១០.១០. ផលិតផលធានារ៉ាប់រងហានិភ័យនៃស្ថាប័នហិរញ្ញវត្ថុ ..... ៣៣

២.១០.១១. ផលិតផលធានារ៉ាប់រងចោរកម្ម ............ ៣៤
២.១០.១២. ផលិតផលធានារ៉ាប់រងការសាងសង/ការតំឡើង............ ៣៤
២.១០.១៣. ផលិតផលធានារ៉ាប់រងគ្រឿងអេឡិចត្រូនិក............ ៣៥
២.១០.១៤. ផលិតផលធានារ៉ាប់រងថែទាំសុខភាពបុគ្គលិក............ ៣៥
២.១០.១៥. ផលិតផលធានារ៉ាប់រងភាពស្មោះត្រង់បុគ្គលិក............ ៣៦
២.១០.១៦. ផលិតផលធានារ៉ាប់រងសម្រាកពេទ្យនិងវះកាត់ ............ ៣៦
២.១០.១៧. ផលិតផលធានារ៉ាប់រងទ្រព្យសម្បត្តិ ............ ៣៧
២.១០.១៨. ផលិតផលធានារ៉ាប់រងការបាត់បង់ប្រាក់ចំណេញ ............ ៣៨
២.១០.១៩. ផលិតផលធានារ៉ាប់រងការដឹកជញ្ជូនទំនិញ ............ ៣៨
២.១០.២០. ផលិតផលធានារ៉ាប់រងសាច់ប្រាក់ ............ ៣៩
២.១០.២១. ផលិតផលធានារ៉ាប់រងផ្ទាំងកញ្ចក់............ ៤០
២.១០.២២. ផលិតផលធានារ៉ាប់រងទំនួលខុសត្រូវវិជ្ជាជីវៈ ............ ៤០
២.១០.២៣. ផលិតផលធានារ៉ាប់រងទំនួលខុសត្រូវសាធារណៈ............ ៤១
២.១០.២៤. ផលិតផលធានារ៉ាប់រងគ្រឿងម៉ាស៊ីនដើរដោយចំហាយ/ចំហេះ ............ ៤១
២.១០.២៥. ផលិតផលធានារ៉ាប់រងទំនួលខុសត្រូវស្របច្បាប់នៃនាយកនិងមន្ត្រីគ្រប់គ្រង ............ ៤២
២.១០.២៦. ផលិតផលធានារ៉ាប់រងគ្រឿងចក្រនិងគ្រឿងម៉ាស៊ីនរបស់ក្រុមហ៊ុនម៉ៅការ............ ៤៣
២.១១. ការវិភាគលើ GROSS PREMIUM និង NET PREMIUM ............ ៤៤
២.១២. ការវិភាគលើចំណែកទីផ្សាររបស់ក្រុមហ៊ុនហ្វតេជៀបនិងទីផ្សារទាំងមូល ............ ៤៧
២.១៣. ការវិភាគអំពីចំណាត់ថ្នាក់បុព្វលាភរបស់ផលិតផលនីមួយៗ ............ ៤៨

## ជំពូកទី៣

## ដំណើរការនៃការផ្តល់សេវាកម្មធានារ៉ាប់រងលើផលិតផលអគ្គីភ័យ

៣.១. គោលបំណងនៃការផ្តល់សេវាកម្មធានារ៉ាប់រងធានារ៉ាប់រងលើអគ្គីភ័យ ............ ៤៩
៣.២. ប្រភេទនៃធានារ៉ាប់រងលើអគ្គីភ័យ ............ ៤៩

៣.២.១. ធានារ៉ាប់រងលើអគ្គីភ័យផ្ទាល់ខ្លួន (Fire Domestic) ........ ៤៩
៣.២.២. ធានារ៉ាប់រងលើអគ្គីភ័យសំរាប់អាជីវកម្ម (Fire Commercial ) ........ ៤៩
៣.៣. នីតិវិធីនៃការផ្តល់សេវាកម្មធានារ៉ាប់រងលើអគ្គីភ័យ ........ ៥០
៣.៣.១ ពត៌មានបឋម ........ ៥០
៣.៣.២. ហានិភ័យជាមូលដ្ឋានដែលត្រូវបានធានា ........ ៥២
៣.៣.៣. អត្រាបុព្វលាភហានិភ័យបន្ថែម ........ ៥២
៣.៣.៤. សម្ភារៈពន្លត់អគ្គីភ័យ ........ ៥៤
៣.៣.៤ .១. ឧបករណ៍ពន្លត់អគ្គីភ័យ ( Portable Extinguishers) ........ ៥៥
៣.៣.៤.២. ផែនទុយោបាញ់ទឹកក្នុងអគារ( Hose Reels Or Internal Hydrants) ........ ៥៥
៣.៣.៤.៣. ក្បាលម៉ាស៊ីនទឹកក្នុងអគារ (Sprinkler Installations) ........ ៥៦
៣.៣.៤.៤. ប្រព័ន្ធផ្តល់សញ្ញានិងតាមដានសញ្ញាអគ្គីភ័យដោយស្វ័យប្រវត្តិ ........ ៥៧
៣.៣.៥. តារាងអត្រាបុព្វលាភនិងចំណាត់ថ្នាក់ប្រភេទអជីវកម្ម ........ ៥៨
៣.៣.៦. កម្រិតមិនធ្វើសំណង ........ ៦៤
៣.៣.៧. ដំណើរការនៃការទាមទារសំណង ........ ៦៥
៣.៣.៨. ដំណើរការនៃការសងសំណង ........ ៦៦
៣.៣.៩. អត្ថប្រយោជន៍នៃធានារ៉ាប់រងលើអគ្គីភ័យនៅក្នុងក្រុមហ៊ុនហ្វតតេ ........ ៦៧
៣.៤. ការវិភាគ Swot ចំពោះដំណើរសេវាកម្ម ........ ៦៧
៣.៤.១. ភាពខ្លាំងរបស់ផលិតផលធានារ៉ាប់រងលើអគ្គីភ័យ ........ ៦៧
៣.៤.២. ភាពខ្សោយរបស់ផលិតផលធានារ៉ាប់រងលើអគ្គីភ័យ ........ ៦៨
៣.៤.៣.ឱកាសរបស់ក្រុមហ៊ុន ........ ៦៨
៣.៤.៤.ការគំរាមកំហែងរបស់ក្រុមហ៊ុន ........ ៦៩

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១. សេចក្តីសន្និដ្ឋាន ........ ៧០
២. អនុសាសន៍ ........ ៧១

# បញ្ជីតារាង

**ទំព័រ**

តារាងទី១ ៖ តារាងបង្ហាញពីអត្ថប្រយោជន៍នៃសេវាកម្មធានារ៉ាប់រងមេឌីគ្រីធីខល សាកល...........................២៥

តារាងទី២ ៖ តារាងបង្ហាញពីអត្ថប្រយោជន៍នៃផលិតផលធានារ៉ាប់រងគាំពារមហារីក.................................២៧

តារាងទី៣ ៖ តារាងបង្ហាញពីបុព្វលាភនៃផលិតផលធានារ៉ាប់រងគាំពារមហារីក........................................២៨

តារាងទី៤ ៖ តារាងបង្ហាញពីអត្ថប្រយោជន៍នៃផលិតផលធានារ៉ាប់រងលើអ្នកដំណើរ..................................៣០

តារាងទី៥ ៖ តារាងដែលបង្ហាញពីការវិភាគទៅលើ GrossPremium និង Net Premium របស់ក្រុមហ៊ុនហ្វតតេ និង វិស័យធានារ៉ាប់រងនៅក្នុងប្រទេសកម្ពុជាពីឆ្នាំ២០០៩ដល់ឆ្នាំ២០១៨....................................៤៤

តារាងទី៦ ៖ តារាងបង្ហាញពីអត្រាបុព្វលាភរបស់ផលិតផលនីមួយៗនៅក្នុងក្រុមហ៊ុនហ្វតតេ........................៤៨

តារាងទី៧ ៖ តារាងបង្ហាញពីកម្រិតមិនធ្វើសំណង..........................................................................៦៤

# បញ្ជីរូបភាព

**ទំព័រ**

រូបទី១ ៖ រូបតំណាងក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ............................................................................. ១៧
រូបទី២ ៖ រូបបង្ហាញពីទីតាំងការិយាល័យរបស់ក្រុមហ៊ុននៅទូទាំងប្រទេស..................................................១៨
រូបទី៣ ៖ រចនាសម្ព័ន្ធក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ........................................................................... ១៩
រូបទី៤ ៖ បង្ហាញពីដំណើរការនៃសេវាកម្មធានារ៉ាប់រងលើអគ្គីភ័យ............................................................៥០
រូបទី៥ ៖ បង្ហាញពីអត្រាបុព្វលាភនិងចំណាត់ថ្នាក់ប្រភេទអជីវកម្ម.........................................................៥៨

# បញ្ជីក្រាប

**ទំព័រ**

ក្រាបទី១ ៖ ក្រាបបង្ហាញពី Gross Premium របស់ក្រុមហ៊ុនហ្វតតេនៅក្នុងវិស័យធានារ៉ាប់រងនៅក្នុងប្រទេសកម្ពុជា ចាប់ពីឆ្នាំ២០០៩ដល់២០១៨..........៤៥

ក្រាបទី២ ៖ ក្រាបបង្ហាញពីNet Premium របស់ក្រុមហ៊ុនហ្វតតេនៅក្នុងវិស័យធានារ៉ាប់រងនៅក្នុងប្រទេសកម្ពុជា ចាប់ពីឆ្នាំ២០០៩ដល់២០១៨..........៤៦

ក្រាបទី៣ ៖ បង្ហាញពីចំណែកទីផ្សាររបស់ក្រុមហ៊ុនហ្វតតេធៀបនឹងវិស័យនេះទាំងមូលក្នុងឆ្នាំ២០១៨ដោយផ្អែក លើ Gross Premium..........៤៧

ក្រាបទី៤ ៖ បង្ហាញពីចំណែកទីផ្សាររបស់ក្រុមហ៊ុនហ្វតតេធៀបនឹងវិស័យនេះទាំងមូលក្នុងឆ្នាំ២០១៨ដោយផ្អែក លើ Net Premium..........៤៧

ក្រាបទី៥ ៖ បង្ហាញពីការផ្តល់សេវាកម្មពេញនិយមនៅក្នុងក្រុមហ៊ុនក្នុងឆ្នាំ២០១៨..........៤៨

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ ៖ កម្រងសំណួរ

ឧបសម្ព័ន្ធទី២ ៖ ទម្រង់បែបបទនៃការស្នើរសុំទិញធានារ៉ាប់រងលើអគ្គីភ័យ

ឧបសម្ព័ន្ធទី៣ ៖ ទម្រង់បែបបទនៃការទាមទារសំណង

ឧបសម្ព័ន្ធទី៤ ៖ ច្បាប់ស្តីពីការធានារ៉ាប់រង

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

បន្ទាប់ពីព្រះរាជាណាចក្រកម្ពុជា ទទួលបានសុខសន្តិភាពយ៉ាងពេញលេញយើងឃើញថារយៈពេលជាងមួយទសវត្សរកន្លងមកនេះឧស្សាហកម្មធានារ៉ាប់រង នៅក្នុងប្រទេសកម្ពុជា មានការរីកចម្រើនយ៉ាងខ្លាំង ការរីកចម្រើននេះគឺគាំទ្រដោយការកើនឡើងនៃ ចំណូលពីការវិនិយោគ អត្រាការប្រាក់មានភាពប្រសើរ និង កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ បើយោងទៅតាមសមាគមធានារ៉ាប់រងកម្ពុជាបានបង្ហាញអោយឃើញថាចំណូលរបស់វិស័យធានារ៉ាប់រងនៅកម្ពុជាមានប្រមាណជាងមួយរយលានដុល្លារអាមេរិកក្នុងឆ្នាំ២០១៩ ។[1]

សព្វថ្ងៃនេះនៅក្នុងប្រទេសកម្ពុជាមានក្រុមហ៊ុនធានារ៉ាប់រងជាច្រើនដែលចូលមកនិងធ្វើអជីវកម្មធានារ៉ាប់រងក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងនោះក្រុមហ៊ុនដែលមានការរីកចម្រើននិងការគាំទ្រពីសំណាក់អតិថិជនទាំងក្នុងស្រុក និង ក្រៅស្រុកដែលឈានមុខគេនៅប្រទេសកម្ពុជានោះគឺក្រុមហ៊ុនធានារ៉ាប់រងហ្វតតេដោយយោងទៅតាមគេហទំព័ររបស់ក្រុមហ៊ុនហ្វតតេ (Company profile) នៅក្នុងឆ្នាំ២០១៨ ប្រទេសកម្ពុជាមានក្រុមហ៊ុនធានារ៉ាប់រងទូទៅចំនួន ១២ ហើយបុព្វលាភដុល សរុបចំនួន ៣១,៩៧១,៨៧៥ ដុល្លារអាមេរិក ជាមួយគ្នានោះដែរក្រុមហ៊ុនធានារ៉ាប់ហ្វតតេទទួលបានបុព្វលាភដុល ចំនួន១៨,៤៧៨,៩៧៤ នៃក្រុមហ៊ុនទាំង ១២។ ដោយសារតែសព្វថ្ងៃនេះយើងឃើញថាកំណើនប្រជាជននិងអ្នកវិនិយោគនៅក្នុងប្រទេសកម្ពុជា កាន់តែច្រើនឡើងៗបានធ្វើអោយសំទុះនៃការសាងសង់ទីលំនៅរោងចក្រនិងសំណង់អាគារផ្សេងៗ មានការរីកលូតលាស់ដូចផ្សិត ។ ទន្ទឹមនឹងគ្នានេះដែរហានិភ័យទៅលើលំនៅដ្ឋាននិងអាគារផ្សេងៗក៏មានការកើតឡើងដូចគ្នាដែលអាចធ្វើឲ្យប្រជាពលរដ្ឋនិងម្ចាស់សហគ្រាសជួបនូវបញ្ហាហិរញ្ញវត្ថុយ៉ាងធ្ងន់ធ្ងរក្នុងគ្រួសារ និងសេដ្ឋកិច្ចជាតិ។ ជាក់ស្តែងការសែតមួយដែលមានឈ្មោះថា VOICE OF AMERICA-KHMER បានចុះផ្សាយនៅថ្ងៃទី ២១ កុម្ភៈ ២០១៩ ថានៅក្នុងសន្និបាតបូកសរុបសភាពការណ៍និងលទ្ធផលការងាររបស់កងកម្លាំងនគរបាលជាតិនាថ្ងៃទី២១ កុម្ភៈ ២០១៩ លោក នេត វន្ណា ប្រធាននាយកដ្ឋាននគរបាលបង្ការពន្លត់អគ្គីភ័យនៃស្នងការនគរបាលជាតិបាននិយាយថាក្នុងឆ្នាំ ២០១៨ មានករណីអគ្គីភ័យកើតឡើងទូទាំងប្រទេសចំនួន ៥៣៤ លើកកើនឡើងចំនួន ២០លើកធៀបនឹងឆ្នាំ ២០១៧។ ករណីទាំងអស់នេះបានបណ្តាលឲ្យមានមនុស្សស្លាប់ចំនួន ១៧នាក់ របួស ៥៧នាក់ និងឆេះផ្ទះអស់ ៥៥៣ខ្នង និងឆេះតូបអស់អស់ ៣៩៦តូបនៅទូទាំងប្រទេសកម្ពុជា។

---

[1] សមាគមធានារ៉ាប់រងកម្ពុជា, Market Statistic Of General Insurance ,ត្រូវបានយកមកប្រើប្រាស់នៅថ្ងៃទី០៧មេសា២០២០ http://www.iac.org.kh

លោក នេត វន្ធា បានបន្ថែមទៀតថា ករណីទាំងអស់នេះអាចបណ្ដាលមកពីការតចរន្តអគ្គីសនីខុសបច្ចេកទេសការធ្វេសប្រហែស ភ្លើងចង្រ្កាន ភ្លើង ទៀនធូប ។ ល ។[2] ប៉ុន្តែក្នុងករណីទាំងនេះប្រសិនបើយើងមានធានារ៉ាប់រង ទៅលើអគ្គីភ័យនោះយើងនឹងពុំមានការព្រួយបារម្ភចំពោះការប៉ះពាល់ផ្នែកហិរញ្ញវត្ថុនោះទេពីព្រោះនៅពេលមានហានិភ័យកើតឡើង យើងបានផ្ទេរហានិភ័យទៅអោយក្រុមហ៊ុនធានារ៉ាប់រងគឺជាអ្នកដោះស្រាយនូវបញ្ហាទាំងនោះ។ ជាហេតុនេះហើយទើបក្រុមយើងខ្ញុំបានលើកឡើងនូវប្រធានបទអំពីដំណើរការនៃការផ្តល់សេវាកម្មធានារ៉ាប់រងលើផលិតផលអគ្គីភ័យយកមកសិក្សាស្រាវជ្រាវ។

## ២. ចំណោទបញ្ហា

បើទោះបីជាវិស័យធានារ៉ាប់រងបានឈានជើងចូលមកក្នុង ព្រះរាជាណាចក្រកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំមកហើយក្តីក៏ប៉ុន្តែ បើផ្អែកទៅលើការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងប្រទេសកម្ពុជាទៅលើវិស័យមួយនេះ គឺនៅមានកម្រិត និងពុំទាន់យល់ដឹងអំពី អត្ថប្រយោជន៍របស់ធានារ៉ាប់រងនៅឡើយ។ដូច្នេះហើយទើបក្រុមរបស់យើងខ្ញុំបានធ្វើការស្រាវជ្រាវទៅលើប្រធានបទមួយនេះពីក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ។ លើសពីនេះទៅទៀតយើងបានលើកឡើងនូវបញ្ហាដែលពាក់ព័ន្ធទៅលើសេវាកម្មធានារ៉ាប់រងមានដូចជា៖

១. តើក្រុមហ៊ុនហ្វតតេមានដំណើរការផ្តល់សេវាកម្មធានារ៉ាប់រងលើផលិតផលអគ្គីភ័យដូចម្តេចខ្លះ?

២.តើធានារ៉ាប់រងអគ្គីភ័យរបស់ក្រុមហ៊ុនហ្វតតេផ្តល់សំណងនឹងអត្ថប្រយោជន៍អ្វីខ្លះចំពោះអតិថិជន?

## ៣. គោលបំណងនៃការស្រាវជ្រាវ

របាយការណ៍សិក្សាស្រាវជ្រាវមានគោលបំណងរួមគឺជាការបង្ហាញពីដំណើរការនៃការផ្តល់សេវាធានារ៉ាប់រងអគ្គីភ័យដែលមានគោលបំណងជាក់លាក់ដូចដែលបានរៀបរាប់ខាងក្រោម ៖

- ប្រវត្តិធានារ៉ាប់រង
- ស្ថានភាពទូទៅរបស់ក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ
- ដំណើរការនៃការផ្តល់សេវាកម្មធានារ៉ាប់រងអគ្គីភ័យក្នុងក្រុមហ៊ុនធានារ៉ាប់ហ្វតតេ
- ប្រភេទធានារ៉ាប់រងអគ្គីភ័យរបស់ក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ
- អត្ថប្រយោជន៍នៃសេវាកម្មធានារ៉ាប់រងទៅលើអគ្គីភ័យ
- ការដោះស្រាយសំណងរវាងក្រុមហ៊ុនទៅដល់អតិថិជន
- សន្និដ្ឋាននឹងការផ្តល់អនុសាសន៍

[2]កាសែតVOAដែលចុះផ្សាយនៅថ្ងៃទី២១ខែកុម្ភៈ២០១៩,ត្រូវបានយកមកប្រើប្រាស់នៅថ្ងៃទី០៧មេសា២០២០
https://khmer.voanews.com/a/firefighter-official-call-on-people-to-be-more-cautious-of-fire/4798113.html

## ៤. វិសាលភាពនិងដែនកំណត់នៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទមួយ តែងតែមានដែនកំណត់នៃការសិក្សាស្រាវជ្រាវយ៉ាងច្បាស់លាស់ ទៅតាមពេលវេលានៃទំហំប្រធានបទ និង ប្រភេទទិន្នន័យដែលបានយកមកស្រាវជ្រាវ ។ដោយសារតែវិស័យធានារ៉ាប់រងនៅពេលបច្ចុប្បន្ននេះមានវិសាលភាពធំទូលាយ ក្រុមហ៊ុនធានារ៉ាប់រងមានជាច្រើន សេវាកម្មធានារ៉ាប់រងមានច្រើនប្រភេទ ដូច្នេះយើងខ្ញុំពុំបានសិក្សាលំអិតអំពីវិស័យធានារ៉ាប់រងទាំងមូលឬអំពីក្រុមហ៊ុនធានារ៉ាប់រងផ្សេងៗ នៅក្នុងប្រទេសកម្ពុជានោះទេ ។ ក្នុងរបាយការណ៍កម្មសិក្សាស្រាវជ្រាវនេះយើងខ្ញុំនឹងសិក្សាស្វែងយល់ពីសេវាកម្មធានារ៉ាប់រងក្នុងក្រុមហ៊ុនធានារ៉ាប់រងហ្វូតតេនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែដោយសារក្រុមហ៊ុនធានារ៉ាប់រងហ្វូតតេ មានសេវាកម្មធានារ៉ាប់រងច្រើនប្រភេទដូច្នេះហើយយើងខ្ញុំបានសម្រេចថានឹងលើកយកតែសេវាកម្មធានារ៉ាប់រងលើអគ្គីភ័យមកសិក្សាតែប៉ុណ្ណោះ ។ដូច្នេះហើយដើម្បីជាជំនួយក្នុងការសិក្សាទៅលើប្រធានបទនេះឲ្យ មានលក្ខណៈល្អប្រសើរនិងកាន់តែច្បាស់លាស់យើងខ្ញុំបានប្រមូលទិន្នន័យកំឡុងឆ្នាំ ២០០៩-២០១៩ និងបានកំណត់ទំហំនៃការស្រាវជ្រាវមួយដោយ ធ្វើការសិក្សាពាក់ព័ន្ធទៅលើ ដំណើរការនៃការផ្តល់សេវាកម្មធានារ៉ាប់រងលើផលិតផលអគ្គីភ័យ ការផ្តល់សំណងនឹង អត្ថប្រយោជន៍ផ្សេងៗ របស់ផលិតផលអគ្គីភ័យ ការវិភាគអំពីអំពីបុព្វលាភដុល និង បុព្វលាភគោល ការវិភាគទៅលើចំណែកទីផ្សាររបស់ក្រុមហ៊ុនហ្វូតតេនៅក្នុងទីផ្សារទាំងមូល ការវិភាគអំពីចំណាត់ថ្នាក់បុព្វលាភរបស់ផលិតផលនីមួយៗ និងភាពខ្លាំង ភាពខ្សោយរបស់ផលិតផលធានារ៉ាប់រងលើអគ្គីភ័យនៅក្នុងក្រុមហ៊ុនធានារ៉ាប់រងហ្វូតតេ តែប៉ុណ្ណោះ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

### ក. ប្រភពទិន្នន័យ

ការប្រមូលទិន្នន័យយើងខ្ញុំបានប្រើប្រាស់ការប្រមូលទិន្នន័យជាពីរប្រភេទគឺទិន្នន័យចម្បង និងទិន្នន័យបន្ទាប់បន្សំ ។ទិន្នន័យចម្បងនេះគឺជាប្រភេទទិន្នន័យដែលត្រូវបានប្រមូលដោយអ្នកស្រាវជ្រាវពីប្រភពទិន្នន័យដោយតាមរយៈ ការសម្ភាសន៍ជាមួយបុគ្គលពាក់ព័ន្ធ ការដកស្រង់មតិពីក្រុមមនុស្ស ការពិសោធន៍នៅនឹងកន្លែងប្រភពទិន្នន័យផ្ទាល់។ រីឯទិន្នន័យបន្ទាប់បន្សំ គឺជាប្រភេទទិន្នន័យដែលត្រូវបានរកឃើញដោយនរណាម្នាក់ដែលអាចអោយអ្នកស្រាវជ្រាវផ្សេងទៀតយកទៅប្រើប្រាស់បាន។[3]

3.Difference Between Primary and Secondary data , https://keydifferences.com/difference-between-primary-and-secondary-data.html , ត្រូវបានយកមកប្រើប្រាស់នៅថ្ងៃទី១០មេសា២០២០

ចំពោះទិន្នន័យទាំងពីរប្រភេទនេះគឺយើងខ្ញុំទទួលបានតាមរយៈ៖

១. ទិន្នន័យចម្បង ៖ ទិន្នន័យចម្បងគឺពួកយើងធ្វើការប្រមូលទិន្នន័យនេះតាមរយៈការបង្កើតជាកម្រងសំណួរ ដើម្បីសម្ភាសន៍ជាមួយបុគ្គលិកជាន់ខ្ពស់នៅខាងផ្នែកអគ្គីភ័យនៅក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ។ មួយវិញទៀតយើងទទួលបានពីការចុះកម្មសិក្សានៅក្នុងក្រុមហ៊ុនហ្វតតេផ្ទាល់ ដើម្បីធ្វើការប្រមូលឯកសារនិងពត៌មានដែលពាក់ព័ន្ធ ។

២. ទិន្នន័យបន្ទាប់បន្សំ ៖ ចំពោះទិន្នន័យបន្ទាប់បន្សំពួកយើងពីប្រភពមួយចំនួនដូចខាងក្រោម

- ឯកសារពាក់ព័ន្ធដែលទទួលបានពីក្រុមហ៊ុន
- ឯកសារដែលបានមកពីការស្រាវជ្រាវក្នុងប្រព័ន្ធអ៊ិនធឺណេត និង គេហទំព័រ(Website)ផ្សេងៗ
- ឯកសារមួយចំនួនទៀតបានដកស្រង់មកពីការសែតនានា

## ខ. ការប្រមូលទិន្នន័យ

ចំពោះការប្រមូលទិន្នន័យ ដោយសារក្រុមហ៊ុនហ្វតតេមានឯកសារគ្រប់គ្រាន់ និងមានការិយាល័យសម្រាប់ធ្វើការចុះកម្មសិក្សា ។ ដូច្នេះហើយយើងខ្ញុំបានប្រមូលទិន្នន័យតាមគំរូដូចខាងក្រោម៖

- ការចុះកម្មសិក្សា និង អនុវត្តការងារជាក់ស្តែងនៅក្រុមហ៊ុនដើម្បីត្រួតពិនិត្យក្នុងប្រតិបត្តិការងារផ្សេងៗ និងដំណើរការនៃការធានារ៉ាប់រង និងការផ្តល់សំណងជាដើម។
- ការសម្ភាសន៍ជាមួយបុគ្គលិកជាន់ខ្ពស់ផ្នែកអគ្គីភ័យ និងការសាកសួរជាមួយបុគ្គលិកតាមផ្នែកផ្សេងៗដោយកម្រងសំណួរចំនួន ២៩សំណួរ(សូមមើលឧបសម្ព័ន្ធទី១ ៖ កម្រងសំណួរ)។
- ឧបករណ៍ជំនួយក្នុងការស្រាវជ្រាវយើងមានដូចជា ប៊ិច សៀវភៅ ប្រើសម្រាប់កត់ត្រាពត៌មាននៅពេលសម្ភាសន៍ កុំព្យូទ័រនិងទូរស័ព្ទសម្រាប់ ស្រាវជ្រាវឯកសារ និងចងក្រងឯកសារផ្សេងៗទៅជារបាយការណ៍។

## គ. ប្រភេទនៃវិធីសាស្ត្រក្នុងការស្រាវជ្រាវ

នៅក្នុងអត្ថបទស្រាវជ្រាវមួយនេះ យើងខ្ញុំបានជ្រើសរើសយកវិធីសាស្ត្រក្នុងការស្រាវជ្រាវ បែបគុណភាព (Qualitative Method) ដែលជាប្រភេទនៃវិធីសាស្ត្រស្រាវជ្រាវមួយដែលគេធ្វើដោយ ការសង្កេតនៅនឹងទីកន្លែងផ្ទាល់ ការសម្ភាសន៍ទៅកាន់អ្នកជំនាញ និង មានបទពិសោធន៍ជាដើម។[4] វិធីនេះប្រើដើម្បីបកស្រាយនិង

---

[4] What's the Difference between qualitative and quantitative research, ត្រូវបានយកមកប្រើប្រាស់នៅថ្ងៃទី១០មេសា ២០២០ , https://www.snapsurveys.com/blog/qualitative-vs-quantitative-research/

វិភាគអត្ថន័យចេញពីទិន្នន័យ ដែលប្រមូលបាន ដើម្បីជាប្រយោជន៍ក្នុងការយល់ដឹងកាន់តែច្បាស់ពី ដំណើរការ បញ្ហា គំនិត និងអត្ថប្រយោជន៍ ផ្សេងៗ ។ហើយជាក់ស្តែងវិធីសាស្ត្រនេះត្រូវជាមួយការស្រាវជ្រាវរបស់យើងខ្ញុំផងដែរ។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវចំពោះប្រធានបទខាងលើនេះមានសារៈសំខាន់ចំពោះ និស្សិត សហគ្រាស និងប្រជាពលរដ្ឋ ៖

- ចំពោះនិស្សិត
  - ទទួលបានការយល់ដឹងបន្ថែមពីធានារ៉ាប់រងផ្សារភ្ជាប់ជាមួយទ្រឹស្តីដែលបានសិក្សាកន្លងមក
  - យល់ដឹងពីប្រភេទ ដំណើរការ និងសំណងផ្សេងៗរបស់ធានារ៉ាប់រង
  - យល់ដឹងពីសារៈសំខាន់របស់ធានារ៉ាប់រងសំរាប់ប្រើប្រាស់ទៅថ្ងៃអនាគត
  - ផ្តល់ជាបទពិសោធន៍និងទំនាក់ទំនងល្អជាមួយក្រុមហ៊ុន
  - ជាឯកសាសំរាប់និស្សិតជំនាន់ក្រោយសិក្សាស្វែងយល់បន្ថែម
  - យល់ច្បាស់ពីគុណសម្បត្តិផលិតផលនីមួយៗរបស់ធានារ៉ាប់រង
  - យល់ច្បាស់ពីដំណើរការមួយចំនួនរបស់សហគ្រាស
  - ជាផ្នែកមួយសម្រាប់អោយពួកគេយល់ដឹងអំពីប្រវត្តិខ្លះរបស់សហគ្រាស
- ចំពោះសហគ្រាស និងស្ថាប័នពាក់ព័ន្ធ
  - ផ្តល់ជាចំណេះដឹងដល់សហគ្រាសទាំងឡាយដើម្បីជាជំនួយក្នុងការប្រើប្រាស់ផ្សេងៗ
  - ផ្តល់ជាព័តមានបន្ថែមសំរាប់ពួកគេយល់ច្បាស់ពីដំណើរការរបស់ក្រុមហ៊ុន
- ចំពោះប្រជាពលរដ្ឋ
  - ជួយឲ្យប្រជាពលរដ្ឋទូទៅស្គាល់ពីសេវាកម្មធានារ៉ាប់រង
  - ជួយឲ្យពួកគេយល់ដឹងពីការការពារហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិតាមរយៈការទិញធានារ៉ាប់រង
  - ជាជំនួយមួយផ្នែកសម្រាប់ពួកគេទៅលើការយល់ដឹងអំពីផលិតផលផ្សេងៗរបស់ក្រុមហ៊ុន

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ



# ជំពូកទី១
# រំលឹកទ្រឹស្តី

# ជំពូកទី១
# រំលឹកទ្រឹស្តី

## ១.១. លក្ខណៈទូទៅ

### ១.១.១. និយមន័យ

**ធានារ៉ាប់រង** គឺជាកិច្ចសន្យាដែលផ្អែកទៅលើគោលនយោបាយរបស់ក្រុមហ៊ុនធានារ៉ាប់រងណាមួយជា មួយនឹងបុគ្គលឬក្រុមហ៊ុនដើម្បីអោយពួកគេទទួលបានការការពារ ឬ សំណងហិរញ្ញវត្ថុដើម្បីទប់ស្កាត់ និងការខាតបង់ពីសំណាក់ក្រុមហ៊ុនធានារ៉ាប់រង។ ក្រុមហ៊ុនធានារ៉ាប់រងបានវិភាគហានិភ័យទាំងឡាយរបស់អតិថិជនដើម្បី ធ្វើការផ្តល់សំណងមួយដែលទៅតាមអ្វីដែលបានសរសេរ នៅក្នុងបណ្ណ័ធានារ៉ាប់រងទៅកាន់អតិថិជន។

**ធានារ៉ាប់រង** សំដៅដល់ការធ្វើកិច្ចសន្យាធានារ៉ាប់រងដែលក្នុងនោះ អ្នកដែលត្រូវបានធានារ៉ាប់រងត្រូវបង់បុព្វលាភធានារ៉ាប់រងទៅឲ្យក្រុមហ៊ុនធានារ៉ាប់រង ហើយក្រុមហ៊ុនធានារ៉ាប់រងត្រូវធ្វើសំណងដល់ការខូចខាតឬបាត់បង់ទ្រព្យសម្បត្តិដែលបង្កឡើងដោយហេតុការណ៍គ្រោះថ្នាក់ ឫក៏ធ្វើសំណង់នៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងស្លាប់ របួស ពិការ មានជំងឺ ឫនៅពេលដែលបុគ្គលនោះឈានដល់ដំណាក់កាលណាមួយដែលភាគីទាំងពីរបានយល់ ព្រមគ្នាដូចមានចែងក្នុងកិច្ចសន្យាធានារ៉ាប់រង។

**កិច្ចសន្យាធានារ៉ាប់រង** សំដៅដល់កិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ ដែលធ្វើឡើងដោយក្រុមហ៊ុនធានារ៉ាប់រង និងអ្នកត្រូវបានធានារ៉ាប់រងដែលតាមរយៈនោះក្រុមហ៊ុនធានារ៉ាប់រងព្រមទទួលនូវហានិភ័យជាក់លាក់ណាមួយ ដោយទទួលមកវិញនូវការបង់បុព្វលាភធានារ៉ាប់រងពីអ្នកដែលត្រូវបានធានារ៉ាប់រង។

**កំណត់សំគាល់** សំដៅដល់ឯកសារបណ្តោះអាសន្នដែលចេញដោយក្រុមហ៊ុនធានារ៉ាប់រងឫភ្នាក់ងារធានារ៉ាប់រង ជំនួសបណ្ណ័សន្យារ៉ាប់រងស្ថាពរ។

**ក្រុមហ៊ុនធានារ៉ាប់រង** សំដៅទៅដល់ក្រុមហ៊ុន ធានារ៉ាប់រងអាយុជីវិត ក្រុមហ៊ុន ធានារ៉ាប់រងទូទៅ ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច និង ក្រុមហ៊ុនធានារ៉ាប់រងបន្ត។

**គ្រឹះស្ថានធានារ៉ាប់រង** សំដៅដល់ក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង ជើងសាធានារ៉ាប់រង និងក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង។

**បណ្ណសន្យារ៉ាប់រង** សំដៅដល់ឯកសារចងភ្ជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ ដែលចេញដោយក្រុមហ៊ុនធានារ៉ាប់រងដោយមានកំណត់ពី ខ្លឹមសារសំខាន់ដែលចែងពីខ្លឹមសាសំខាន់និងចែងពីលក្ខខណ្ឌលំអិត ដែល

បានព្រមព្រៀងរវាង ក្រុមហ៊ុនធានារ៉ាប់រង និង អ្នកត្រូវបានធានារ៉ាប់រងក្នុងកិច្ចសន្យាធានារ៉ាប់រង។ បណ្ណសន្យារ៉ាប់រងត្រូវភ្ជាប់មកវិញជាមួយនូវវិញ្ញាបនបត្រធានារ៉ាប់រង ឬឯកសារពាក់ព័ន្ធផ្សេងៗទៀត។

**បុព្វលាភធានារ៉ាប់រង** សំដៅដល់ចំនួនទឹកប្រាក់ដែលអ្នកត្រូវបានធានារ៉ាប់រងត្រូវបង់អោយទៅអោយក្រុមហ៊ុន តាមការកំណត់របស់ក្រុមហ៊ុនធានារ៉ាប់រងនៅក្នុងបណ្ណសន្យារ៉ាប់រង។

**សំណងធានារ៉ាប់រង** សំដៅដល់សំណងជាប្រាក់ឬវត្ថុឬសំណងរួមជាប្រាក់និងវត្ថុដែលត្រូវបានសងដោយក្រុមហ៊ុនធានារ៉ាប់រង។

**អ្នកត្រូវបានធានារ៉ាប់រង** សំដៅដល់រូបវន្តបុគ្គលឬ នីតិបុគ្គលដែលទិញបណ្ណសន្យារ៉ាប់រងក្នុងករណីមួយចំនួនអាចជាម្ចាស់បណ្ណសន្យារ៉ាប់រងផងនិងអាចជាអ្នកត្រូវបានធានារ៉ាប់រងផង។

**អ្នកស្នើសុំធានារ៉ាប់រង** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលអាចនឹងក្លាយជាអ្នកត្រូវបានធានារ៉ាប់រងនាពេលអនាគតដែលបំពេញ និងចុះហត្ថលេខាលើទម្រង់បែបបទជាលាយលក្ខណ៍អក្សររបស់ក្រុមហ៊ុនធានារ៉ាប់រងអំពីស្ថានភាពផ្ទាល់របស់បុគ្គលនោះ។

គ្រប់អត្ថន័យរបស់ពាក្យបច្ចេកទេសខាងលើត្រូវបានដកស្រង់ចេញពីច្បាប់ស្តីពីធានារ៉ាប់រង មាត្រាទី៤ ដែលចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៤។

**១.១.២. ប្រវត្តិធានារ៉ាប់រង**

ធានារ៉ាប់រង គឺជាដាននៃការអភិវឌ្ឍនៃជំនួញបែបទំនើបនៃការធានារ៉ាប់រងដើម្បីប្រឆាំងនឹងហានិភ័យជាពិសេសចំពោះ ធានារ៉ាប់រងលើនាវា ធានារ៉ាប់រងលើទ្រព្យសម្បត្តិ ធានារ៉ាប់រងលើអាយុជីវិត ធានារ៉ាប់រងលើគ្រោះថ្នាក់លើយានយន្ត និងធានារ៉ាប់រងសុខភាព។

វិធីសាស្ត្រដំបូងនៃ ការផ្ទេរឬបែងចែកហានិភ័យហិរញ្ញវត្ថុនៅក្នុងសេដ្ឋកិច្ចត្រូវបានគេអនុវត្តដំបូងដោយអ្នកជំនួញជនជាតិចិននិង BABYLONIAN នៅក្នុងកំឡុង 3rd និង 2nd millennia BC ។ អ្នកជំនួញចិនបានជួបនឹងគ្រោះថ្នាក់ដោយចៃដន្យពេលដែលកំពុងធ្វើដំណើរតាមទន្លេ។ ដូច្នេះហើយអ្នកជំនួញទាំងនោះបានបង្កើត ប្រព័ន្ធមួយដែលធានារ៉ាប់រងលើការការបាត់បង់ទំនិញ និងផលិតផលរបស់ពួកគេ ដោយពួកគេបានខ្ចីប្រាក់ពីអ្នកចងការប្រាក់ត្រូវបង់ប្រាក់ទៅវិញនូវ ចំនួនបន្ថែមខ្លះដើម្បីជាការសងនៃការធានារ៉ាប់រងទៅលើសុវត្ថិភាពទៅលើទំនិញរបស់ពួកគេ។ ពួកដែលអោយប្រាក់គេខ្ចីនៅពេលដែលពួកអ្នកជំនួញទាំងនោះបាត់បង់ទំនិញក្នុងកំឡុងពេលដឹកតាមសមុទ្រនោះពួកគេ នឹង ផ្តល់ជាប្រាក់សងទៅដល់អ្នកជំនួញដែលបានខ្ចីរបស់ប៉ុន្តែបើសិន ជាមិនមានពួកគេបញ្ហាកើតអ្វីឡើងក្នុងកំឡុងពេលដឹកទំនិញពួកអ្នកជំនួញទាំងនោះត្រូវបង់ប្រាក់

បន្ថែមទៅឲ្យពួកគេវិញ។បន្ទាប់មកមានការវិវត្តន៍ជាច្រើនដំណាក់កាលរហូតដល់ បច្ចុប្បន្នមានការធានារ៉ាប់រងបែបទំនើបជាច្រើនប្រភេទដូចជា៖

- ធានារ៉ាប់រងលើអចលនទ្រព្យ : នាកំឡុងឆ្នាំ១៩៦៦អគ្គីភ័យបានបំផ្លាញផ្ទះប្រជាពលរដ្ឋច្រើនជាង 13,000ខ្នងនៅក្នុងទីក្រុងឡុង ដែលហៅថា ( Great Fire of London ) ក្រោយព្រឹត្តិការណ៍ដ៏រន្ធត់នេះមកនៅកំឡុងឆ្នាំ១៩៧៦ ការធានារ៉ាប់រងលើអចលនទ្រព្យត្រូវបានបង្កើតឡើង។
- ធានារ៉ាប់រង់លើមុខជំនួញ : ក្នុងកំឡុងពេលចុងសតវត្សទី១៧ លោក Edward Lloyd បានបង្កើតផ្ទះកាហ្វេ មួយនៅតាមផ្លូវ Tower street ក្នុងទីក្រុងឡុង ដែលមានប្រជាប្រិយភាពខ្លាំងនិងប្រជុំទៅដោយពួកម្ចាស់នាវា ពាណិជ្ជករ នាវិក ក្នុងការពិភាក្សាផ្សេងៗ ។ វាក៏បានក្លាយទៅជាទីកន្លែងសម្រាប់ការជួបជុំរបស់ក្រុមឧស្សាហកម្មដឹកជញ្ជូនតាមនាវា ដែលមានបំណងក្នុងការធានាចំពោះទំនិញលើនាវា និងនាវា។ទាំងនេះក្នុងគោលបំណងធានានិងគាំទ្រចំពោះការប្រថុយរបស់នាវា ។ វាក៏បានវិវត្តន៍ខ្លួនទៅជាទីផ្សារធានារ៉ាប់រងមួយក្នុងទីក្រុងឡុងមានឈ្មោះ ថា ″Lloyd’s of London″ ។
- ធានារ៉ាប់រងអាយុជីវិត : វាបានបង្កើតឡើងនៅមុនសតវត្សទី១៨ ហើយក្រុមហ៊ុនដំបូងដែលបានបង្កើតធានារ៉ាប់រងអាយុជីវិតនេះគឺ ″Amicable society for a Perpetual Assurance office″ ក្នុងទីក្រុងឡុង ក្នុងឆ្នាំ១៧០៦ដោយលោក William Talbot និងលោក Sir Thomas ។
- ធានារ៉ាប់រងលើគ្រោះថ្នាក់ ធានារ៉ាប់រងនេះបានបង្កើតនៅចុងសតវត្សទី១៩ ហើយក្រុមហ៊ុនទីមួយដែលបានបង្កើតវាគឺ ″Railway passengers Assurance″ នៅក្នុងឆ្នាំ១៨៤៨ក្នុងប្រទេសអង់គ្លេស។[5]

### ១.១.៣. ប្រវត្តិធានារ៉ាប់រងក្នុងប្រទេសកម្ពុជា

បើយោងទៅតាមប្រវត្តិរបស់ធានារ៉ាប់រងក្នុងប្រទេសកម្ពុជាយើងអាចកត់សម្គាល់បានថាមានការវិវត្តិន៍ចំនួន ៣ ដំណាក់កាល ៖

- ដំណាក់កាលទី១ ពីឆ្នាំ១៩៥៦ដល់ឆ្នាំ១៩៧៥

អជីវកម្មធានារ៉ាប់រងនៅក្នុងប្រទេសកម្ពុជាបានចាប់ផ្ដើមជាលើកដំបូងក្នុង ១៩៥៦ ជាមួយនឹងវត្តមានរបស់ក្រុមហ៊ុនធានារ៉ាប់រងមួយចំនួនដើម្បីបំពេញសេចក្ដីត្រូវការនៅពេលនោះ ។ ប៉ុន្តែចាប់ពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ១៩៦៣ រាជរដ្ឋាភិបាលបានប្រមូលទិញភាគហ៊ុនឯកជនរបស់ក្រុមហ៊ុនធានារ៉ាប់រងមកវិញទាំងអស់។នៅថ្ងៃទី ០៩ មករា ឆ្នាំ១៩៦៤ រដ្ឋសភាបានអនុម័តច្បាប់ដែលអនុញ្ញាតឲ្យរដ្ឋគ្រប់គ្រងលើ

[5] History Of Insurance , https://en.wikipedia.org/wiki/History_of_insurance , បានយកមកប្រើប្រាស់នៅក្នុងថ្ងៃទី១មីនា២០២០

ធានារ៉ាប់រងទាំងអស់នៅក្នុងប្រទេសកម្ពុជា។ ចាប់ពីពេលនោះមកក្រុមហ៊ុនធានារ៉ាប់រងជាតិមួយដែលមានឈ្មោះថា (Société National d' Assurance )ត្រូវបានបង្កើតឡើងនិងជាក្រុមហ៊ុនផ្តាច់មុខតែមួយក្នុងទីផ្សារ។ ក្រុមហ៊ុនធានារ៉ាប់រងជាតិនេះបានបម្រើទីផ្សារចាប់ពី ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ១៩៦៤ ដល់ ថ្ងៃទី ១៧ មេសា ឆ្នាំ ១៩៧៥។

នៅក្នុងរបបប៉ុលពតឬរបបខ្មែរក្រហម(១៩៧៥ ដល់ ១៩៧៩) ហេដ្ឋារចនាសម្ព័ន្ធត្រូវបានបំផ្លាញស្ទើរតែទាំងស្រុង ទំនិញនិងសេវាកម្មនានាត្រូវបានលុបចោល ហើយលើសពីនេះរាល់សកម្មភាពរបស់សេវាកម្មធានារ៉ាប់រងទាំងឡាយត្រូវបានលុបចោល។

- ដំណាក់កាលទី២ ពីឆ្នាំ ១៩៩០ ដល់ឆ្នាំ ១៩៩៩

យោងតាមគោលនយោបាយកំណែរទម្រង់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលអនុក្រឹត្យលេខ២៤ ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ១៩៩០ ត្រូវបានចេញដែលពាក់ព័ន្ធនឹងការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ អនុក្រឹត្យក៏ត្រូវបានលើកឡើងផងដែរអំពីការបង្កើតក្រុមហ៊ុនធានារ៉ាប់រងជាតិកម្ពុជាដែលមានឋានៈជានាយកដ្ឋាន។

នៅថ្ងៃទី៣០ មករា ឆ្នាំ ១៩៩២ រដ្ឋសភាបានអនុម័តច្បាប់ស្តីពីការបង្កើតអជីវកម្មធានារ៉ាប់រងដែលមាន ៤ មាត្រា ហើយវិស័យធានារ៉ាប់រងនេះត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋ។ គោលបំណងនៃច្បាប់នេះគឺជាការរួមចំណែកដល់ ការអភិវឌ្ឍន៍សង្គមនិងសេដ្ឋកិច្ចនិងផ្តល់សំណង់ដល់ជនរងគ្រោះពីការបាត់បង់ដែលបណ្តាលមកពីគ្រោះមហន្តរាយធម្មជាតិ និងគ្រោះថ្នាក់ផ្សេងៗ។

បន្ទាប់ពី ច្បាប់ស្តីពីការបង្កើតអជីវកម្មធានារ៉ាប់រងត្រូវបានប្រកាសអោយប្រើមានព្រឹត្តិការណ៍សំខាន់ៗមួយចំនួនដូចតទៅ៖

- នៅថ្ងៃទី ០៩ មិថុនា ឆ្នាំ ១៩៩២ទីស្តីការគណៈរដ្ឋមន្ត្រីបាន អនុម័តអនុក្រឹត្យស្តីពីការត្រួតពិនិត្យអាជីវកម្មធានារ៉ាប់រងដែលមាន ៣៨មាត្រា។
- នៅថ្ងៃទី២ កញ្ញា ឆ្នាំ១៩៩២ ទីស្តីការគណៈរដ្ឋមន្ត្រីបានចេញសេចក្តីជូនដំណឹងលេខ១៥៣០ ស្តីពីការអនុញ្ញាតឲ្យក្រុមហ៊ុនធានារ៉ាប់រងជាតិកម្ពុជាចាប់ផ្តើមអជីវកម្មរបស់ខ្លួនចាប់ពីត្រីមាសទី៤ នៃឆ្នាំ ១៩៩២។
- នៅថ្ងៃទី១៥ តុលា ១៩៩២ យោងតាមការសម្រេចរបស់ គណៈអចិន្ត្រៃយ៍គណៈកម្មាធិការទីស្តីការគណៈរដ្ឋមន្ត្រី បានចេញសេចក្តីជូនដំណឹងលេខ ១៨១១ ដែលអនុញ្ញាតអោយក្រុមហ៊ុនកាមិនកូសហការជាមួយក្រុមហ៊ុនបារាំងមួយឈ្មោះថា ( GEATER ) ។ហើយនៅថ្ងៃទី១៣ មិថុនា ឆ្នាំ១៩៩៣ ក្រុមហ៊ុនកាមិនកូបានដាក់ចេញនូវគោលនយោបាយធានារ៉ាប់រងសមុទ្រជាលើកដំបូងដល់អតិថិជនរបស់ខ្លួន។

– នៅថ្ងៃទី ១ សីហា ឆ្នាំ១៩៩៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានអនុម័ត ប្រកាសរួមស្តីពីការធានារ៉ាប់រងស៊ីវិលរបស់ម្ចាស់យានយន្ត។ ប្រកាសនេះមានក្រសួងពាក់ព័ន្ធចំនួន៣ គឺ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងក្រសួងសាធារណៈការនិងដឹកជញ្ជូន។ គោលបំណងនៃសេចក្តីប្រកាសនេះ គឺដើម្បីផ្តល់ការធានារ៉ាប់រងដល់គ្រប់ប្រភេទយានយន្តទាំងអស់និងម្ចាស់យានយន្ត។

– នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៩៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញសេចក្តីប្រកាសស្តីពីតារាងតម្លៃ និងតារាងប្រាក់សំណង សម្រាប់ការធានារ៉ាប់រងយានយន្តហើយច្បាប់នេះត្រូវបានប្រកាសឲ្យប្រើសម្រាប់ធានារ៉ាប់រងស៊ីវិលរបស់ម្ចាស់យានយន្ត។

– នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៦ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញសេចក្តីប្រកាសដើម្បីអនុញ្ញាតឲ្យក្រុមហ៊ុន Indochina Insurance Union ក្លាយជាភ្នាក់ងាររបស់ក្រុមហ៊ុនកាមិនកូ។

– នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៩៦ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញសេចក្តីប្រកាសដើម្បីអនុញ្ញាតឲ្យក្រុមហ៊ុន Asia Insurances (Cambodia) Ltd ក្លាយជាភ្នាក់ងាររបស់ក្រុមហ៊ុនកាមិនកូ។

– នៅថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៩៧ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញសេចក្តីប្រកាសដើម្បីអនុញ្ញាតឲ្យក្រុមហ៊ុន Forte Trading Private Ltd ក្លាយជាភ្នាក់ងាររបស់ក្រុមហ៊ុនកាមិនកូ។

- ដំណាក់កាលទី៣ ពីឆ្នាំ ២០០០ ដល់បច្ចុប្បន្ន

ចាប់តាំងពីឆ្នាំ ២០០០ មកប្រទេសកម្ពុជាបានផ្លាស់ប្តូទៅទីផ្សារសេដ្ឋកិច្ចសេរីដែលអនុញ្ញាតឱ្យមានកំណើនទីផ្សារធានារ៉ាប់រងនៅប្រទេសកម្ពុជា។ រដ្ឋាភិបាលបានធ្វើបច្ចុប្បន្នភាពច្បាប់និងបទបញ្ញាដែលបានប្រកាសបទបញ្ញាដែលត្រូវបានប្រកាសតាំងពីឆ្នាំ ១៩៩០ - ១៩៩៩ រួមទាំងច្បាប់ស្តីអំពីការបង្កើតអាជីវកម្មធានារ៉ាប់រងទៅក្នុងច្បាប់ថ្មីស្តីពីធានារ៉ាប់រងមាត្រា ៥៦ ដែលអនុមត្តដោយរដ្ឋសភានៅថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០០០។បន្ទាប់មកអនុក្រឹត្យស្តីពីធានារ៉ាប់រងត្រូវបានអនុម័តនៅថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០០១។

បន្ទាប់ពីច្បាប់ និង អនុក្រឹត្យស្តីពីធានារ៉ាប់រងត្រូវបានប្រកាសឱ្យក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានចេញប្រកាសនិងសារាចរមួយចំនួន។អំឡុងពេលនេះមានការអភិវឌ្ឍសំខាន់ជាច្រើនដូចជាៈ

– នៅថ្ងៃ១៧ខែសីហាឆ្នាំ២០០០ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញសេចក្តីប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃនាយដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុដែលកំណត់តួនាទី និងទំនួលខុសត្រូវផ្នែកធានារ៉ាប់រង។

– នៅថ្ងៃ ៣១ ខែធ្នូ ឆ្នាំ ២០០១ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចបង្កើតសហគ្រាសសារធាណៈមួយទៀតដែលមានលក្ខណៈជាក្រុមហ៊ុនរដ្ឋមានឈ្មោះថាក្រុមហ៊ុនធានារ៉ាប់រង ( កម្ពុជារ៉ែ ) ក្រោមការគ្រប់គ្រងបច្ចេកទេសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងហិរញ្ញវត្ថុ។

– នៅថ្ងៃ ០៩ ខែ ធ្នូ ឆ្នាំ ២០០៣ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចេញផ្សាយសារាចរស្តីអំពីការផ្តល់អាជ្ញាបណ្ណ័បណ្តោះអាសន្ន ក្នុងគោលបំណងលើកកម្ពស់អាជីកម្មធានារ៉ាប់រងស្របតាមទីផ្សារនៅពេលនោះ។

– នៅថ្ងៃទី១៤ ខែតុលាឆ្នាំ២០០៥ សមាគមធានារ៉ាប់រងទូទៅកម្ពុជា ត្រូវបានបង្កើតឡើងដោយមានការយល់ព្រមពីការចុះបញ្ជីពីក្រសួងមហាផ្ទៃ។គោលដៅនៃសមាគមធានារ៉ាប់រងទូទៅកម្ពុជាគឺ ដើម្បីពង្រឹងទីផ្សារធានារ៉ាប់រងទូទៅ ដោយមធ្យោបាយជាច្រើនដែលមានចែងនៅក្នុងមាត្រានិងអនុស្សារណៈនៃសមាគមធានារ៉ាប់រងទូទៅកម្ពុជា។[6]

### ១.១.៤. ចំណាត់ថ្នាក់ប្រភេទនៃសេវាធានារ៉ាប់រង

នៅក្នុងវិស័យធានារ៉ាប់រងទូទៅ នៅក្នុងព្រះរាជាណាចក្រកម្ពុជាចំពោះចំណាត់ថ្នាក់នៃប្រភេទសេវាកម្មឬក៏ផលិតផលនោះត្រូវបានបែងចែកជា ៧ ចំណាត់ថ្នាក់ ៖

**ធានារ៉ាប់រងលើយានយន្ត (Auto Mobile Insurance)**

កិច្ចសន្យាធានារ៉ាប់រងយានយន្ត ជួយការពារចំណាយអតិថិជនដែលបានទិញនិងមានយានយន្តពេលមានហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍ ចោរកម្មមិនថាអតិថិជនធ្វើដំណើរក្នុងមុខជំនួញឬដំណើរកម្សាន្តគឺអតិថិជនអាចកាត់បន្ថយចំណាយទៅលើ ការជុសជុល បានយ៉ាងច្រើនដោយអតិថិជនបានទទួលសំណងពីក្រុមហ៊ុនធានារ៉ាប់រង។ចំពោះធានារ៉ាប់រងលើយានយន្តត្រូវបានបែងចែកមានដូចជា Commercial vehicle, Private vehicle, Motor cycle ។

**ធានារ៉ាប់រងលើទ្រព្យសម្បត្តិ (Property Insurance)**

ធានារ៉ាប់រងលើទ្រព្យសម្បត្តិ សំដៅលើការការពារទ្រព្យសម្បត្តិនិងការធានាលើបំណុល។ ជាក់ស្តែងរាល់អជីវកម្មនិងស្ថាប័ននានា ដូចជាសណ្ឋាគារ ការិយាល័យ ផ្សារទំនើរ និងរោងចក្រជាដើម សុទ្ធតែអាចប្រឈមមុខនឹងហានិភ័យឧបទ្ទហេតុដោយសារកត្តាជាច្រើន។ដូច្នេះដើម្បីកាត់បន្ថយហានិភ័យទាំងនោះ សេវាធានារ៉ាប់រងលើទ្រព្យសម្បត្តិដែលមានវិសាលភាពនៃការធានាធំធេងគឺជាកត្តាចាំបាច់សម្រាប់ អាជីវកម្មទាំងអស់ ។ រាល់សហគ្រាសពាណិជ្ជកម្ម ឬឧស្សាហកម្ម ត្រូវប្រាកដថាមានការធានាការពារពេញលេញចំពោះការខូចខាត ឬបានបាត់បង់ដែលអាចកើតមានឡើងព្រមទាំងការអាក់ខានធ្វើអាជីវកម្មដោយសារការខូចខាតឬបាត់បង់ទ្រព្យសម្បតិទាំងនោះ។

---

[6] History Of Insurance Industry in Cambodia , https://angkornation.com/history-insurance-industry-cambodia/ ដែលបានយកមកប្រើប្រាស់នៅថ្ងៃទី៣ខែមីនា២០២០

**ធានារ៉ាប់រងលើការដឹកជញ្ជូនទំនិញ** (Marine cargo Insurance)

ធានារ៉ាប់រងលើការដឹកជញ្ជូនទំនិញ ធានាលើហានិភ័យលើការបាត់បង់ឬ ការខូចខាតទំនិញខណៈពេលដែលដឹកជញ្ជូនដោយវិធីសាស្ត្រនៃការដឹកជញ្ជូនដូចជា ៖ តាមសមុទ្រ ផ្លូវដែក ផ្លូវអាកាស ឬតាមប្រៃសណីយ៍ គ្រប់ទីកន្លែងលើពិភពលោកពីចំណុចចាប់ផ្តើមដល់ចំណុចគោលដៅចុងក្រោយ។

**ធានារ៉ាប់រងគ្រោះថ្នាក់បុគ្គល** (Personal accident Insurance)

ការធានារ៉ាប់រងគ្រោះថ្នាក់ផ្ទាល់ខ្លួន គឺជាកិច្ចព្រមព្រៀងរវាងក្រុមហ៊ុនធានារ៉ាប់រងនិងអ្នកដែលបានធានាក្នុងការផ្តល់សំណងហិរញ្ញវត្ថុដល់គ្រួសាររបស់គាត់ក្នុងករណីមានពិការភាពអចិន្ត្រៃយ៍ ឬ មរណភាពដែលបង្ករឡើងដោយផ្ទាល់និងដោយសារតែគ្រោះថ្នាក់ណាមួយ ។ ការធានារ៉ាប់រងពេញ ២៤ ម៉ោងត្រូវបានផ្តល់សម្រាប់ធានាលើ គ្រោះថ្នាក់អំឡុងពេលបំពេញការងារ ឬការលម្ហែកម្សាន្ត។

**ធានារ៉ាប់រងវិស្វកម្ម** (Engineering Insurance)

ធានារ៉ាប់រងលើវិស្វកម្មគឺធានាលើសេវាកម្មធានារ៉ាប់រងលើការសាងសង់និងការតំឡើង ដើម្បីផ្តល់ការការពារគ្រប់បែបយ៉ាងក្នុងកំឡុងពេលសាងសង់និងការតំឡើង។

**ធានារ៉ាប់រងសុខភាព** ( Medical Insurance)

ធានារ៉ាប់រងសុខភាព គឺជាធានារ៉ាប់រងដែលបានផ្តល់នូវការធានាដ៏ទូលំទូលាយសម្រាប់ការចំណាយថ្លៃព្យាបាលចាំបាច់ រួមទាំងការព្យាបាលនៅមន្ទីរពេទ្យ ។

**ធានារ៉ាប់រងផ្សេងៗ** (Miscellaneous Insurance)

ធានារ៉ាប់រងផ្សេងៗ គឺជាធានារ៉ាប់រងដែលសំដៅទៅលើកិច្ចសន្យាធានារ៉ាប់រងក្រៅពីកិច្ចសន្យាធានារ៉ាប់រងអាយុជីវិតធានារ៉ាប់រងលើអគ្គិភ័យនិងធានារ៉ាប់រងលើការដឹកជញ្ជូនទំនិញ។[7]

### ១.១.៥ ប្រភេទធានាក្រុមហ៊ុនធានារ៉ាប់រង

បច្ចុប្បន្ននេះយើងឃើញថាមានក្រុមហ៊ុនធានារ៉ាប់រងចំនួន ៣០ ក្រុមហ៊ុនដែលកំពុងតែដំណើរការនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលក្នុងនោះធានារ៉ាប់រងទូទៅមានចំនួន ១៥ ក្រុមហ៊ុនធានារ៉ាប់រងលើអាយុជីវិតមានចំនួន ៩ និងក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច មានចំនួន ៥ ហើយក្រុមហ៊ុនទាំងអស់នេះត្រូវបានធ្វើការធានារ៉ាប់រងបន្តកម្ពុជា(កម្ពុជារី)ដែលក្រុមហ៊ុនទាំងអស់នោះមានដូចជា ៖

[7] សមាគមន៍ធានារ៉ាប់រងកម្ពុជា,របាយការណ៍ស្ថិតិធានារ៉ាប់រងទូទៅ , យកមកប្រើប្រាស់នៅថ្ងៃទី៧មីនា២០២០ http://www.iac.org.kh/

ក្រុមហ៊ុនធានារ៉ាប់រងទូទៅទាំងអស់មានចំនួន ១៥ មានដូចជា ៖

១. ក្រុមហ៊ុនធានារ៉ាប់រង ហ្វតតេ Forte Insurance

២. ក្រុមហ៊ុនធានារ៉ាប់រង អេស៊ីអា Asia Insurance

៣. ក្រុមហ៊ុនធានារ៉ាប់រង កម្ពុជា-វៀតណាម Cambodia-Vietnam Insurance

៤. ក្រុមហ៊ុនធានារ៉ាប់រង កាមិនកូ Caminco Insurance

៥. ក្រុមហ៊ុនធានារ៉ាប់រង កម្ពុប៊ែង ឡុងប៉ាក់ Campu Lonpac Insurance

៦. ក្រុមហ៊ុនធានារ៉ាប់រង អ៊ីនហ្វីនីធី Infinity Insurance

៧. ក្រុមហ៊ុនធានារ៉ាប់រងភាពជាដៃគូរ People & Partner Insurance

៨. ក្រុមហ៊ុនធានារ៉ាប់រងអីស East Insurance Plc.

៩. ក្រុមហ៊ុនធានារ៉ាប់រង លីហួរ Ly Hour Insurance Plc.

១០. ក្រុមហ៊ុនធានារ៉ាប់រង ហ្វីលីព Phillip General Insurance ( Cambodia ) Plc.

១១. ក្រុមហ៊ុនធានារ៉ាប់រង នីវ៉ា Newa Insurance (Cambodia Plc).

១២. ក្រុមហ៊ុនធានារ៉ាប់រង តារ៉ា Dara Insurance Plc.

១៣. ក្រុមហ៊ុនធានារ៉ាប់រងស៊ីប៊ី CB General Insurance

១៤. ក្រុមហ៊ុនធានារ៉ាប់រង Prosur Micro Insurance Plc.

១៥.ក្រុមហ៊ុនធានារ៉ាប់រង Etiqa General Insurance (Cambodia) Plc.

ក្រុមហ៊ុនធានារ៉ាប់រងលើអាយុជីវិតទាំងអស់មានចំនួន ៩ មានដូចជា ៖

១. ក្រុមហ៊ុនធានារ៉ាប់រង ហ្វតតេ Forte Life Insurance

២. ក្រុមហ៊ុនធានារ៉ាប់រង មេនូឡាយហ្វ៍ Manulife (Cambodia)

៣. ក្រុមហ៊ុនធានារ៉ាប់រង ព្រូដិនសល Prudential (Cambodia)

៤. ក្រុមហ៊ុនធានារ៉ាប់រង សុវណ្ណាភូមិ ឡាយហ្វ៍ Savannaphum life (Cambodia)

៥. ក្រុមហ៊ុនធានារ៉ាប់រង ដាយ អ៊ិឈិ ឡាយហ្វ៍ Dai-ichi Life Insurance (Cambodia) Plc.

៦. ក្រុមហ៊ុនធានារ៉ាប់រង អេ អាយ អេ AIA (Cambodia) Life Insurance Plc.

៧. ក្រុមហ៊ុនធានារ៉ាប់រងហ្គ្រេន ឆាយណា ឡាយហ្វ៍ Grand China Life Insurance Plc.

៨. ក្រុមហ៊ុនធានារ៉ាប់រង ហ្វីលីព ឡាយហ្វ៍Phillip Life Assurance (Cambodia) Plc.

៩. ក្រុមហ៊ុនធានារ៉ាប់រង Etiqa Life Insurance (Cambodia) Plc.

ស្របជាមួយគ្នានេះដែរក៏មានក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច Micro Insurance ចំនួន ៥ ដែលកំពុងដំណើរការនៅក្នុងប្រទេសកម្ពុជាមានដូចជា ៖

1. ក្រុមហ៊ុនធានារ៉ាប់រង ប៊ីម៉ា BIMA Cambodia
2. ក្រុមហ៊ុនធានារ៉ាប់រង Cambodian People Micro Insurance Plc. (CPMI)
3. ក្រុមហ៊ុនធានារ៉ាប់រង អេច អាយម៉ាយក្រូ ភីអិលស៊ី H.I Micro Insurance Plc.
4. ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច មេគង្គ ភីអិលស៊ី Mekong Micro insurance Plc.
5. ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច Prevoir (KAMPUCHEA) Micro Life Insurance Plc. (PKMI) [8]

---

[8] សមាគមធានារ៉ាប់រងកម្ពុជា,ក្រុមហ៊ុនធានារ៉ាប់រងនៅក្នុងប្រទេសកម្ពុជា ,យកមកប្រើប្រាស់នៅថ្ងៃទី១០មីនា២០២០ http://www.iac.org.kh/

# ជំពូកទី២

# ស្ថានភាពទូទៅរបស់ក្រុមហ៊ុនធានារ៉ាប់រង ហ្វតតេ

# ជំពូកទី២

# ស្ថានភាពទូទៅរបស់ក្រុមហ៊ុនធានារ៉ាប់រង ហ្វតតេ

## ២.១. ប្រវត្តិសង្ខេបរបស់ក្រុមហ៊ុន

ក្រុមហ៊ុនហ្វតតេ ជាក្រុមហ៊ុនដែលឈានមុខគេនៅលើវិស័យធានារ៉ាប់រងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានផ្តល់នូវសេវាកម្មគ្រប់តម្រូវការដែលគួរឲ្យជឿទុកចិត្ត។ លើសពីនេះទៅទៀតក្រុមការងារមានជំនាញ និង ក្រុមហ៊ុនបានចំណាយពេលវេលាស្វែងយល់និងចេញបណ្ណ៍សន្យាធានារ៉ាប់រងស្របនិងតម្រូវការផ្ទាល់ខ្លួន គ្រួសារ ឬ ជំនួញរបស់អតិថិជន។

ក្រុមហ៊ុនហ្វតតេ បានបើកដំណើរការសេវាកម្មធានារ៉ាប់រងរបស់ខ្លួនក្នុងនាមជាក្រុមហ៊ុនជើងសាធានារ៉ាប់រងនៅរាជធានីភ្នំពេញនៅឆ្នាំ ១៩៩៦ ហើយបានក្លាយទៅជាក្រុមហ៊ុនធានារ៉ាប់រងមួយក្នុងចំណោមក្រុមហ៊ុនធានារ៉ាប់រងដំបូងគេបង្អស់ដែលបានបង្កើតឡើងនៅប្រទេសកម្ពុជា។ នៅឆ្នាំ ១៩៩៨ ក្រុមហ៊ុនធានារ៉ាប់រងហ្វតតេបានបើកការិយាល័យផ្ទាល់ខ្លួននៅចំកណ្តាលនៃបេះដូងរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា។ ដោយមានការគាំទ្រពី ក្រុមហ៊ុនធានារ៉ាប់រងបន្តធំៗនៅក្នុងតំបន់ និង ជុំវិញពិភពលោក ក្រុមហ៊ុនធានារ៉ាប់រងហ្វតតេបាន ចាប់ផ្តើមដំណើរការក្នុងគោលបំណងផ្តល់នូវការធានារ៉ាប់រងដ៏ធំទូលំទូលាយគ្រប់ហានិភ័យនៅទូទាំងប្រទេសកម្ពុជា។ ជាមួយនិងការជ្រោមជ្រែងពីសំណាក់អ្នកធានារ៉ាប់រងធំៗនៅក្នុងតំបន់ និងជុំវិញពីពិភពលោក ក្រុមហ៊ុនបានដាក់ចេញគោលដៅដើម្បីផ្តល់នូវការគ្រប់គ្រងដែលមានសុវត្ថភាពនិងទូលំទូលាយដល់ប្រទេសកម្ពុជា។ ក្នុងរយៈពេលដ៏ខ្លី ហ្វតតេបានក្លាយជាក្រុមហ៊ុនធានារ៉ាប់រងធំជាងគេ និងឈានមុខគេនៅក្នុងព្រះរាជាណាចក្រកម្ពុជា។យ៉ាងណាក្តីក្រុមហ៊ុននៅតែបន្តឥតងាករេក្នុងការផ្តោតសំខាន់លើចំណុចខ្លាំងរបស់ខ្លួនគឺតាមរយៈការផ្តល់ជូននូវផលិតផល ក៏ដូចជាពង្រីកការយល់ដឹងអំពីសារប្រយោជន៍របស់សេវាធានារ៉ាប់រងដល់ប្រជាជនកម្ពុជាឲ្យកាន់តែមានភាពខ្លាំងក្លារ និង ដុះដាលទៅមុខ។

ក្រុមហ៊ុន បានធ្វើការពង្រីកការផ្គត់ផ្គង់សេវាកម្មរបស់ខ្លួនទៅតាមតំបន់ផ្សេងៗនៃប្រទេសកម្ពុជា ហើយក្រុមហ៊ុនបានដំណើរការ ៦ សាខានៅទីក្រុងភ្នំពេញតាមបណ្តាខេត្តនានាដែលត្រូវបានអនុញ្ញាតដោយរាជរដ្ឋាភិបាល។ នាខែមករា ឆ្នាំ២០០២ ក្រុមហ៊ុនហ្វតតេបានដាក់ដំណើរសាខាទី២នៅខេត្តសៀមរាប ដែលអាចជួយអោយក្រុមហ៊ុន បានធ្វើការផ្តល់សេវាកម្មធានារ៉ាប់រងបានល្អជាងមុនទៅកាន់អតិថិជនដែលរស់នៅតំបន់ទិសពាយព្យនៃប្រទេសកម្ពុជានៅខែមិនា ឆ្នាំ ២០០៤ ក្រុមហ៊ុនបានស្ថាបនាអគារការិយាល័យទី ២ របស់ខ្លួននៅទីក្រុងភ្នំពេញផងដែរ។ក្រុមហ៊ុនបានពង្រីកសាខារបស់ខ្លួនទៅដល់ខេត្តបាត់ដំបង នាខែមិថុនា ឆ្នាំ ២០១១និង

សាខាខេត្តកំពុងចាម នាខែឧសភា ឆ្នាំ ២០១៣ ដើម្បីផ្តល់ជាភាពងាយស្រួលនិងឆាប់រហ័សទៅដល់អតិថិជនក្នុងការប្រើប្រាស់សេវាកម្មធានារ៉ាប់រងរបស់ក្រុមហ៊ុន។ ចំណែកឯសាខាក្រុងព្រះសីហនុត្រូវបានដំណើរការនៅថ្ងៃទី៥ ឆ្នាំ ២០១៤។

## ២.២. អត្តសញ្ញាណ( ទីតាំងអាជីវកម្ម និងនិមិត្តសញ្ញា)

### ២.២.១. និមិត្តសញ្ញា

*រូបភាពទី១ រូបតំណាងរបស់ក្រុមហ៊ុនហ្វតតេ*

### ២.២.២. ទីតាំងអាជីវកម្ម

ទីស្នាក់ការកណ្តាលរបស់ក្រុមហ៊ុនហ្វតតេ មានទីតាំងស្ថិតនៅ ជាន់ទី១៨ នៃអគារវឌ្ឍនៈនៅតាមបណ្តោយមហាវិថីព្រះមុន្នីវង្ស ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ លើសពីនេះទៅទៀតក្រុមហ៊ុនហ្វតតេ មានសាខាចំនួន៤ នៅតាមបណ្តាលខេត្តមួយចំនួនមានដូចជាសាខាសៀមរាបសាខាបាត់ដំបង សាខាកំពុងចាម និងសាខាក្រុងព្រះសីហនុផងដែរ។

- ភ្នំពេញ : (១) អគារវឌ្ឍនៈ ជាន់ទី១៨ អគារ៦៦ មហាវិថីព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
- រាជធានីភ្នំពេញ(២) City Tower ជាន់ទី១ មហាវិថីម៉ៅសេទុង សង្កាត់ផ្សារដេប៉ូ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
- សាខាសៀមរាប : មណ្ឌលស្តាតចាស់ ភូមិសាលាកន្សែង សង្កាត់ស្វាយដង្គុំ ក្រុងសៀមរាប ខេត្តសៀមរាប

- សាខាបាត់ដំបង : ផ្ទះលេខ២៦ ផ្លូវជាតិលេខ៥ ភូមិរំចេក៥ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង
- សាខាកំពង់ចាម : ផ្ទះលេខ៨ ផ្លូវសុរាម្រិត ភូមិ៣ សង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម
- សាខាព្រះសីហនុ : ភូមិ៣ សង្កាត់១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

*រូបទី២ ទីតាំងការិយាល័យរបស់ក្រុមហ៊ុនហ្វតតេ*




## ២.៣. បេសកកម្ម និងចក្ខុវិស័យ

ក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ បានផ្តល់ជូនពិសេសនូវសេវាកម្មធានារ៉ាប់រងទូទៅ យ៉ាងទូលំទូលាយប្រកបដោយប្រសិទ្ធភាព និងធានាដល់ការបន្តជំរុញភាពរីកចម្រើន ព្រមទាំងជួយដល់ការអភិវឌ្ឍវិស័យធានារ៉ាប់រងនៅកម្ពុជាផងដែរ។ តាមរយៈជំនាញវិជ្ជាជីវៈដ៏ច្បាស់លាស់ក្នុងវិស័យធានារ៉ាប់រងមួយនេះធ្វើអោយយើងសាងនូវកេរ្តិ៍ឈ្មោះល្បីល្បាញប្រកបដោយភាពស្មោះត្រង់ និងសុចរិតភាព។ ដោយសារការទទួលស្គាល់នូវភាពខ្លាំង និងសេវាកម្ម ដែលយើងបានផ្តល់ជូនដល់អតិថិជនធ្វើអោយ ហ្វតតេ ក្លាយជាក្រុមហ៊ុនធានារ៉ាប់រងមួយឈានមុខគេបំផុតនៅកម្ពុជា។

### ២.៣.១. បេសកកម្ម

ក្រុមហ៊ុនធានារ៉ាប់រង ហ្វតតេមានបេសកកម្មការក៏សាងភាពជឿជាក់របស់អតិថិជននិងដៃគូសហការអន្តរជាតិហើយនិងរក្សានូវចំណង់ចំណូលចិត្តក្នុងការអភិវឌ្ឍឧស្សាហកម្មធានារ៉ាប់រងនៅក្នុងប្រទេសកម្ពុជា។

### ២.៣.២. ចក្ខុវិស័យ

- បន្តភាពជាអ្នកដឹកនាំនៅក្នុងសេវាកម្មធានារ៉ាប់រង
- សកម្មក្នុងការផ្លាស់ប្តូរនិងក្លាយជាអ្នកច្នៃប្រឌិតឈានមុខគេក្នុងការផ្តល់នូវសេវាកម្ម
- ក្លាយជាអង្គភាពដែលមានចំណេះដឹងនិងជំនាញដ៏រឹងមាំ
- ក្លាយទៅជាក្រុមហ៊ុនធានារ៉ាប់រងជម្រើសសម្រាប់ភ្នាក់ងារនិងឈ្មួញកណ្តាលនៅបរទេស
- បទពិសោធន៍សម្រាប់អតិថិជននិងផលិតផលដែលពាក់ពន្ធ័
- សុចរិតភាព, ចំណេះដឹង, ភាពជឿជាក់, ការយកចិត្តទុកដាក់

## ២.៤. រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន




*រូបទី៣ រចនាសម្ព័ន្ធរបស់ក្រុមហ៊ុនហ្វតតេ*

## ២.៥. ដៃគូរពាណិជ្ជកម្ម

វិស័យធានារ៉ាប់រងនៅក្នុងប្រទេសកម្ពុជា មានភាពរីកចម្រើនខ្លាំងនៅរយៈកាលចុងក្រោយនេះហើយក្រុមហ៊ុនធានារ៉ាប់រងដែលមានការឈានមុខគេក្នុងប្រទេសមួយនេះគឺជា ក្រុមហ៊ុនធានារ៉ាប់រងហ្វតេ។ដោយសារតែកត្តានេះហើយទើបមាន ក្រុមហ៊ុនបរទេសជាច្រើនបានមើលឃើញពីសក្តានុពលទាំងនេះ ហើយក៏បានសហការជាមួយក្រុមហ៊ុនធានារ៉ាប់រងហ្វតេជាដៃគូពាណិជ្ជកម្ម។ ក្រុមហ៊ុនបរទេសទាំងនោះរួមមាន៖

**១. AIG** គឺជាក្រុមហ៊ុនធានារ៉ាប់រងមួយដែលមកពីពាក្យកាត់ និង ឈ្មោះថា ( American International Group, Inc) ដែលក្រុមហ៊ុននេះបានបម្រើអតិថិជនច្រើនជាង ៨០ ប្រទេសនៅក្នុងពិភពលោក ហើយក្រុមហ៊ុនមួយនេះត្រូវបានស្គាល់និងទុកចិត្តពីសំណាក់អតិថិជន និង ដៃគូរពាណិជ្ជកម្មជាច្រើនអស់រយៈពេលជាង ១០០ ឆ្នាំមកហើយ។ [9]

**២. AVIVA Plc** គឺជាក្រុមហ៊ុនធានារ៉ាប់រងមួយដែលកាលពីមុនមានឈ្មោះថាCGNU Plc ដែលត្រូវបានបោះឆ្នោតដោយក្រុមម្ចាស់ភាគហ៊ុនដើម្បីប្តូរឈ្មោះក្រុមហ៊ុនទៅ AVIVA Plc នៅកំឡុងខែមេសា ឆ្នាំ២០០២។ វាបានបង្កើតឡើងដោយការរួមបញ្ចូលគ្នារវាងក្រុមហ៊ុនពីរគឺ Norwich Union & CGU Plc នៅកំឡុងឆ្នាំ១៩៩៨។ហើយបច្ចុប្បន្ននេះ AVIVA មានការិយាល័យកណ្តាលនៅលើផ្លូវ ហេលិន នៅក្នុងទីក្រុងឡុង ចក្រភពអង់គ្លេស។ដែលមានប្រាក់ចំណូលសរុបនៅក្នុងឆ្នាំ២០១៩ប្រមាណ ២៦៣លានផោន។[10]

**៣. AXA** ត្រូវបានចាប់កំណើតនៅក្នុងប្រទេសបារាំងអស់រយៈពេល២០៤ឆ្នាំមកហើយពោលគឺចាប់ផ្តើមពីឆ្នាំ ១៨១៦ ដោយអ្នកជំនួញសញ្ជាតិបារាំងឈ្មោះថា Claude Bébéar ។ វាមានការិយាល័យកណ្តាលឋិតនៅទីក្រុង ប៉ារីស ប្រទេសបារាំង។ ក្រុមហ៊ុននេះមានទ្រព្យសកម្មប្រមាណ៩៣០.៧ពាន់លានអឺរ៉ូក្នុងឆ្នាំ២០១៨ និងមានប្រាក់ចំណូលសរុប៣.៨៣ពាន់លានអឺរ៉ូនៅឆ្នាំ២០១៩។ បើគិតត្រឹមខែធ្នូឆ្នាំ២០១៨ក្រុមហ៊ុននេះមានបុគ្គលិកចំនួន១២៥,៩៣៤នាក់។[11]

---

[9] American International Group INC Website , https://www.aig.com/about-us ប្រើប្រាស់នៅថ្ងៃទី១០ខែមេសាឆ្នាំ២០២០

[10] "AVIVA Plc" ,https://en.wikipedia.org/wiki/Aviva ,យកមកប្រើប្រាស់នៅថ្ងៃទី១០ខែមេសាឆ្នាំ២០២០

[11] "AXA" , https://en.wikipedia.org/wiki/Axa , យកមកប្រើប្រាស់នៅថ្ងៃទី១០ខែមេសាឆ្នាំ២០២០

៤. **BAOVIET TOKIO MARINE** គឺជាក្រុមហ៊ុនធានារ៉ាប់រងដំបូងគេបង្អស់នៅក្នុងប្រទេសវៀតណាម ដែលមានការវិនិយោគពីក្រៅប្រទេស។ក្រុមហ៊ុននេះបាន ចាប់ផ្តើមដោយមានម្ចាស់ភាគហ៊ុន ៣ គឺ BaoViet ៥១%, Commercial Union ២៤.៥%និង Tokio Marine ២៤.៥%។ វាមានទីស្នាក់ការកណ្តាលនៅទីក្រុងហាណូយប្រទេសវៀតណាម។[12]

៥. **CHINA TAIPING** ក្រុមហ៊ុនធានារ៉ាប់រងក្នុងប្រទេសចិនមួយនេះមានទ្រព្យសកម្មរហូតទៅ ៧៥២,១០១ លានដុល្លារហុងកុង។ ហើយនៅក្នុងឆ្នាំ ២០១៨ CHINA TAIPING មានប្រាក់ចំណូល៦,៨៨៤លានដុល្លារហុងកុង ដែល ៩៣% នៃប្រាក់ចំណូលរបស់ពួកគេគឺបានមកពីចិនដីគោក។ ក្រុមហ៊ុននេះបានបង្កើតឡើងដំបូងនៅកំឡុងឆ្នាំ១៩២៩ហើយបច្ចុប្បន្នមានការិយាល័យកណ្តាលនៅទីក្រុងហុងកុង។[13]

៦.**QBE Insurance Group Limited** គឺជាក្រុមហ៊ុនធានារ៉ាប់រងដែលធំជាងគេបង្អស់ចំណាត់ថ្នាក់ទី២នៅក្នុងប្រទេសអូស្ត្រាលី ដែលមានទ្រព្យសកម្មសរុបរហូតទៅដល់៣៩,៥៨២ លានដុល្លា។ **QBE** មានអាយុកាលអស់រយៈពេល ១៣៤ឆ្នាំហើយដោយវាត្រូវបានបង្កើតឡើងនៅក្នុងខែមករា ឆ្នាំ១៩៨៦។វាមានការិយាល័យកណ្តាលនៅទីក្រុងស៊ីដនីប្រទេសអូស្ត្រាលី។[14]

៧. **RSA Insurance Group Plc** ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៦ នៅទីក្រុងឡុងចក្រភពអង់គ្លេសដោយមានការរួមបញ្ចូលគ្នារវាង Sun Alliance និង Royal Insurance។ RSA បានផ្តល់សេវាកម្មទៅឲ្យអតិថិជនជាង១៤០ប្រទេសប្រមាណ ៩លាននាក់។ RSAមានប្រាក់ចំណេញសុទ្ធប្រមាណ ៣៨៣ លានផោនក្នុងឆ្នាំ ២០១៨។[15]

---

[12] https://www.baoviettokiomarine.com/site/index/pages/name/history/lid/english , “ Baoviet Tokio Marine Company History” , យកមកប្រើប្រាស់នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០

[13] “China Taiping Insurance Holdings” https://en.wikipedia.org/wiki/China_Taiping_Insurance_Holdings,យកមកប្រើប្រាស់នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០

[14] “QBE Insurance” https://en.wikipedia.org/wiki/QBE_Insurance , យកមកប្រើប្រាស់នៅថ្ងៃទី១០ខែមេសា២០២០

[15]“RSA Insurance Group”, https://en.wikipedia.org/wiki/RSA_Insurance_Group ,យកមកប្រើប្រាស់នៅថ្ងៃទី១០ខែមេសាឆ្នាំ ២០២០

៨. **Swiss Reinsurance Company Ltd** ដែលត្រូវបានគេស្គាល់ជាទូទៅថា Swiss Re ដែលជាក្រុមហ៊ុនដែលត្រូវបានបង្កើតដោយសាប្រទេសស្វីសធ្លាប់បានជួបនូវគ្រោះអគ្គីភ័យមួយនៅ ទីក្រុង Glarus ដែលធ្វើអោយផ្ទះច្រើនជាង ៥០០ខ្នង ត្រូវបានបំផ្លាញដោយអណ្តាតភ្លើង នៅ ថ្ងៃទី១០ ១១ ខែឧសភា ឆ្នាំ ១៨៦១។ហើយក្រុមហ៊ុននេះក៏បានបង្កើតឡើងនៅ ខែធ្នូ ឆ្នាំ១៨៦៣។ហើយបច្ចុប្បន្ន Swiss Re មានទ្រព្យសកម្មចំនួន២០៧.៥៧ពាន់លានដុល្លាអាមេរិក។[16]

៩. **Zurich Insurance Group Ltd** គឺជាក្រុមហ៊ុនធានារ៉ាប់រងដែលធំជាងគេបង្អស់ នៅក្នុងប្រទេសស្វីស ដែលមានទ្រព្យសកម្មរហូតដល់ទៅ៣៩៦.៣៤ ពាន់លានដុល្លារអាមេរិក។ Zurich ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៨៧២។ ហើយបច្ចុប្បន្ននេះ Zurich បានបម្រើសេវាកម្មជាង១៧០ប្រទេសនៅលើពិភពលោក។[17]

១០. **MSH China** ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ២០០១ ដោយមានការិយាល័យកណ្តាលនៅទីក្រុងសៀងហៃ។ បេសកកម្មរបស់ MSH គឺបង្កើនភាពងាយស្រួល និង ដំណោះស្រាយផ្នែកការថែរក្សាសុខភាពអោយកាន់តែមានគុណភាពខ្ពស់ និង ល្អប្រសើរឡើង។[18]

១១. **PING AN Insurance Group**ត្រូវបានបង្កើតឡើងដោយស្ថាបនិកឈ្មោះថា MA MINGZHEនៅក្នុងឆ្នាំ ១៩៨៨។ហើយនៅពេលបច្ចុប្បន្នក្រុមហ៊ុននេះមានទ្រព្យសកម្ម ប្រមាណ៨២២២ពាន់លានយ៉ាន់ និងចំណូល ប្រមាណ ១៤៩.៤ពាន់លានយ៉ាន់។[19]

[16] "Swiss Re", https://en.wikipedia.org/wiki/Swiss_Re , យកមកប្រើប្រាស់នៅថ្ងៃទី១០ខែមេសាឆ្នាំ២០២០

[17] "Zurich Insurance Group" , https://en.wikipedia.org/wiki/Zurich_Insurance_Group ,យកមកប្រើប្រាស់នៅថ្ងៃទី១០ខែមេសាឆ្នាំ២០២០

[18] "About MSH China" https://www.mshasia.com/AboutUs.aspx?key=10002&keyParent=L01 ,យកមកប្រើប្រាស់នៅថ្ងៃទី១០ខែមេសាឆ្នាំ២០២០

[19] "Ping An Insurance" https://en.wikipedia.org/wiki/Ping_An_Insurance , យកមកប្រើប្រាស់នៅថ្ងៃទី១០ខែមេសាឆ្នាំ២០២០

## ២.៦. ទំនួលខុសត្រូវក្នុងសង្គម

អត្ថន័យដ៏ធំធេង នៃទំនួលខុសត្រូវកិច្ចការសង្គមតែងជំរុញអោយក្រុមហ៊ុនហ្វតតេផ្តល់នូវកិច្ចតបស្នង ដល់សង្គមដែលយើងរស់នៅ។ នៅក្នុងតួនាទីជាច្រើនមានដូចជាក្នុងនាមជាវិនិយោគិនក្រុមហ៊ុនធានារ៉ាប់រង និយោជក និង អតិថិជនក្រុមហ៊ុនហ្វតតេជឿថាការរួមចំណែកដល់ការអភិវឌ្ឍន៍ភាពជោគជ័យរបស់សហគមន៍ទាំងនេះគឺជា មូលដ្ឋានគ្រឹះនៃភាពជោគជ័យរបស់ក្រុមហ៊ុនហ្វតតេក្នុងកិច្ចសហការដៃគូជាមួយ សហគមន៍ដែលធ្វើប្រតិបត្តិការ។

ក្រុមហ៊ុនហ្វតតេ បានជឿថាការរួមចំណែកដល់ការអភិវឌ្ឍន៍នឹងបន្តផ្តល់ការលើកទឹកចិត្តនិងផ្តល់ជាធនធាន ដើម្បីជាចំណែកមួយក្នុងការជួយអភិវឌ្ឍន៍ទំនួលខុសត្រូវសង្គម ។ ចាប់តាំងពីការចាប់ផ្តើមរបស់ខ្លួនក្នុងឆ្នាំ ១៩៩៩ ក្រុមហ៊ុន ហ្វតតេ បានបង្កើតកម្មវិធីជួយសង្គម ជាច្រើន ដូចជា ៖ សហការជាមួយអង្គការក្រៅរដ្ឋាភិបាលរបស់ជប៉ុន The Organization for Industrial Spiritual and Cultural Advancement International ដើម្បីឧបត្ថម្ភគម្រោងបៃតងនានា និង ការអភិវឌ្ឍន៍ធនធានមនុស្សនៅក្នុងវិស័យកសិកម្ម បញ្ជូនជនជាតិខ្មែរពីររូបទៅប្រទេសជប៉ុនជារៀងរាល់ឆ្នាំ ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលផ្នែកកសិកម្ម រៀបចំកម្មវិធីព្រៃឈើកុមារ ដែលជាយុទ្ធនាការដាំដើមឈើដើម្បីអប់រំកុមារឲ្យយល់ដឹង ពីសារប្រយោជន៍នៃបរិស្ថានមួយប្រកបដោយនិរន្តរភាព និង បានដាំកូនឈើប្រមាណ១២,០០០ដើមត្រឹមឆ្នាំ២០១៨។ ការផ្តួចផ្តើមយុទ្ធនាការផ្លូវសុវត្ថិភាព ដែលសហការជាមួយ អង្គការក្រៅរដ្ឋាភិបាល Junior Chamber International ដើម្បីឧបត្ថម្ភមួកសុវត្ថិភាពចំនួន ៣០០០ មួកទៅឲ្យសិស្សានុសិស្ស និងអ្នកជិះម៉ូតូ។[20]

## ២.៨. ភាពថ្លៃថ្នូរ

តាមរយៈជំនាញវិជ្ជាជីវៈដ៏ច្បាស់លាស់របស់ក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ ក្នុងវិស័យធានារ៉ាប់រងនេះធ្វើអោយក្រុមហ៊ុនហ្វតតេ ក៏សាងនូវកេរ្តិ៍ឈ្មោះល្បីល្បាញប្រកបដោយភាពស្មោះត្រង់និងសុចរិតភាពដោយសារការទទួលស្គាល់នូវភាពខ្លាំង និង សេវាកម្មដែលបានផ្តល់ជូនដល់អតិថិជនធ្វើអោយហ្វតតេក្លាយជាក្រុមហ៊ុនធានារ៉ាប់រងឈានមុខគេបំផុតនៅកម្ពុជា។

## ២.៩. ធនធានមនុស្សនៅក្នុងសហគ្រាស

សេវាកម្មដ៏ពិសេសរាប់តាំងពី បុគ្គលិកថ្នាក់លើរហូតទៅដល់ថ្នាក់ក្រោមចាប់ផ្តើមកកើតដំបូងចេញពីក្រុមជំនាញដែលមានសមាជិកត្រឹម ២០ រូប បច្ចុប្បន្នក្រុមហ៊ុនហ្វតតេ មានការចូលរួមពីសមាគមន៍វិស័យផ្សេង

---

[20] យោងតាម Forte Insurance Corporate Profile ឆ្នាំ២០១៩

និងជាបណ្ដុំនៃអ្នកមានទេពកោសល្យផ្សេងៗពីគ្នា។យើងចូលរួមកម្មវិធីជាច្រើនដើម្បីអភិវឌ្ឍក្រុមហ៊ុននិងបង្កើនសមត្ថភាពអ្នកជំនាញរបស់យើងជាបន្តបន្ទាប់ ។ ជាពិសេស ហ្វតតេគឺជាក្រុមហ៊ុនធានារ៉ាប់រងមួយនៅកម្ពុជាដែលផ្ដល់ជូនដល់បុគ្គលិកនូវវគ្គបណ្ដុះបណ្ដាលដូចជា The Malaysian Insurance Institute និង Chartered Insurance Institute ដែលស្របតាមស្តង់ដារធានារ៉ាប់រងដែលមានការទទួលស្គាល់ទូទាំងសាកលលោក។

ក្រុមហ៊ុនជឿជាក់យ៉ាងមុតមាំថាបរិស្ថានការងារដែលមានភាពចម្រុះ និងវប្បធម៌ផ្សេងៗពីគ្នា នឹងជម្រុញឲ្យបុគ្គលិកទាំងអស់ធ្វើការបានពោរពេញដោយសក្តានុពល។ ទស្សនៈវិស័យ និងបទពិសោធន៍ដ៏ប្លែកៗពីគ្នារបស់ពួកគេ រួមចំណែកដ៏សំខាន់ក្នុងការបន្តនូវភាពជោគជ័យប្រកបដោយចីរភាព។ ជារួមបុគ្គលិកទាំងអស់ ជាបុគ្គលដែលទុកចិត្ត ស្មោះត្រង់ និងធ្វើការប្រកបដោយប្រសិទ្ធិភាព។ ចំណេះដឹង និងបទពិសោធន៍របស់បុគ្គលិក ជាកត្តាធ្វើអោយក្រុមហ៊ុនមានការរីកចម្រើនជាបន្តបន្ទាប់ក៏ដូចជាអាចផ្ដល់ជូនអតិថិជននូវផលិតផលនិងសេវាកម្មប្រកបទៅដោយគុណភាពខ្ពស់។

## ២.១០. ផលិតផលរបស់ក្រុមហ៊ុន

### ២.១០.១. ផលិតផលធានារ៉ាប់រងមេឌីគ្រីធីខល សាកល

ប័ណ្ណសន្យារ៉ាប់រងមេឌីគ្រីធីខលសាកល អនុញ្ញាតអោយទទួលបានការព្យាបាលផ្នែកវេជ្ជសាស្ត្រល្អបំផុត។ ហើយលើសពីនេះ លោកអ្នកអាចទទួលបានការព្យាបាលពីវេជ្ជបណ្ឌិតជំនាញឯកទេស និងមន្ទីរពេទ្យដ៏ល្អបំផុតគ្រប់ទីកន្លែងទូទាំងពិភពលោក។ ប័ណ្ណសន្យារ៉ាប់រងនេះ ផ្ដល់ការធានារ៉ាប់រងលើការព្យាបាលផ្នែកវេជ្ជសាស្ត្រ និងការចំណាយទាំងស្រុងដែលជាប់ពាក់ព័ន្ធ ដូច្នេះអ្វីដែលលោកអ្នកគួរតែយកចិត្តទុកដាក់ គឺថែទាំសុខភាពឲ្យបានប្រសើរ។

ប័ណ្ណសន្យារ៉ាប់រងមេឌីគ្រីធីខលសាកល ផ្ដល់ការធានារ៉ាប់រងសម្រាប់លោកអ្នកនិងសមាជិកគ្រួសារប្រសិន បើមានការព្យាបាលនៅក្រៅប្រទេសដូចខាងក្រោម៖

- ការព្យាបាលជំងឺមហារីក
- ការវះកាត់សរសៃឈាមក្បូរ៉ូណារី
- ការផ្លាស់ប្តូរបេះដូង
- កែសម្រួលប្រឹសបេះដូង
- ការវះកាត់លលាដ៏ក្បាល និងខួរឆ្អឹង
- ការផ្លាស់ប្តូរ និង ផ្សាំសរីរាង្គ
- ផ្សាំខួរឆ្អឹង ពីអ្នកបរិច្ចាគដែលមានជីវិត ។

បណ្ណសន្យារ៉ាប់រង មេឌីគ្រីធីខល សាកល អនុញ្ញាតឲ្យលោកអ្នកទទួលបានការព្យាបាលជាមួយអ្នកជំនាញ និងទទួលបានការព្យាបាលផ្នែកវេជ្ជសាស្ត្រល្អបំផុតនៅក្រៅប្រទេសកម្ពុជាដូចក្នុងតារាងខាងក្រោម៖[21]

| វិសាលភាពនៃការធានា | បណ្ណសន្យារ៉ាប់រង មេឌីគ្រីធីខល សាកល |
|---|---|
| ការចំណាយសរុប | រហូតដល់ ១លានដុល្លារអាមេរិក ក្នុង១នាក់ និងក្នុង១ឆ្នាំ<br>រហូតដល់ ២លានដុល្លារអាមេរិក ក្នុង១នាក់ និងក្នុង១ជីវិត |
| ការចំណាយលើការធ្វើដំណើរ | ការធានាពេញសម្រាប់លោកអ្នក និងអ្នកកំដរម្នាក់ |
| ការចំណាយលើការស្នាក់នៅ | ការធានាពេញសម្រាប់លោកអ្នក និងអ្នកកំដរម្នាក់ |
| ការចំណាយលើការធ្វើមាតុភូមិនិវត្តន៍ | ការធានាពេញសម្រាប់លោកអ្នក ក្នុងករណីទទួលមរណភាពនៅក្រៅប្រទេស |
| អត្ថប្រយោជន៍ប្រចាំថ្ងៃ | ១០០ ដុល្លារអាមេរិក ក្នុង១ថ្ងៃ សម្រាប់ការសម្រាកព្យាបាលនៅក្រៅប្រទេស រហូតដល់អតិបរមា ៦០ថ្ងៃ |
| អត្ថប្រយោជន៍សម្រាប់ការប្រើប្រាស់ឱសថ | ៥០,០០០ ដុល្លារអាមេរិក ក្នុង១នាក់ និងក្នុង១ជីវិត សម្រាប់ឱសថដែលទិញនៅក្នុងប្រទេសកម្ពុជា បន្ទាប់ពីត្រលប់មកពីព្យាបាលនៅក្រៅប្រទេស |

*តារាងទី១ អត្ថប្រយោជន៍របស់ផលិតផលធានារ៉ាប់រងមេឌីគ្រីធីខល សាកល*

ប្រភព ៖ គេហទំព័ររបស់ក្រុមហ៊ុនធានារ៉ាប់រងហ្វតេ, https://www.forteinsurance.com/km/individual-insurance/list/medicritical-worldwide/

[21] យោងតាម គេហទំព័រក្រុមហ៊ុនហ្វតេ,ផលិតផលមីឌីគ្រីធីខលសាកល , https://www.forteinsurance.com/km/individual-insurance/list/medicritical-worldwide/ យកមកប្រើប្រាស់នៅថ្ងៃ២០មេសា២០២០

### ២.១០.២. ផលិតផលធានារ៉ាប់រង សុខភាពអន្តរជាតិ

ផលិតផលធានារ៉ាប់រង FIGTREE BLUE ជាជម្រើសដ៏សមរម្យមួយដែលផ្តល់ការធានាជាអន្តរជាតិ គម្រោងនេះផ្តល់ជូននូវការធានារ៉ាប់រងដ៏ទូលំទូលាយពេញ ២៤ម៉ោងក្នុងមួយថ្ងៃ និង ៣៦៥ថ្ងៃក្នុងមួយឆ្នាំ ទោះបីលោកអ្នកនៅកន្លែងធ្វើការ នៅផ្ទះ ឬ វិស្សមកាលនៅជុំវិញពិភពលោក ។ ផលិតផលធានារ៉ាប់រងសុខភាពអន្តរជាតិ FIGTREE BLUE ត្រូវបានបង្កើតឡើងជាពិសេសសម្រាប់ជនបរទេសដែលបានរស់នៅប្រទេសកម្ពុជា និងសម្រាប់ប្រជាជនកម្ពុជាគ្រប់រូប។ ផលិតផលនេះផ្តោតយកចិត្តទុកដាក់លើការព្យាបាល និងអត្ថប្រយោជន៍បន្ថែមជាច្រើនទៀត សម្រាប់គ្រួសារ ក៏ដូចជាបុគ្គលិករបស់ស្ថាប័ន ក្រុមហ៊ុននានា។

អត្ថប្រយោជន៍សំខាន់ៗរបស់ផលិតផលធានារ៉ាប់រង សុខភាពអន្តរជាតិ FIGTREE BLUE

- ការអនុម័តឆាប់រហ័ស
- ផ្តល់សំណងយ៉ាងមានប្រសិទ្ធភាព
- តម្លៃសមរម្យ
- ផ្តល់ការធានាទូទាំងពិភពលោក
- សេវាបញ្ជូនសង្គ្រោះបន្ទាន់ និង
- សេវាការព្យាបាលជំងឺ[22]

### ២.១០.៣ ផលិតផលធានារ៉ាប់រងគាំពារមហារីក CANCKOAMPEA

CANCKOAMPEA មានគោលបំណងកាត់បន្ថយបន្ទុកចំណាយ និងទុក្ខលំបាករបស់អតិថិជន និងក្រុមគ្រួសារនៅពេលដែលត្រូវបានរកឃើញនូវជំងឺមហារីកធ្ងន់ធ្ងរ។ក្នុងករណីអកុសលដែលរោគវិនិច្ឆ័យបញ្ជាក់ថាមានជំងឺមហារីកធ្ងន់ធ្ងរ នោះអ្នកត្រូវបានធានានឹងទទួលបាន១០០% នៃចំនួនទឹកប្រាក់ដែលត្រូវបានធានា ហើយអាចប្រើប្រាស់ថវិការនោះតាមតំរូវការ។ អតិថិជនអាចទិញប័ណ្ណសន្យារ៉ាប់រងនេះសម្រាប់ខ្លួនឯង ក៏ដូចជាក្រុមគ្រួសារ និង/ឬ សាច់ញាតិសមាជិកក្នុងបន្ទុកគ្រួសារ (បងប្អូនបង្កើត ឪពុកម្តាយចិញ្ចឹម កូនចិញ្ចឹម អាណាព្យាបាលស្របច្បាប់) ។[23]

---

[22] យោងតាម គេហទំព័រក្រុមហ៊ុនហ្វតតេ,ផលិតផលធានារ៉ាប់រងសុខភាពអន្តរជាតិ , https://www.forteinsurance.com/km/individual-insurance/list/figtree-blue-insurance/ ទស្សនានៅថ្ងៃ២០មេសា២០២០

[23] យោងតាម គេហទំព័រក្រុមហ៊ុនហ្វតតេ,ផលិតផលធានារ៉ាប់រងគាំពារមហារីក, https://www.forteinsurance.com/km/individual-insurance/list/cancer-insurance/ , ទស្សនានៅថ្ងៃ២០មេសា២០២០

ក្រុមហ៊ុនផ្តល់ជូន នូវជម្រើស ចំនួន ៣ គម្រោងគឺ Classic, Executive & Premier ៖

| ទំហំនៃការធានារ(ដុល្លាអាមេរិក) | Classic(USD) | Executive(USD) | Premier(USD) |
|---|---|---|---|
| ប្រាក់សម្រាប់រៀបចំបុណ្យសព អាចទូទាត់ជាកញ្ចប់ករណីអ្នកត្រូវបានធានាបាត់បង់ជីវិត | $1,000 | $2,000 | $3,000 |
| ជំងឺមហារីក-ទឹកប្រាក់ត្រូវបានធានា | $10,000 | $20,000 | $30,000 |
| ជំងឺមហារីកដែលធ្វើរោគវិនិច្ឆ័យ 90 ថ្ងៃ ក្រោយកាលបរិច្ឆេទនៃការចាប់ផ្តើមប័ណ្ណសន្យារ៉ាប់រងឬក្រោយកាលបរិច្ឆេទបំពេញឡើងវិញ។ | 70% នៃទឹកប្រាក់ដែលបានធានា | 70% នៃទឹកប្រាក់ដែលបានធានា | 70% នៃទឹកប្រាក់ដែលបានធានា |
| ជំងឺមហារីកដែលធ្វើរោគវិនិច្ឆ័យ 180ថ្ងៃ ក្រោយកាលបរិច្ឆេទនៃការចាប់ផ្តើមប័ណ្ណសន្យារ៉ាប់រង ឬ ក្រោយកាលបរិច្ឆេទបំពេញឡើងវិញ។ | 100% នៃទឹកប្រាក់ដែលបានធានា | 100% នៃទឹកប្រាក់ដែលបានធានា | 100% នៃទឹកប្រាក់ដែលបានធានា |
| អំឡុងពេលរស់រានមានជីវិត (អ្នកត្រូវបានធានាត្រូវមានជីវិតរស់រានយ៉ាងតិច14ថ្ងៃ បន្ទាប់ពីថ្ងៃដឹងរោគវិនិច្ឆ័យ) | 14ថ្ងៃ | 14ថ្ងៃ | 14ថ្ងៃ |

*តារាងទី២ អត្ថប្រយោជន៍របស់ផលិតផលធានារ៉ាប់រងគាំពារមហារីក*

ប្រភព៖គេហទំព័ររបស់ក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ,https://www.forteinsurance.com/km/individual-insurance/list/cancer-insurance/

បុព្វលាភប្រចាំឆ្នាំរបស់លោកអ្នកអាចនឹងប្រែប្រួលអាស្រ័យលើទឹកប្រាក់ដែលត្រូវបានធានា ក៏ដូចជាអាស្រ័យលើភេទ និងអាយុដូចតារាងខាងក្រោម៖

| អាយុគិតត្រឹម ថ្ងៃខួបកំណើត ចុងក្រោយ | Classic(USD) | | Executive(USD) | | Premier(USD) | |
|---|---|---|---|---|---|---|
| | ប | ស | ប | ស | ប | ស |
| 1 ខែ - 17 | 12 | 12 | 21 | 23 | 29 | 33 |
| 18 - 24 | 12 | 12 | 21 | 23 | 29 | 33 |
| 25-29 | 17 | 20 | 32 | 36 | 45 | 53 |
| 30 - 34 | 27 | 29 | 51 | 55 | 75 | 80 |
| 35 - 39 | 45 | 43 | 86 | 82 | 128 | 121 |
| 40 - 44 | 72 | 59 | 139 | 116 | 208 | 171 |
| 45 - 49 | 109 | 81 | 214 | 158 | 319 | 236 |
| 50 - 54 | 148 | 102 | 291 | 200 | 436 | 299 |
| 55 - 59 | 178 | 114 | 352 | 224 | 526 | 335 |
| 60 - 64 | 202 | 118 | 399 | 233 | 597 | 347 |
| 65 - 69 | 245 | 137 | 486 | 269 | 727 | 402 |
| 70 - 74 | 257 | 140 | 511 | 277 | 764 | 414 |

*តារាងទី៣ តារាងនៃការគណនាបុព្វលាភផលិតផលធានារ៉ាប់រងគាំពារមហារីក*

ប្រភព៖គេហទំព័ររបស់ក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ,https://www.forteinsurance.com/km/individual-insurance/list/cancer-insurance/

### ២.១០.៤. ផលិតផលធានារ៉ាប់រងគ្រោះថ្នាក់បុគ្គល

ការធានារ៉ាប់រងពេញ២៤ម៉ោង ត្រូវបានផ្តល់អោយសម្រាប់ធានាលើឧប្បត្តិហេតុគ្រោះថ្នាក់អំឡុងពេលបំពេញការងារ ឬការលម្ហែកម្សាន្ត។ គម្រោងនេះរួមមានគ្រោះថ្នាក់ផ្សេងៗ (លើកលែងតែករណីមិនធានា) មិនថាអំឡុងពេលបម្រើការងារ ឬក្រៅម៉ោងការងារ កើតឡើងនៅគេហដ្ឋាន ឬអំឡុងពេលធ្វើដំណើរកម្សាន្ត។ គ្មានការកំណត់ចំពោះទីតាំងភូមិសាស្ត្រឡើយនេះជាផលិតផលធានារ៉ាប់រងដែលផ្តល់ការធានាលើគ្រោះថ្នាក់ដែលកើតឡើងនៅទូទាំងពិភពលោក។

អត្ថប្រយោជន៍របស់ផលិតផលធានារ៉ាប់រងគ្រោះថ្នាក់បុគ្គល

- តម្លៃសមរម្យ
- មានភាពបត់បែន
- សេវាកម្មទាមទារសំណងប្រកបដោយប្រសិទ្ធភាព
- ការធានាទូលំទូលាយ
- ភាពងាយស្រួលសម្រាប់ការងាររដ្ឋបាលរបស់ក្រុមហ៊ុន
- ករណីបាត់ខ្លួន និងរកឃើញវិញ[24]

### ២.១០.៥. ផលិតផលធានារ៉ាប់រងលើអ្នកដំណើរ

សេវាធានារ៉ាប់រងលើអ្នកដំណើររបស់ហ្វតតេ នឹងផ្តល់ការទូទាត់សំណងអំឡុងពេលធ្វើដំណើរទៅលើបញ្ហាដូចជា ការបាត់បង់ឥវ៉ាន់និងរបស់របរផ្ទាល់ខ្លួន ការចំណាយលើការសម្រាកព្យាបាលនៅបរទេសនិង/ឬការចំណាយបន្ថែម។ ទំនួលខុសត្រូវផ្ទាល់ខ្លួនការប្លន់យន្តហោះគ្រោះថ្នាក់បណ្តាលឲ្យបាត់បង់ជីវិតនិងពិការភាពជាអចិន្ត្រៃយ៍ ។

- សំណងសម្រាប់ការបាត់បង់ប្រាក់កក់ដែលមិនអាចដកវិញបាន នៅពេលការធ្វើដំណើរត្រូវបានលុបចោល
- ជំនួយវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់ ២៤ ម៉ោងនិងសេវាកម្មដែលផ្តល់ដោយអន្តរជាតិ ។[25]

---

[24] យោងតាម គេហទំព័រក្រុមហ៊ុនហ្វតតេ,ផលិតផលធានារ៉ាប់រងគ្រោះថ្នាក់បុគ្គល , https://www.forteinsurance.com/km/individual-insurance/list/personal-accident-insurance/ យកមកប្រើប្រាស់នៅថ្ងៃ២០មេសា២០២០

[25] យោងតាម គេហទំព័រក្រុមហ៊ុនហ្វតតេ,ផលិតផលធានារ៉ាប់លើអ្នកដំណើរ, https://www.forteinsurance.com/km/individual-insurance/list/traveller-s-insurance/ , យកមកប្រើប្រាស់នៅថ្ងៃ២០មេសា២០២០

អត្ថប្រយោជន៍របស់ផលិតផលធានារ៉ាប់រងលើអ្នកដំណើរត្រូវបានបែងចែកជា២ Super Plan និង Standard Plan៖

| ផ្នែក | អត្ថប្រយោជន៍ និងការកំណត់ | Super Plan (US $) | Standard Plan (US $) |
|---|---|---|---|
| 1 | ចំណាយលើការសម្រាកព្យាបាល និង ចំណាយបន្ថែមផ្សេងៗនៅបរទេស | 100,000 | 50,000 |
| 2 | សេវា និងជំនួយវេជ្ជសាស្ត្រ សម្រាប់ការសង្គ្រោះបន្ទាន់ 24 ម៉ោង | អត្ថប្រយោជន៍ផ្តល់ជូនដូចគ្នាសំរាប់បុគ្គលធានាម្នាក់ៗ ។ ព័ត៌មានលម្អិតត្រូវបានចែងក្នុងប័ណ្ណធានារ៉ាប់រង | |
| 3 | ការបាត់បង់ជីវិត និងពិការភាពអចិន្ត្រៃយ៍ ដោយសារគ្រោះថ្នាក់ | 60,000 | 30,000 |
| 4 | ឥវ៉ាន់និងរបស់របរផ្ទាល់ខ្លួន | 3,000 | 1,500 |
| 5 | ការបាត់ប្រាក់កាស | 600 | 300 |
| 6 | ទំនួលខុសត្រូវផ្ទាល់ខ្លួន | 500,000 | 250,000 |
| 7 | ការបង់ខាតលើប្រាក់កក់ និងលើការលុបចោលការធ្វើដំណើរ | 6,000 | 3,000 |
| 8 | ការប្តូរយន្តហោះ | 3,000 | 1,500 |

*តារាងទី៤ តារាងអត្ថប្រយោជន៍របស់ផលិតផលធានារ៉ាប់រងលើអ្នកដំណើរ*

ប្រភព ៖ គេហទំព័ររបស់ក្រុមហ៊ុនធានារ៉ាប់រងហ្វតេ, https://www.forteinsurance.com/km/individual-insurance/list/traveller-s-insurance/

### ២.១០.៦. ផលិតផលធានារ៉ាប់រងលើយានយន្ត

ប័ណ្ណសន្យារ៉ាប់រងលើយានយន្តរបស់ក្រុមហ៊ុនហ្វតេ ជួយការពារ និងធានាសុវត្ថិភាពដល់មនុស្សជាទីស្រឡាញ់ និងការវិនិយោគរបស់អតិថិជនចំពោះករណីយានយន្តជួបគ្រោះថ្នាក់ចរាចរណ៍ចោរលួច អគ្គីភ័យឆាបឆេះជាដើម។ មិនថាការធ្វើដំណើរដើម្បីបំពេញការងាររអាជីវកម្ម ឬកម្សាន្ត ឬចតយានយន្តក្តីអតិថិជននឹងអស់ក្តីបារម្ភ និងអាចកាត់បន្ថយហានិភ័យលើចំណាយថ្លៃជួសជុល ឬសំណងផ្សេងៗប្រសិនបើយានយន្តដែលជួបគ្រោះថ្នាក់ចរាចរណ៍ ហើយអតិថិជននឹងត្រូវបានធានានិងទទួលបានសំណងផងដែរក្នុងករណីយានយន្តត្រូវបានចោរលួច ឬទទួលរងការខូចខាតដោយអគ្គិភ័យជាដើម។

ផលិតផលធានារ៉ាប់រងមួយនេះ ផ្តល់នូវការធានាកាន់តែទូលំទូលាយ និងជម្រើសតម្លៃសម្រាប់ជ្រើសរើសធានារ៉ាប់រងមួយដែលសក្តិសមបំផុតសម្រាប់អតិថជន។យើងមានទាំងកញ្ចប់ការ″ ធានាជាមូលដ្ឋាន ″ តម្លៃសមរម្យសម្រាប់ការធានាកម្រិតស្តង់ដារ រហូតដល់កញ្ចប់សេវា ″ ធានាគ្រប់ហានិភ័យ ″ ដែលក្រុមហ៊ុនអាចរៀបចំជូននូវកញ្ចប់ គម្រោងសេវាមួយដែលមានភាពបត់បែន មានន័យថាអតិថិជនអាចបង់ប្រាក់សម្រាប់ប្រភេទនៃការធានា ដែលពួកគេត្រូវការ ៖

– កញ្ចប់ធានារ៉ាប់រងកម្រិតមូលដ្ឋាន

ការធានាទទួលខុសត្រូវចំពោះតតិយជន ជួយការពារអតិថិជន ក្នុងករណីបង្កគ្រោះថ្នាក់បណ្តាលអោយរបួសរាងកាយអ្នកដទៃ ឬ ខូចខាតរថយន្តអ្នកដទៃ ឬ ទ្រព្យសម្បត្តិផ្សេងៗទៀតអំឡុងពេលកំពុងបើកបរ ។ អតិថិជនក៏អាចមានសិទ្ធិទទួលបានថវិការហូតដល់ ១៥០០ដុល្លារ សម្រាប់ដោះស្រាយសំណងផ្លូវច្បាប់ទៀតផង។

– កញ្ចប់ធានារ៉ាប់រងគ្រប់ហានិភ័យ

កញ្ចប់ធានារ៉ាប់រងគ្រប់ហានិភ័យ មានលក្ខណៈបត់បែនតាមតម្រូវការដើម្បីផ្តល់ការធានាកម្រិតអតិបរមា ប្រសិនបើករណីយានយន្តរបស់អតិថិជនត្រូវចោរលួច ឬ ខូចខាតដោយចៃដន្យជាដើម ក៏ដូចជាការពារអតិថិជនពីការទាមទារសំណងដោយភាគីដទៃផងដែរ។ ក្នុងលក្ខណៈដ៏ទូលំទូលាយនៃសេវារ៉ាប់រងគ្រប់ហានិភ័យ អាចធានាលើការទទួនខុសត្រូវចំពោះអ្នករួមដំណើរ ករណីចោរលួច អគ្គិភ័យឆាបឆេះ បាតុកម្ម កុបកម្ម ចលាចលសង្គម និងខូចខាតដោយសារទឹកជំនន់ផងដែរ។សេវាកម្មនៅក្នុងក្រុមហ៊ុនហ្វតតេរួមមាន៖

– ដោះស្រាយសំណងជាមួយតតិយជន
– អូសសណ្តោងយានយន្តរងការខូចខាតដែលមិនអាចចល័តបាន (បើចាំបាច់)
– សម្របសម្រួលជាមួយសមត្ថកិច្ចចរាចរណ៍
– ផ្តល់នូវការសង្គ្រោះបឋមសម្រាប់របួសតិចតួច
– រៀងចំចាត់ចែងការជួសជុលយានយន្ត
– ដោះស្រាយបញ្ហាសុវត្ថិភាពអតិថិជន
– ការបញ្ចុះតម្លៃពិសេស និង ការបញ្ចុះតម្លៃសម្រាប់ករណីមិនធ្លាប់បង្កគ្រោះថ្នាក់[26]

[26]យោងតាម គេហទំព័រក្រុមហ៊ុនហ្វតតេ,ផលិតផលធានារ៉ាប់រងលើយាន្តយន្ត, https://www.forteinsurance.com/km/individual-insurance/list/automobile-insurance/ , យកមកប្រើប្រាស់នៅថ្ងៃ២០មេសា២០២០

### ២.១០.៧. ផលិតផលធានារ៉ាប់រងលើអគ្គីភ័យ

មិនថាផ្ទះក្តី ឬ កន្លែងអាជីវកម្មក្តី ប្រាកដជាបានវិនិយោគដោយចំណាយទាំងពេលវេលាការខិតខំប្រឹងប្រែង និងថវិការអស់ច្រើនសន្ធឹកសន្ធាប់ ទៅលើទ្រព្យសម្បត្តិទាំងនោះ ការពារទ្រព្យសម្បត្តិ និងការវិនិយោគរបស់អតិថិជនពីការខូចខាត ដោយសារគ្រោះអគ្គីភ័យ រន្ទះ ការផ្ទុះ ទឹកជំនន់ និងហានិភ័យផ្សេងៗទៀត។[27]

### ២.១០.៨. ផលិតផលធានារ៉ាប់រងសុខភាពអន្តរជាតិ

ផលិតផលធានារ៉ាប់រងសុខភាពអន្តរជាតិសម្រាប់ ប្រជាជនខ្មែរ និង ជនបរទេសដែលរស់នៅក្នុងប្រទេសកម្ពុជា ។ ផលិតផលធានារ៉ាប់រងសុខភាពអន្តរជាតិផ្តល់នូវការធានាទូលំទូលាយសម្រាប់ការចំណាយថ្លៃព្យាបាលចាំបាច់រួមទាំងការព្យាបាលនៅមន្ទីរពេទ្យ ការព្យាបាលជំងឺក្រៅ នៅទូទាំងពិភពលោក សេវាបញ្ជូនសង្គ្រោះបន្ទាន់ សុខភាពផ្លូវចិត្ត និងការធានាលើជំងឺមានស្រាប់ (សម្រាប់គម្រោងដែលជ្រើសរើស)។

- ទឹកប្រាក់ធានារ៉ាប់រងរហូតដល់ ២,៥០០,០០០ ដុល្លារអាមេរិក ក្នុងមួយឆ្នាំ
- មន្ទីរពេទ្យដៃគូរជាង ៧៥០,០០០កន្លែងទូទាំងពិភពលោក
- ការទូទាត់ដោយផ្ទាល់នៅតាមបណ្តាញមន្ទីរពេទ្យដៃគូរ និង សេវាប្រឹក្សា ២៤ម៉ោង
- ជម្រើសអត្ថប្រយោជន៍បន្ថែមរួមមាន៖ មាតុភាព ការពិនិត្យសុខភាព សុខភាពមាត់ធ្មេញ និងសុខភាពភ្នែកសម្រាប់គម្រោង។[28]

### ២.១០.៩. ផលិតផលធានារ៉ាប់រងអាកាសចរណ៍

ខុសពីអ្វីដែលយើងធ្លាប់បានដឹងកន្លងមក ធានារ៉ាប់រងអាកាសចរណ៍ មានការធានាច្រើនលើសពី ការធានារ៉ាប់រងទៅលើយន្តហោះ និងបុគ្គលដែលជាអ្នកបើកបរ ទៅទៀត។ ការពិត ការធានារ៉ាប់រង ឯកទេសមួយនេះ គឺផ្តល់ការធានា លើហានិភ័យ និងមុខជំនួញជាប់ពាក់ព័ន្ធជាច្រើនប្រភេទ រួមមាន អាកាសយានដ្ឋាន ប្រតិបត្តិករក្រុមហ៊ុនអាកាសចរណ៍ អ្នកផ្តល់សេវាកម្មអាកាសចរណ៍ទូទៅ ប្រតិបត្តិករឧទ្ធម្ភាគចក្រ និងប្រតិបត្តិករយន្តហោះគ្មានមនុស្សបើកជាដើម។នៅក្នុងក្រុមហ៊ុន ហ្វតតេក្រុមការងារខាងធានារ៉ាប់រងអាកាសចរណ៍ ធ្វើការសហការយ៉ាងជិតដិតជាមួយនឹងទីផ្សារឈ្នួញកណ្តាលកំពូលៗប្រចាំនៅទីក្រុងឡុង ហើយក៏នៅតែបន្តអភិវឌ្ឍទៅលើសមត្ថភាព និងលទ្ធភាពទីផ្សារដែលមានមូលដ្ឋានពី អគារទីផ្សារធានារ៉ាប់រងដើម្បីរក្សាឱ្យ

---

[27]យោងតាម គេហទំព័រក្រុមហ៊ុនហ្វតតេ,ផលិតផលធានារ៉ាប់រងអគ្គីភ័យ , https://www.forteinsurance.com/km/individual-insurance/list/fire-and-perils-insurance/ , យកមកប្រើប្រាស់នៅថ្ងៃ២០មេសា២០២០

[28]យោងតាម គេហទំព័រក្រុមហ៊ុនហ្វតតេ,ផលិតផលធានារ៉ាប់រងសុខភាពអន្តរជាតិ, https://www.forteinsurance.com/km/individual-insurance/list/mediplus-insurance/ , យកមកប្រើប្រាស់នៅថ្ងៃ២០មេសា ២០២០

បាននូវបច្ចុប្បន្នភាពនៃទីផ្សារធានារ៉ាប់រង និងទិន្នន័យព័ត៌មានរបស់ក្រុមហ៊ុន។ហ្វតតេ បានត្រៀមខ្លួនរួចរាល់ក្នុងការផ្តល់ជូនផលិតផលធានារ៉ាប់រងជាច្រើនសំរាប់វិស័យអាកាសចរណ៍ រួមមាន ការខូចខាតតួយន្តហោះ និងទំនួលខុសត្រូវតតីយជននៃក្រុមហ៊ុនអាកាសចរណ៍ ទំនួលខុសត្រូវតតីយជននៃព្រលានយន្តហោះ ទំនួលខុសត្រូវទូទៅនៃក្រុមហ៊ុនផ្តល់សេវាកម្មផ្សេងៗដែលពាក់ព័ន្ធនឹងការហោះហើរ ទំនួលខុសត្រូវតតីយជននៃអាជីវកម្មដែលមានទីតាំងនៅក្នុងបរិវេណអាកាសយានដ្ឋាន ក៏ដូចជា ការធានារ៉ាប់រងលើការខូចខាតតួជ្រូននិងទំនួលខុសត្រូវតតីយជននៃប្រតិបត្តិករយន្តហោះ។[29]

### ២.១០.១០. ផលិតផលធានារ៉ាប់រងហានិភ័យនៃស្ថាប័នហិរញ្ញវត្ថុ

បច្ចុប្បន្នមាននិន្នាការកាន់តែច្រើនទៅ ដែលបង្ហាញអោយដឹងពី កំណើននៃការខាតបង់ផ្នែកហិរញ្ញវត្ថុ ដែលកើតឡើងពី សកម្មភាពក្លែងបន្លំផ្សេងៗ ដែលត្រូវបានបង្កឡើងដោយ បុគ្គលិកផ្ទាល់របស់ស្ថាប័នហិរញ្ញវត្ថុ ក៏ដូចជាភាគីតតីយជនទាំងឡាយ ដែលនៅក្រៅស្ថាប័នទាំងនោះ។

រាល់ស្ថាប័នហិរញ្ញវត្ថុ គឺតែងតែប្រឈមនឹង ហានិភ័យនៃសកម្មភាពឧក្រិដ្ឋកម្មទាំងក្នុងស្ថាប័នរបស់ខ្លួន និងក្រៅស្ថាប័ន។ ហើយលទ្ធផលនៃសកម្មភាពទាំងនេះ គឺការខាតបង់ផ្នែកហិរញ្ញវត្ថុ ដែលអាចបង្កផលប៉ះពាល់ធ្ងន់ធ្ងរទៅលើតារាងតុល្យការរបស់ស្ថាប័នហិរញ្ញវត្ថុរបស់ខ្លួន។

ក្រុមហ៊ុនហ្វតតេ មានជំនាញច្បាស់លាស់ក្នុងការផ្តល់ជូនស្ថាប័នហិរញ្ញវត្ថុនូវ សេវាធានារ៉ាប់រងដ៏ត្រឹមត្រូវមួយ ដែលធ្វើការធានាលើ ការខាតបង់ផ្នែកហិរញ្ញវត្ថុរបស់ស្ថាប័ន ក្នុងអំឡុងពេលប្រត្តិបត្តការអាជីវកម្មរបស់ពួកគេ រួមមានដូចជា ការខាតបង់ផ្នែកហិរញ្ញវត្ថុដែលកើតឡើងពីភាពមិនស្មោះត្រង់របស់បុគ្គលិក ការបាត់បង់សាច់ប្រាក់ក្នុងបរិវេណស្ថាប័ន ការបាត់បង់សាច់ប្រាក់ក្នុងអំឡុងពេលដឹកជញ្ជូន ការក្លែងបន្លំសាច់ប្រាក់ បទឧក្រិដ្ឋកម្មតាមអេឡិចត្រូនិក និងកុំព្យូទ័រ ការបាត់បង់សាច់ប្រាក់ក្នុងទូអេធីអឹម ។ល។[30]

---

[29] យោងតាម គេហទំព័រក្រុមហ៊ុនហ្វតតេ,ផលិតផលធានារ៉ាប់រងអាកាសចរណ៍, https://www.forteinsurance.com/km/corporate-insurance/ , យកមកប្រើប្រាស់នៅថ្ងៃ២០មេសា២០២០

[30] យោងតាម គេហទំព័រក្រុមហ៊ុនហ្វតតេ,ផលិតផលធានារ៉ាប់រងហានិភ័យនៃស្ថាប័នហិរញ្ញវត្ថុ , https://www.forteinsurance.com/km/corporate-insurance/, យកមកប្រើប្រាស់នៅថ្ងៃ២០មេសា២០២០

### ២.១០.១១.ផលិតផលធានារ៉ាប់រងចោរកម្ម

ប័ណ្ណសន្យារ៉ាប់រងចោរកម្ម មានសារៈសំខាន់សំរាប់ទាំងគ្រួសារនិងអជីវកម្មព្រោះប័ណ្ណសន្យារ៉ាប់រងនេះផ្តល់នូវសំណងហិរញ្ញវត្ថុនៅពេល ដែលមានការបាត់បង់ ឬ ខូចខាតទ្រព្យសម្បត្តិដែលត្រូវបានធានា ដែលបណ្តាលមកពីអំពើចោរកម្មដែលមានការលួចគាស់ចូលរឺចេញ រួមទាំងការខូចខាតទ្រព្យសម្បត្តិដែលមាននៅក្នុងបរិវេណអគាររបស់លោកអ្នកដែលបណ្តាល មកពីអំពើចោរកម្មចូលលួចគាស់យក ទ្រព្យសម្បត្តិទាំងនោះ។

ប័ណ្ណសន្យារ៉ាប់រងករណីចោរកម្មរបស់ ក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ ធានាលើទ្រព្យសម្បត្តិគ្រប់ប្រភេទ រួមទាំងទំនិញដែលជាកម្មសិទ្ធរបស់អតិថិជនរឺក៏ក្រោមការគ្រប់គ្រងនិងការទទួលខុសត្រូវរបស់អតិថិជន ដែលស្ថិតនៅក្នុងបរិវេណអគាររបស់អតិថិជន។[31]

### ២.១០.១២. ផលិតផលធានារ៉ាប់រងការសាងសង/ការតំឡើង

ក្នុងនាមជាអ្នកសាងសង់រឺម្ចាស់គំរោងសំណង់ លោកអ្នកបានចំណាយដើមទុនពេលវេលានឹងកំលាំងកាយចិត្តយ៉ាងខ្លាំង ដើម្បីសាងសង់គំរោងរបស់អ្នកអោយជោគជ័យ។ សេវាកម្មធានារ៉ាប់រងលើការសាងសង់ និងការតំឡើង របស់ហ្វតតេបង្កើតឡើងដើម្បី ផ្តល់ការការពារគ្រប់បែបយ៉ាងទៅលើគំរោងរបស់លោកអ្នក ក្នុងកំឡុងពេលសាងសង់ ការតំឡើងទៅនឹង៖

**ផ្នែកទីមួយ៖** សំណងលើការខូចខាតឬបាត់បង់នៃទ្រព្យសម្បត្តិរបស់គំរោងដែលបណ្តាលមកពីឧបទ្ទហេតុគ្រប់យ៉ាងលើកលែង កត្តាដែលមិនធានាដោយប័ណ្ណសន្យារ៉ាប់រងនេះ។

**ផ្នែកទីពីរ៖** សំណងលើតតិយជនដែលលោកអ្នកត្រូវទទួលខុសត្រូវមុខច្បាប់ក្នុងករណី

១. មរណភាព ពិការ រឺរបួសដល់តតិយជន

២. ការខូចខាតទ្រព្យសម្បតិរបស់តតិយជន ដែលកើតឡើងដោយសាការសាងសង់ក្នុងរយះពេលដែលធានា ដោយរួម បញ្ចូលថ្លៃបណ្តឹងនានា។[32]

---

[31] យោងតាម គេហទំព័រក្រុមហ៊ុនហ្វតតេ,ផលិតផលធានារ៉ាប់រងចោរកម្ម, https://www.forteinsurance.com/km/corporate-insurance/ , យកមកប្រើប្រាស់នៅថ្ងៃ២០មេសា២០២០

[32] យោងតាម គេហទំព័រក្រុមហ៊ុនហ្វតតេ,ផលិតផលធានារ៉ាប់រងការសាងសងឬតំឡើង , https://www.forteinsurance.com/km/corporate-insurance/, យកមកប្រើប្រាស់នៅថ្ងៃ២០មេសា២០២០

**២.១០.១៣. ផលិតផលធានារ៉ាប់រងគ្រឿងអេឡិចត្រូនិក**

គ្រឿងបរិក្ខារអេឡិចត្រូនិក គឺជាកត្តាដ៏សំខាន់មួយក្នុងការបំពេញសកម្មភាពវិជ្ជាជីវៈប្រចាំថ្ងៃ។ សព្វថ្ងៃគ្មានសហគ្រាសណាដែលមិនពឹងផ្អែកលើប្រព័ន្ធអេឡិចត្រូនិក ដើម្បីបំពេញតម្រូវការចាំបាច់សម្រាប់ប្រតិបត្តិការរបស់ខ្លួនឡើយ ។ គ្រឿងបរិក្ខារអេឡិចត្រូនិកមានតម្រូវការនិងលក្ខណៈពិសេសជាក់លាក់ ។ ដោយសារការទាមទារលើការធានាគ្រឿងបរិក្ខារអេឡិចត្រូនិក ដែលមានតំលៃទាំងនេះ បានជំរុញអោយក្រុមហ៊ុនហ្វតតេ ណែនាំជូននូវប័ណ្ណសន្យារ៉ាប់រង "**គ្រឿងអេឡិចត្រូនិក**" នេះដែលត្រូវបានបង្កើតឡើងដើម្បីធានាការពារហានិភ័យគ្រប់ប្រភេទទាក់ទងនឹងសម្ភារបរិក្ខារ និង គ្រឿងម៉ាស៊ីនអេឡិចត្រូនិកដែលប្រើប្រាស់ក្នុងវិស័យនានារាប់ចាប់ពី បច្ចេកវិទ្យាព័ត៌មានវិទ្យាទូរគមនាគមន៍ ធនាគារ ក៏ដូចជាវេជ្ជសាស្ត្រជាដើម។ល។[33]

**២.១០.១៤. ផលិតផលធានារ៉ាប់រងថែទាំសុខភាពបុគ្គលិក**

ផលិតផលធានារ៉ាប់រងថែទាំសុខភាពបុគ្គលិក EmCare របស់ក្រុមហ៊ុនធានារ៉ាប់រង ហ្វតតេ គឺជាគម្រោងសុខភាពដែលអាចបត់បែនទៅតាមតម្រូវការរបស់អតិថិជន ហើយត្រូវបានរចនាឡើងយ៉ាងពិសេសសម្រាប់ក្រុមហ៊ុនក្នុងស្រុក និងក្រៅស្រុកដែលមានបុគ្គលិកបំរើការងារចាប់ពី ៣នាក់ឡើងទៅ។ ផលិតផលនេះផ្តល់ការធានាយ៉ាងទូលំទូលាយ ទាំងការព្យាបាលនៅមន្ទីរពេទ្យ និងវះកាត់ ដោយរាប់បញ្ចូលទាំងជំងឺដែលតម្រូវអោយសម្រាកពេទ្យ និងមិនសម្រាកពេទ្យគួបផ្សំជាមួយជម្រើសអត្ថប្រយោជន៍បន្ថែមក្នុងករណីគ្រោះថ្នាក់ និងមានជំងឺផ្សេងៗ។ អត្ថប្រយោជន៍បន្ថែមមានដូចជា៖

- អាចធានាដល់ក្រុមគ្រួសារ (ដូចជាប្តីប្រពន្ធ និងកូនរបស់បុគ្គលិក)
- ទទួលយកសេវាកម្មដ៏មានទំនុកចិត្តនៅមន្ទីរពេទ្យ និងគ្លីនិកដៃគូសាកល ២៤ម៉ោងក្នុងមួយថ្ងៃ
- ជម្រើសអត្ថប្រយោជន៍បន្ថែមរួមមាន មាតុភាព សុខភាពមាត់ធ្មេញ ពិការភាពអចិន្ត្រៃយ៍ និងមរណភាព
- ការទូទាត់ដោយផ្ទាល់ជាមួយមន្ទីរពេទ្យ និងគ្លីនិកដៃគូ ( អ្នកត្រូវបានធានារ៉ាប់រងមិនចាំបាច់បង់ប្រាក់នៅមន្ទីរពេទ្យ និងគ្លីនិកដៃគូ)
- សេវាទូរស័ព្ទបន្ទាន់រហ័ស ២៤/៧ ជាមួយអ្នកប្រឹក្សាច្រើនភាសា[34]

---

[33] យោងតាម គេហទំព័រក្រុមហ៊ុនហ្វតតេ,ផលិតផលធានារ៉ាប់រងគ្រឿងអេឡិចត្រូនិច, https://www.forteinsurance.com/km/corporate-insurance/ , យកមកប្រើប្រាស់នៅថ្ងៃ២០មេសា២០២០

[34] យោងតាម គេហទំព័រក្រុមហ៊ុនហ្វតតេ,ផលិតផលធានារ៉ាប់រងថែទាំសុខភាពបុគ្គលិក , https://www.forteinsurance.com/km/corporate-insurance/, យកមកប្រើប្រាស់នៅថ្ងៃ២០មេសា២០២០

### ២.១០.១៥. ផលិតផលធានារ៉ាប់រងភាពស្មោះត្រង់បុគ្គលិក

ទ្រព្យសកម្មដែលមានតំលៃបំផុតរបស់ក្រុមហ៊ុនមួយគឺ បុគ្គលិករបស់ពួកគេ។ ក្រុមហ៊ុនភាគច្រើនចាត់វិធានការគ្រប់គ្រាន់ដើម្បីធានាថា ពួកគេផ្តល់ការងារដល់អ្នកមានទេពកោសល្យ ប៉ុន្តែ ការជ្រើសរើសពេលខ្លះនៅតែមានកំហុសឆ្គង។ បុគ្គលិកដែលមានទេពកោសល្យរបស់អ្នក អាចក្លាយជាមូលហេតុនៃការបាត់បង់ចោរកម្ម និងការក្លែងបន្លំនៅក្នុងក្រុមហ៊ុនរបស់អ្នក ទៅវិញ។

ជាមួយនឹងការរីកចម្រើន នៃបច្ចេកវិទ្យាក្នុងការប្រើទិន្នន័យអេឡិចត្រូនិចនិងយន្តការផ្ទេរទ្រព្យសម្បត្តិក្រុមហ៊ុនដែលធ្វើប្រត្តិបត្តិការជាមួយនឹងសាច់ប្រាក់ ទំនិញ ឬទ្រព្យសម្បត្តិផ្សេងទៀត ជាប្រចាំថ្ងៃ កំពុងតែប្រឈមនឹងការបាត់បង់ហិរញ្ញវត្ថុយ៉ាងគួរអោយកត់សំគាល់ ដែលកើតឡើងពីអំពើក្លែងបន្លំ ឬអំពើមិនស្មោះត្រង់របស់បុគ្គលិកផ្ទាល់ខ្លួនរបស់ពួកគេ។

នៅក្រុមហ៊ុនធានារ៉ាប់រង ហ្វតេ មានផ្តល់ជូននូវការធានារ៉ាប់រងលើភាពស្មោះត្រង់បុគ្គលិក ដែលធ្វើការធានា លើរាល់ការបាត់បង់ទាំងនេះដែលប្រព្រឹត្តដោយបុគ្គលិករបស់អ្នកក្នុងគោលបំណងទទួលផលប្រយោជន៍ផ្ទាល់ ខ្លួន។ សំណងអតិបរមាគឺស្មើនឹងចំនួនទឹកប្រាក់ធានារ៉ាប់រង ដែលត្រូវបានដាក់ធានាសម្រាប់និយោជិកម្នាក់ៗ។ សូមទុកចិត្តចុះថា យើងក៏អាចផ្តល់ជូនផងដែរ នូវភាពបត់បែនលើវិធីសាស្ត្រក្នុងការធ្វើការធានាលើបុគ្គលិករបស់ លោកអ្នក ទៅតាមតំរូវការនៃទីផ្សារដែលកំពុងផ្លាស់ប្តូរឥតឈប់ឈរ។ ការធានានេះអាចធ្វើបាន តាមរូបភាពជាច្រើន រួមមាន ការធានាតាមឈ្មោះបុគ្គលិកម្នាក់ៗ ការធានាតាមក្រុមបុគ្គលិក ការធានាជាទឹកប្រាក់ធានារ៉ាប់រងសរុបសំរាប់ក្រុមហ៊ុនទាំងមូល ឬ ការធានាតាមមុខតំណែងបុគ្គលិក។[35]

### ២.១០.១៦. ផលិតផលធានារ៉ាប់រងសម្រាកពេទ្យនិងវះកាត់

ប័ណ្ណសន្យារ៉ាប់រងលើការសម្រាកពេទ្យ និងវះកាត់ ជួយលោកអ្នកក្នុងការចំណាយទាំងស្រុង ឬមួយចំនួនទៅលើថ្លៃវះកាត់ និងសម្រាកព្យាបាលដែលមានតម្លៃខ្ពស់ រាប់ចាប់ពី ការពិគ្រោះជំងឺមុនពេលសម្រាកព្យាបាល រហូតដល់ការព្យាបាលត្រូវបានបញ្ចប់ ជាមួយគម្រោងផលិតផលដ៏ទូលំទូលាយដែលយើងផ្តល់ជូនធានាថាលោកអ្នកនឹងទទួលបានការការពារដោយយកចិត្តទុកដាក់ខ្ពស់ ដោយចំណាយចាប់ពី ១២សេន ប៉ុណ្ណោះក្នុងមួយថ្ងៃ។គម្រោង នេះផ្តល់ជូននូវការធានារ៉ាប់រងដ៏ទូលំទូលាយពេញ ២៤ម៉ោងក្នុងមួយថ្ងៃ និង ៣៦៥ថ្ងៃក្នុងមួយឆ្នាំ ទោះបីលោកអ្នកនៅកន្លែងធ្វើការ នៅផ្ទះ ឬវិស្សមកាលនៅប្រទេសជិតខាង ដូចជាប្រទេសថៃ ប្រទេសវៀតណាម និងប្រទេសឡាវ។

[35] យោងតាម គេហទំព័រក្រុមហ៊ុនហ្វតេ,ផលិតផលធានារ៉ាប់រងភាពស្មោះត្រង់បុគ្គលិក , https://www.forteinsurance.com/km/corporate-insurance/ , យកមកប្រើប្រាស់នៅថ្ងៃ២០មេសា២០២០

អតិថិជននឹងទទួលបាននូវការធានា លើថ្លៃចំណាយជាក់ស្តែងក្នុងអំឡុងពេល ព្យាបាលជំងឺ ឬ គ្រោះថ្នាក់ផ្សេងៗ។ ផលិតផលនេះផ្តោតយកចិត្តទុកដាក់សំខាន់ទៅលើ ថ្លៃបន្ទប់ និងអាហារផ្តល់ដោយមន្ទីរពេទ្យ ( រហូតដល់ ៩០ថ្ងៃ ) ការវះកាត់ ការពិគ្រោះជំងឺ បន្ទប់សង្គ្រោះបន្ទាន់កំរិតធ្ងន់( រហូតដល់ ២០ថ្ងៃ ) ព្រមទាំងការចំណាយក្រោយការព្យាបាល (រហូតដល់ ៩០ថ្ងៃ)។ ហ្វតតេ តែងតែគិតពីភាពងាយស្រួលរបស់អតិថិជនជាចម្បង។អតិថិជន នឹងទទួលបានអត្ថប្រយោជន៍ពីមន្ទីរពេទ្យទំនើបឈានមុខដែលជាដៃគូដ៏ជិតស្និទ្ធរបស់យើងនៅប្រទេសកម្ពុជា ដែលធានាផ្តល់នូវសេវាសុខភាពប្រកបដោយគុណភាពខ្ពស់និងទំនុកចិត្តដល់អតិថិជន ។ ប័ណ្ណសន្យារ៉ាប់រងរបស់ហ្វតតេបានផ្តល់ជូនដល់ដូចជា ៖ ភាពងាយស្រួលក្នុងការទទួលសេវាព្យាបាលការទូទាត់សំណងឆាប់រហ័សការព្យាបាលសង្គ្រោះបន្ទាន់។[36]

### ២.១០.១៧. ផលិតផលធានារ៉ាប់រងទ្រព្យសម្បត្តិ

ជាក់ស្តែងរាល់អាជីវកម្មនិងស្ថាប័ននានា ដំណើរការបានដោយមានទីតាំងត្រឹមត្រូវមួយដែលអាចជាអគារការិយាល័យ សណ្ឋាគារ ឬរោងចក្រជាដើម។ មិនថាអាជីវកម្មធំឬតូចទេ ទ្រព្យសម្បតិរបស់អ្នកអាចប្រឈមមុខនឹងហានិភ័យដោយ ឧប្បត្តិហេតុ ពីកត្តាជាច្រើនដែលរាប់មិនអស់ដើម្បីឆ្លើយតបទៅនឹងឧប្បត្តិហេតុទាំងនោះសេវាធានារ៉ាប់រងលើ ទ្រព្យសម្បតិដែលមានវិសាលភាពនៃការធានាធំធេងគឺ ជាកត្តាចាំបាច់សម្រាប់អាជីវកម្មទាំងអស់។ រាល់សហគ្រាសពាណិជ្ជកម្ម ឬឧស្សាហកម្ម ត្រូវប្រាកដថាមានការធានាការពារពេញលេញចំពោះការខូចខាត ឬ បានបាត់បង់ដែលអាចកើតមានឡើង ព្រមទាំងការអាក់ខានធ្វើអាជីវកម្មដោយសារការខូចខាតឬបាត់បង់ទ្រព្យសម្បតិទាំងនោះ។ ប័ណ្ណសន្យារ៉ាប់រងលើទ្រព្យសម្បតិរបស់ផ្តល់នូវការធានាយ៉ាងធំធេងដែលមានដូចជា សំណងលើការខូចខាត ឬ បាត់បង់នៃទ្រព្យសម្បត្តិដែលបណ្តាលមកពីឧបទ្ទវហេតុគ្រប់យ៉ាងលើកលែងកត្តាដែលមិនធានាដោយ ប័ណ្ណសន្យារ៉ាប់រងនេះ។សំណងលើការអាក់ខានធ្វើអាជីវកម្មដោយសារតែមានការខូតខាត។[37]

---

[36] យោងតាម គេហទំព័រក្រុមហ៊ុនហ្វតតេ,ផលិតផលធានារ៉ាប់រងសម្រាក់ពេទ្យនិងវះកាត់ , https://www.forteinsurance.com/km/corporate-insurance/ , យកមកប្រើប្រាស់នៅថ្ងៃ២០មេសា២០២០

[37] យោងតាម គេហទំព័រក្រុមហ៊ុនហ្វតតេ,ផលិតផលធានារ៉ាប់រងទ្រព្យសម្បត្តិ , https://www.forteinsurance.com/km/corporate-insurance/, យកមកប្រើប្រាស់នៅថ្ងៃ២០មេសា២០២០

### ២.១០.១៨. ផលិតផលធានារ៉ាប់រងការបាត់បង់ប្រាក់ចំណេញ

ខណៈដែលលោកអ្នកមានប័ណ្ណសន្យារ៉ាប់រងអគ្គិភ័យ ឬ ប័ណ្ណសន្យារ៉ាប់រងទ្រព្យសម្បត្តិដែលអាចការពារលោកអ្នកក្នុងករណីបាត់បង់ រឺខូចខាតទៅលើ ទ្រព្យសម្បត្តិ ប្រាកដណាស់ទ្រព្យសម្បត្តិរបស់លោកអ្នកមានការការពារ ។ ប៉ុន្តែលោកអ្នកខាតបង់ប្រាក់ចំណូលដោយសារមានការផ្អាកធ្វើអជីវកម្មដែលបណ្តាលមកពីការខូចខាត រឺបាត់បង់ទ្រព្យសម្បត្តិ របស់លោកអ្នក។ ដូចនេះហើយ ប័ណ្ណសន្យាធានារ៉ាប់រងលើការបាត់បង់ប្រាក់ចំណូលរបស់យើងខ្ញុំ អាចផ្តល់ដំណោះស្រាយដើម្បីកាត់បន្ថយការខាតបង់ ប្រាក់ចំណូល នេះបាន។ការធានានេះ ត្រូវរួមជាមួយនឹងប័ណ្ណសន្យារ៉ាប់រងអគ្គិភ័យ ឬប័ណ្ណសន្យារ៉ាប់រងលើទ្រព្យសម្បត្តិ ដើម្បីធានាចំពោះការបាត់បង់ប្រាក់ចំណូលដែលបណ្តាល មកពីការអាក់ខានក្នុងដំណើរអាជីវកម្ម ដែលកើតឡើងដោយសារហានិភ័យដែលត្រូវបានធានារ៉ាប់រងក្រោមប័ណ្ណសន្យារ៉ាប់រងអគ្គិភ័យ និងគ្រោះថ្នាក់ផ្សេងៗ រឺប័ណ្ណសន្យារ៉ាប់រងទ្រព្យសម្បត្តិ។[38]

### ២.១០.១៩. ផលិតផលធានារ៉ាប់រងការដឹកជញ្ជូនទំនិញ

ជាមួយនឹងការរីកចម្រើនយ៉ាងឆាប់រហ័សនៃ ពាណិជ្ជកម្មអន្តរជាតិនិងការរីកចម្រើននៃបច្ចេកវិទ្យានៅក្នុងឧស្សាហកម្មដឹកជញ្ជូន អាជីវកម្មនៃការបំលាស់ទីទំនិញនាពេលបច្ចុប្បន្ននេះ ក៏កំពុងតែរីកចំរើន ប៉ុន្តែក្នុងពេលជាមួយគ្នានេះ វាក៏មានភាពស្មុគស្មាញផងដែរ។ ពីរោងចក្រទៅដល់ទិសដៅចុងក្រោយ ខណៈពេលដែលទំនិញត្រូវបានគេដឹកជញ្ជូនតាមអាកាស តាមសមុទ្រ ឬផ្លូវដែក ផ្លូវថ្នល់ ឬតាមការរួមបញ្ចូលគ្នានៃវិធីសាស្ត្រមួយចំនួនឬទាំងអស់ខាងលើ តាមរយៈមធ្យោបាយដឹកជញ្ជូន ផ្សេងៗ គ្រប់ការដឹកជញ្ជូន គឺសុទ្ធតែត្រូវប្រឈមនឹងហានិភ័យ ជាច្រើន តាមផ្លូវធ្វើដំណើររបស់ខ្លួន ។ យើងមានក្រុមអ្នកចេញបណ្ណសន្យារ៉ាប់រងប្រកបដោយបទពិសោធន៍ ។ ពួកគេយល់យ៉ាង ច្បាស់ថាលក្ខណៈអាជីវកម្មរបស់លោកអ្នកមានមានសណ្ឋានខុសៗគ្នានិងរៀងៗខ្លួន ហើយយើងអាចផ្តល់ឱ្យលោកអ្នកនូវ ការធានាប្រកបដោយភាពបត់បែនដែលសមស្រប នឹង តម្រូវការរបស់លោកអ្នក ប្រភេទទំនិញរបស់លោកអ្នក ទិសដៅនៃការដឹកទំនិញរបស់លោកអ្នក និងរបៀបនៃការដឹកជញ្ជូនរបស់លោកអ្នក។ ការធានារ៉ាប់រងលើការដឹកជញ្ជូនទំនិញរបស់យើង ផ្តល់នូវសំណាងលើការបាត់បង់ឬខូចខាតទំនិញរបស់លោកអ្នក ដែលបណ្តាលមកពីហានិភ័យទាំងឡាយក្នុងអំឡុងពេលនៃការដឹកជញ្ជូនរួមមាន អគ្គិភ័យ ចោរលួច ការផ្ទុះ នាវាជាប់គាំង នាវាជាប់គៀង លិចនាវាការធ្លាក់ចេញ ពីនាវា

[38] យោងតាម គេហទំព័រក្រុមហ៊ុនហ្វតតេ,ផលិតផលធានារ៉ាប់រង ការបាត់បង់ប្រាក់ចំណេញ , https://www.forteinsurance.com/km/corporate-insurance/, យកមកប្រើប្រាស់នៅថ្ងៃ២០មេសា២០២០

ដោយសាររលក ការក្រឡាប់យានដឹកទំនិញតាមផ្លូវគោក ឬការក្រឡាប់រថភ្លើងព្រមទាំងហានិភ័យធម្មជាតិផ្សេងទៀត ដូចជា ការរញ្ជួយដី ការផ្ទុះភ្នំភ្លើង ឬ រន្ទះ ជាដើម។យើងមានដៃគូរបណ្តាញជាមួយភ្នាក់ងារ Lloyd ជាង 260 ភ្នាក់ងារ គិតមកដល់សព្វថ្ងៃ ។ ហេតុនេះយើងអាចផ្តល់ជូននូវការឆ្លើយតបទាន់ពេលវេលា លើការចុះវិភាគការខូចខាត ដែលពួកគាត់ស្ថិតនៅជាង 170 ប្រទេសនៅជុំវិញពិភពលោក។ ជំនាញវិជ្ជាជីវៈរបស់ពួកគាត់ និង ឯកទេសប្រកបដោយបទពិសោធន៍នៃការចេញបណ្ណធានារ៉ាប់រងរបស់យើង បានរួមបញ្ចូលគ្នា ដើម្បីផ្តល់ជូនទៅទីផ្សារនូវវិសាលភាព នៃការធានារ៉ាប់រងដ៏ល្អបំផុតនិងសេវាកម្មនៃការទាមទារសំណងដែលអាចជឿជាក់បានបំផុត។[39]

## ២.១០.២០. ផលិតផលធានារ៉ាប់រងសាច់ប្រាក់

នៅក្នុងអាជីវកម្មជាច្រើន ជាពិសេសអាជីវកម្មដែលធ្វើការជាមួយសាច់ប្រាក់រាប់តាំងពីក្រុមហ៊ុនដឹកជញ្ជូនសាច់ប្រាក់ជំនាញដែលធ្វើការដឹកជញ្ជូនសាច់ប្រាក់ រហូតដល់ស្ថាប័នហិរញ្ញវត្ថុដែលធ្វើប្រតិបត្តិការសាច់ប្រាក់នៅតាមបញ្ជរសេវាកម្មអតិថិជន ឬ នៅក្នុងទូរដែកឬបន្ទប់សុវត្ថិភាព ហានិភ័យនៃការប្លន់និងចោរគាស់គឺជាកត្តាមិនអាចមើលឃើញ ប៉ុន្តែ វាគួរអោយភ័យខ្លាច ហើយក៏អាចទៅរួចផងដែរ។ ដើម្បីផ្តោតលើយុទ្ធសាស្ត្រពង្រីកអាជីវកម្មនិងការគ្រប់គ្រងក្រុមហ៊ុនអាជីវកម្មទាំងអស់នេះត្រូវការរឿងដូចគ្នាមួយ ពោលគឺ « សន្តិភាពផ្លូវចិត្ត » ហើយក្រុមហ៊ុនទាំងនេះអាចរកវាបានតាមរយៈការទទួលយកនូវសេវាធានារ៉ាប់រងលើសាច់ប្រាក់របស់យើង។ ក្រុមហ៊ុនហ្វតតេ មានឯកទេសក្នុងការផ្តល់ជូននូវ ការធានារ៉ាប់រងលើសាច់ប្រាក់ដែលផ្តល់សំណងលើការបាត់បង់សាច់ប្រាក់ ទាំងក្នុងអំឡុងពេលដឹកជញ្ជូនពីកន្លែងមួយទៅកន្លែងមួយ និងទាំងក្នុងអំឡុងពេលដែលសាច់ប្រាក់ត្រូវបានរក្សាទុកនៅខាងក្នុងទូរដែក ឬ បន្ទប់សុវត្ថិភាពនិងបន្ទប់រឹងមាំនៅក្នុងទីតាំងជាក់លាក់ណាមួយរួមទាំងម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិនៃគ្រឹះស្ថានហិរញ្ញវត្ថុផងដែរ។ ប័ណ្ណធានារ៉ាប់រងរបស់យើង ធ្វើការធានាលើការព្រួយបារម្ភភាគច្រើនរួមមានការបាត់បង់សាច់ប្រាក់ដែលបណ្តាលពី ចោរគាស់បន្ទាប់ពីម៉ោងធ្វើការឬបណ្តាលពីអំពើប្លន់ក្នុងម៉ោងធ្វើការរួមទាំងការធានាបន្ថែមលើការខូចខាតនៃបរិវេណ ឬទូរដែកសុវត្ថិភាព ឬបន្ទប់រឹងមាំ និងម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិផងដែរ។[40]

---

[39] យោងតាម គេហទំព័រក្រុមហ៊ុនហ្វតតេ,ផលិតផលធានារ៉ាប់រងការដឹកជញ្ជូនទំនិញ, https://www.forteinsurance.com/km/corporate-insurance/ , យកមកប្រើប្រាស់នៅថ្ងៃ២០មេសា២០២០

[40] យោងតាម គេហទំព័រក្រុមហ៊ុនហ្វតតេ,ផលិតផលធានារ៉ាប់រងសាច់ប្រាក់, https://www.forteinsurance.com/km/corporate-insurance/ , យកមកប្រើប្រាស់នៅថ្ងៃ២០មេសា២០២០

### ២.១០.២១. ផលិតផលធានារ៉ាប់រងផ្ទាំងកញ្ចក់

ប័ណ្ណសន្យារ៉ាប់រងនេះ ត្រូវបានបង្កើតឡើងសម្រាប់អគារនានាដែលមានទ្វារកញ្ចក់ បង្អួចកញ្ចក់ បន្ទះកញ្ចក់ និងការបង្ហាញផលិតផលក្នុងផ្ទាំងកញ្ចក់។ ប័ណ្ណសន្យារ៉ាប់រងផ្ទាំងកញ្ចក់ ផ្ដល់នូវសំណងដល់ការធានារ៉ាប់រងចំពោះការបាត់បង់និងការខូចខាតដោយផ្ទាំងកញ្ចក់ ដែលកើតឡើងដោយគ្រោះថ្នាក់ឧបទ្ទវហេតុដោយចៃដន្យ។ មានជម្រើសជាច្រើនសម្រាប់ការផ្ដល់សំណង រាប់ទាំងការប្ដូរកញ្ចក់ដែលបែក ឬទូទាត់សំណងជាសាច់ប្រាក់ដែលមានតម្លៃ ស្មើនឹងតម្លៃកញ្ចក់ដែលបែក ក្នុងពេលបាត់បង់ ឬ ខូចខាត រហូតដល់អតិបរមានៃតំលៃដែលដាក់ធានា។ ប័ណ្ណសន្យារ៉ាប់រងនេះក៏អាចរៀបចំសម្រាប់ទូរកញ្ចក់ សញ្ញាបង្ហាញ កញ្ចក់ជាប់នឹងជញ្ជាំង និង កញ្ចក់ខណ្ឌចែកនៅក្នុងបរិវេណអគារ។[41]

### ២.១០.២២. ផលិតផលធានារ៉ាប់រងទំនួលខុសត្រូវវិជ្ជាជីវៈ

ក្នុងនាមជាអ្នកអាជីពម្នាក់ លក្ខណៈវិជ្ជាជីវៈក្នុងការងារលោកអ្នក មានន័យថា ដំបូន្មាន ការផ្ដល់សេវា ឬផលិតផលរបស់លោកអ្នក អាចមានតម្លៃស្មើដល់រាប់លានដុល្លារ ចំពោះ អតិថិជនរបស់លោកអ្នក ឬក៏អាចមានផលប៉ះពាល់ យ៉ាងធ្ងន់ធ្ងរ ទៅលើពួកគេ ប្រសិនបើ លោកអ្នកធ្វើឱ្យមានកំហុស ឬ ការភ្លេចភ្លាំងណាមួយ។ លោកអ្នកត្រូវប្រឈមនឹងការប្ដឹងផ្ដល់ទាំងពីសំណាក់អតិថិជនរបស់លោកអ្នក និងពីសំណាក់អ្នកដ៏ទៃទៀតដែលទទួលរងផលប៉ះពាល់ពីកំហុស ឬ ការភ្លេចភ្លាំងនោះ ។មិនថាក្រុមហ៊ុន ឬ បុគ្គល គឺសុទ្ធតែ បានរកឃើញថាខ្លួនជាប់ពាក់ព័ន្ធនឹងបណ្ដឹងរឿងក្ដីក្ដាំកាន់តែ ច្រើនឡើង ដែលកើតចេញពីកំហុស និងការភ្លេចភ្លាំង នៅពេលដែលពួកគាត់ផ្ដល់នូវសេវាកម្មវិជ្ជាជីវៈ ទៅអតិថិជនរបស់ពួកគាត់។ ការការពារសំណុំរឿងក្ដីក្ដាំមួយ មិនត្រឹមតែចំណាយពេលនិងប្រាក់កាស ប៉ុណ្ណោះទេ តែវា រឹតតែប៉ះពាល់ដល់កេរ្តិ៍ឈ្មោះក្រុមហ៊ុនឬ កេរ្តិ៍ឈ្មោះបុគ្គលនៅក្នុងវិស័យអាជីវកម្ម លោកផងដែរ។ប្រសិនបើ លោកអ្នកជាវិជ្ជាជីវៈណាមួយក្នុងចំណោមវិជ្ជាជីវៈទាំងនេះ៖ ក្រុមហ៊ុនភ្នាក់ងារផ្សាយពាណិជ្ជកម្ម អ្នកអភិវឌ្ឍន៍កម្មវិធីកុំព្យូទ័រ អ្នកផ្ដល់ប្រឹក្សាផ្នែកទីផ្សារ ក្រុមហ៊ុនបោះពុម្ពផ្សាយ ភ្នាក់ងារស្វែងរកការងារ អ្នកអង្កេតបរិមាណ សាស្ត្រាចារ្យអ្នកអប់រំ អ្នកផ្ដល់ប្រឹក្សាលើការគ្រប់គ្រង ស្ថាប័នហិរញ្ញវត្ថុ អ្នកគ្រប់គ្រងអចលនទ្រព្យ ឬ អ្នកជំនាញវិជ្ជាជីវៈ ផ្សេងៗទៀត លោកអ្នកអាចទទួលបានការការពារពីសេវាធានារ៉ាប់រងទំនួលខុសត្រូវវិជ្ជាជីវៈ ជាមួយក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ។

---

[41] យោងតាម គេហទំព័រក្រុមហ៊ុនហ្វតតេ,ផលិតផលធានារ៉ាប់រងផ្ទាំងកញ្ចក់, https://www.forteinsurance.com/km/corporate-insurance/ , យកមកប្រើប្រាស់នៅថ្ងៃ២០មេសា២០២០

ផលិតផលធានារ៉ាប់រងទំនួលខុសត្រូវវិជ្ជាជីវៈ នេះ ផ្តល់នូវការការពារហិរញ្ញវត្ថុសម្រាប់អ្នកអាជីព លើការការពារសំណុំរឿងក្តីក្តាំជាមួយតតិយជនដែលបានរងការខាតបង់ហិរញ្ញវត្ថុ ដោយសារតែទង្វើខុសឆ្គងនិងការធ្វេសប្រហែសលើវិជ្ជាជីវៈរបស់គាត់។[42]

### ២.១០.២៣. ផលិតផលធានារ៉ាប់រងទំនួលខុសត្រូវសាធារណៈ

ក្រុមហ៊ុនហ្វតតេមានផលិតផលធានារ៉ាប់រងលើទំនួលខុសត្រូវសាធារណៈ ដែលអាចផ្តល់ជូននូវការការពារក្នុងការប្រឆាំងតវ៉ាជាមួយការទាមទារសំណង ឬបណ្តឹងពីភាគី ឬបុគ្គលទី៣ ដែលកើតចេញពីការបង្ករបួសស្នាមលើរាងកាយ ការខូចខាតទ្រព្យសម្បត្តិ និង ការបង្ខូចកេរ្តិ៍ឈ្មោះ ដែលអាចកើតមានឡើងដោយសារបរិវេណនៃទីតាំងការិយាល័យ ប្រតិបត្តិការអាជីវកម្ម និង ផលិតផល និងការងារដែលបានបញ្ចប់រួចហើយ។[44]

អត្ថប្រយោជន៍បន្ថែមផលិតផលធានារ៉ាប់រងទំនួលខុសត្រូវសាធារណៈរួមមានដូចជា៖

- មានរួមបញ្ចូល ការចំណាយលើមេធាវីការពារក្តី
- ហ្វតតេ អាចផ្តល់ជូននូវការធានារ៉ាប់រង ដែលធ្វើការធានាទាំង តាមដែនកំណត់ដែនដីទូទាំងពិភពលោក និង យុត្តាធិការទូទាំងពិភពលោក។
- មានភាពបត់បែនគ្រប់គ្រាន់ ក្នុងការកំណត់ទំហំនៃការធានា ដើម្បីផ្តល់ជូននូវការធានាលើ កន្លែងចតរថយន្តការសង្គ្រោះបឋម ជណ្តើរយន្តជើងនិងជណ្តើរយន្តប្រអប់ ឧបករណ៍លើក និងស្ទូច ផ្ទាំងផ្សាយពាណិជ្ជកម្ម សកម្មភាពសង្គម និងកីឡា ដំណើរអាជីវកម្មក្រៅប្រទេស និង ទំនួលខុសត្រូវរបស់អ្នកជួល ជាដើម។[43]

### ២.១០.២៤. ផលិតផលធានារ៉ាប់រងគ្រឿងម៉ាស៊ីនដើរដោយចំហាយ/ចំហេះ

ប័ណ្ណសន្យារ៉ាប់រងលើ គ្រឿងម៉ាស៊ីនដោយប្រើចំហាយ/ចំហេះផ្តល់នូវការការពារនៅពេលដែលមានការផ្ទុះ រឺការខូចខាតផ្នែកណាមួយនៃម៉ាស៊ីននោះ។ប័ណ្ណសន្យារ៉ាប់រងនេះធ្វើសំណងដល់អតិថិជនក្នុងករណីដូចជា៖

**ផ្នែកទីមួយ៖ ការខូចខាតនៃ( ក្រៅពីការខូចខាតដោយអគ្គីភ័យ )**

- ផ្នែកណាមួយនៃម៉ាស៊ីនសម្ភារៈឬក៏ ទ្រព្យសម្បត្តិផ្សេងៗដែលជាកម្មសិទ្ធរបស់អតិថិជន ឬ ក្រោមការគ្រប់គ្រងនិងការទទួលខុសត្រូវរបស់អតិថិជន។

---

[42] យោងតាម គេហទំព័រក្រុមហ៊ុនហ្វតតេ,ផលិតផលធានារ៉ាប់រងទំនួលខុសត្រូវវិជ្ជាជីវៈ , https://www.forteinsurance.com/km/corporate-insurance/ , យកមកប្រើប្រាស់នៅថ្ងៃ២០មេសា២០២០

[43] យោងតាម គេហទំព័រក្រុមហ៊ុនហ្វតតេ,ផលិតផលធានារ៉ាប់រងទំនួលខុសត្រូវសាធារណៈ, https://www.forteinsurance.com/km/corporate-insurance/ , យកមកប្រើប្រាស់នៅថ្ងៃ២០មេសា២០២០

**ផ្នែកទីពីរ៖** ទំនួលខុសត្រូវមុខច្បាប់ក្នុងករណី

- មរណភាព ពិការ រឺរបួសដល់បុគ្គលនានា ដែលមិនមែនជាបុគ្គលិក

-ការខូចខាតទ្រព្យសម្បត្តិរបស់ជនដទៃ ដែលមិនមែនជាទ្រព្យសម្បត្តិរបស់អតិថិជន។

ប័ណ្ណសន្យារ៉ាប់រងនេះផ្តល់នូវការការពារដល់គ្រឿងម៉ាស៊ីនដោយផ្តល់សំណងទៅលើការជួសជុល ឬផ្លាស់ប្តូរគ្រឿងបន្លាស់ រឺម៉ាស៊ីនទាំងមូល ដែលខូចខាតបណ្តាលមកពីឧបទ្ទហេតុគ្រប់យ៉ាងលើកលែងកត្តាដែលមិនធានាដោយប័ណ្ណសន្យារ៉ាប់រងនេះ នៅពេលដែលម៉ាស៊ីនទាំងនេះកំពុងដំណើរការ ពេលសំរាកមិនដំណើរការ ពេលកំពុងរុះរើ ផ្លាស់ប្តូរទីកន្លែង រឺតំឡើងឡើងវិញ ក្នុងគោលបំណងដើម្បីសំអាត ត្រួតពិនិត្យ ជួសជុល ឬ តំឡើង នៅទីតាំងណាមួយក្នុងអគារ។ប័ណ្ណសន្យារ៉ាប់រងនេះមានសារៈសំខាន់ណាស់ចំពោះចង្វាក់ផលិតកម្ម ព្រោះការផលិតត្រូវការការដំណើរការរបស់គ្រឿងម៉ាស៊ីនជារៀងរាល់ថ្ងៃ។[44]

## ២.១០.២៥. ផលិតផលធានារ៉ាប់រងទំនួលខុសត្រូវស្របច្បាប់នៃនាយកនិងមន្ត្រីគ្រប់គ្រង

នាយកនិងមន្ត្រីគ្រប់គ្រងនៃក្រុមហ៊ុនទាំងឡាយ តែងធ្វើការសំរេចចិត្តជាប្រចាំថ្ងៃ ដោយមិនបានដឹងថា ការសំរេចចិត្តទាំងនោះ មានហានិភ័យដែលអាចជា វិវាទបុគ្គល និងការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ ដែលគ្មានដែនកំណត់ ដែលអាចនឹងជះឥទ្ធិពលចំពោះភាពជោគជ័យរបស់ក្រុមហ៊ុន ក៏ដូចជាអាជីពការងាររបស់ខ្លួន។ថ្មីៗនេះបញ្ហាវិវាទបុគ្គលនេះ បានកើនឡើងក្នុងអត្រាមួយដែលគួរឲ្យព្រួយបារម្ភ ហើយនិន្នាការនេះបានបង្ហាញថាអត្រាកំណើននេះគ្មានសញ្ញាថយចុះនៅឡើយទេ ខណៈច្បាប់ថ្មីត្រូវបានអនុម័ត ទាំងនៅជុំវិញតំបន់អាស៊ី និងអន្តរជាតិ។យើងដឹងយ៉ាងច្បាស់ ពីតម្រូវការដើម្បីការពារ នាយកនិងមន្ត្រីគ្រប់គ្រងរបស់លោកអ្នក ពីផលប៉ះពាល់ទាំងនេះ។ យើងដឹងពីសារៈសំខាន់នៃការផ្តល់ជូននូវការការពារលើទំនួលខុសត្រូវនៃគណៈគ្រប់គ្រងដ៏ល្អបំផុត ដែលអាចធ្វើទៅបាន។ ប្រវត្តិស្នាដៃ បទពិសោធន៍ និង ភាពជាអ្នកដឹកនាំក្នុងវិស័យធានារ៉ាប់រង របស់យើង ត្រូវបានរួមបញ្ចូលគ្នាដើម្បីផ្តល់ជូននូវសេវាធានារ៉ាប់រងប្រកបដោយភាពច្នៃប្រឌិត និងទូលំទូលាយបំផុតសម្រាប់នាយកនិងមន្ត្រីគ្រប់គ្រងរបស់លោកអ្នក។[45]

---

[44] យោងតាម គេហទំព័រក្រុមហ៊ុនហ្វតតេ,ផលិតផលធានារ៉ាប់រងគ្រឿងម៉ាស៊ីនដើរដោយចំហាយឬចំហេះ , យកមកប្រើប្រាស់នៅថ្ងៃ ២០មេសា២០២០https://www.forteinsurance.com/km/corporate-insurance/ ,

[45] យោងតាម គេហទំព័រក្រុមហ៊ុនហ្វតតេ,ផលិតផលធានារ៉ាប់រងទំនួលខុសត្រូវស្របច្បាប់នៃនាយកនិងមន្ត្រីគ្រប់គ្រង, យកមកប្រើប្រាស់នៅថ្ងៃ២០មេសា២០២០ , https://www.forteinsurance.com/km/corporate-insurance/ ,

### ២.១០.២៦. ផលិតផលធានារ៉ាប់រងគ្រឿងចក្រនិងគ្រឿងម៉ាស៊ីនរបស់ក្រុមហ៊ុនម៉ៅការ

ស្របពេលវេលាដែលដើរលឿនពីមួយថ្ងៃទៅមួយថ្ងៃគ្រឿងចក្រ និងគ្រឿងម៉ាស៊ីនរបស់លោកអ្នកធ្វើកាយ៉ាងពេញកម្លាំងលើគម្រោងការដ្ឋាន ។ ខណៈពេលដែលលោកអ្នកគិតតែផ្ដោតលើការសម្រេចការងារអោយចប់ទាន់ពេលវេលាកំណត់ លោកអ្នកអាចភ្លេចគិតដល់ហានិភ័យមួយចំនួនដែលលោកមិនបានដឹងដូចជាគ្រោះថ្នាក់ជាយថាហេតុ ការបុកគ្នារ ការក្រឡាប់ អគ្គិភ័យ ចោរលួចប្លន់ និងគ្រោះធម្មជាតិដូចជា ការរំជួយដី ទឹកជំនន់ និងគ្រោះធម្មជាតិផ្សេងៗទៀតដែលអាចកើតឡើងគ្រប់ពេលវេលា។ ការពារអាជីវកម្មលោកអ្នកកុំឲ្យមានការខាតបង់លើកត្តាថៃដន្យទាំងនេះជាមួយ ការធានារ៉ាប់រងពេញលេញសម្រាប់គ្រឿងចក្រ និង គ្រឿងម៉ាស៊ីនជាមួយប័ណ្ណសន្យារ៉ាប់រងគ្រឿងចក្រ និងគ្រឿងម៉ាស៊ីនរបស់ក្រុមហ៊ុនរបស់ហ្វតតេ ។

នេះជាប័ណ្ណសន្យារ៉ាប់រងដែលធានាគ្រប់ហានិភ័យ ទៅលើគ្រឿងចក្រនិងគ្រឿងម៉ាស៊ីនដែលប្រើប្រាស់ក្នុងការដ្ឋានសំណង់។ ប័ណ្ណសន្យារ៉ាប់រងនេះ ធ្វើសំណងជូននៅពេលគ្រឿងចក្រ និង គ្រឿងម៉ាស៊ីនរទទួលរងការខូចខាត ឬ បាត់បង់ដោយកត្តាខាងក្រៅទាំងឡាយជាយថាហេតុហើយកត្តានោះមិនបានលើកលែងនៅក្នុងប័ណ្ណសន្យារ៉ាប់រង។ សម្រាប់គ្រឿងចក្រនិងគ្រឿងម៉ាស៊ីនដែលអាចធានាក្រោមគោលការណ៍ របស់ប័ណ្ណសន្យារ៉ាប់រង មានដូចខាងក្រោម៖

- ម៉ាស៊ីនកិនពង្រាបផ្លូវថ្នល់
- ម៉ាស៊ីនក្រាលផ្លូវកៅស៊ូ ឬបេតុង
- ម៉ាស៊ីនស្ទូច
- ម៉ាស៊ីនរំញ័រ
- ច្រវាក់យោង ទម្ពក់រ៉ែក
- រោងចក្របង្កើតថាមពល
- ម៉ាស៊ីនបូមលាយស៊ីម៉ងត៍
- ម៉ាស៊ីនអេស្កាចូក និងអេស្កាកាយ
- ម៉ាស៊ីនឈូសឆាយ[46]

[46] យោងតាម គេហទំព័រក្រុមហ៊ុនហ្វតតេ,ផលិតផលធានារ៉ាប់រងគ្រឿងចក្រនិងគ្រឿងម៉ាស៊ីនរបស់ក្រុមហ៊ុនម៉ៅការ, យកមកប្រើប្រាស់នៅថ្ងៃ២០មេសា២០២០https://www.forteinsurance.com/km/corporate-insurance/ ,

## ២.១១ ការវិភាគលើ GROSS PREMIUM និង NET PREMIUM

តារាងខាងក្រោមនេះ ជាតារាងដែលធ្វើការបង្ហាញអំពីការប្រៀបធៀបអំពីបុព្វលាភដុល និងបុព្វលាភគោលប្រចាំឆ្នាំរវាងក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ ជាមួយនិង ក្រុមហ៊ុនធានារ៉ាប់រងផ្សេងៗទៀតចាប់តាំងពី ឆ្នាំ ២០០៩ រហូតដល់២០១៨។លើសពីនេះទៅទៀតក្រុមហ៊ុនធានារ៉ាប់រងទូទៅនៅឆ្នាំ២០០៩មានចំនួន ៦ និងមានការកើនរហូតទៅដល់១២ ក្រុមហ៊ុននៅក្នុងឆ្នាំ ២០១៨។

តាមរយៈតារាងយើងឃើញថានៅក្នុងវិស័យធានារ៉ាប់រងទាំងមូលនៅក្នុងប្រទេសកម្ពុជាមានការ កើនឡើងទាំងបុព្វលាភដុល និងបុព្វលាភគោលជារៀងរាល់ឆ្នាំ។

| Gross Premium(USD) | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
|---|---|---|---|---|---|---|---|---|---|---|
| Industry | 20,012,934 | 24,873,121 | 29,711,519 | 36,090,237 | 42,109,117 | 52,975,741 | 61,645,937 | 70,401,608 | 75,372,255 | 86,698,829 |
| Forte Insurance | 5,774,764 | 8,244,711 | 9,755,501 | 12,364,779 | 15,963,497 | 23,868,605 | 28,098,144 | 32,928,617 | 34,421,721 | 39,496,473 |
| Number of companies | 6 | 6 | 6 | 6 | 6 | 6 | 7 | 7 | 7 | 12 |
| Insurance Industry average | 3,335,489 | 4,145,520 | 4,951,920 | 6,015,040 | 7,018,186 | 8,829,290 | 8,806,562 | 10,057,373 | 10,767,465 | 7,224,902 |
| Net Premium(USD) | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| Industry | 7,645,666 | 9,237,457 | 11,514,945 | 14,124,621 | 16,658,435 | 19,119,496 | 24,879,579 | 29,098,356 | 27,403,812 | 31,971,875 |
| Forte Insurance | 3,580,617 | 4,423,267 | 5,657,352 | 6,899,117 | 9,280,650 | 11,109,541 | 15,159,775 | 16,643,545 | 16,439,875 | 18,478,974 |
| Number of companies | 6 | 6 | 6 | 6 | 6 | 6 | 7 | 7 | 7 | 12 |
| Insurance Industry average | 1,274,278 | 1,539,576 | 1,919,158 | 2,354,104 | 2,776,406 | 3,186,583 | 3,554,226 | 4,156,908 | 3,914,830 | 2,664,323 |

*តារាងទី៥ តារាងការវិភាគទៅលើ Gross Premium និងNet Premium របស់ក្រុមហ៊ុនហ្វតតេនិងវិស័យធានារ៉ាប់រងនៅក្នុងប្រទេសកម្ពុជា(២០០៩-២០១៨)*

ប្រភព៖ Forte Corporate Profile 2019

ក្រាបខាងក្រោមនេះ ជាក្រាបដែលបង្ហាញអំពីបុព្វលាភដុលប្រចាំឆ្នាំរបស់ ក្រុមហ៊ុនធានារ៉ាប់រងហ្វតតេជាមួយនិង បុព្វលាភដុលជាមធ្យមប្រចាំឆ្នាំវិស័យធានារ៉ាប់រងទាំងមូលនៅក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ ២០០៩ រហូតដល់២០១៨ ។ ជារួមមកចំពោះបុព្វលាភដុលនៅក្នុងក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ មានការកើនឡើងជារៀងរាល់ឆ្នាំ ចំណែកឯ បុព្វលាភដុលជាមធ្យមប្រចាំឆ្នាំរបស់វិស័យធានារ៉ាប់រងនៅប្រទេសកម្ពុជាវិញ ចាប់ពីឆ្នាំ ២០០៩ ដល់ឆ្នាំ២០១៧ មានការឃើញតៗតែដល់ឆ្នាំ២០១៨ ក៏មានការធ្លាក់ចុះវិញយ៉ាងខ្លាំង។




*ក្រាបទី១ បង្ហាញពីGross Premium របស់ក្រុមហ៊ុនហ្វតតេនិងវិស័យធានារ៉ាប់រងជាមធ្យមនៅក្នុងប្រទេសកម្ពុជា (២០០៩-២០១៨)*

ប្រភព៖ Forte Corporate Profile 2019

ក្រាបខាងក្រោមនេះជាក្រាប ដែលបង្ហាញអំពីបុព្វលាភគោលប្រចាំឆ្នាំរវាងក្រុមហ៊ុនធានារ៉ាប់រងហ្វតតេជាមួយ និង បុព្វលាភគោលជាមធ្យមប្រចាំឆ្នាំរបស់វិស័យធានារ៉ាប់រង ក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ ២០០៩ រហូតដល់២០១៨។ យើងឃើញថាចំពោះបុព្វលាភដុលនៅក្នុងក្រុមហ៊ុនធានារ៉ាប់រងហ្វតតេមានការកើនឡើងខ្លាំងចាប់ពីឆ្នាំ ២០០៩ ដល់ឆ្នាំ២០១៦ តែនៅឆ្នាំ ២០១៦ដល់ ២០១៧មានការធ្លាក់ចុះបន្តិចបន្ទាប់ក៏មានការកើនឡើងវិញយ៉ាងខ្លាំងនៅក្នុងឆ្នាំ ២០១៨ ។តែបើយើងក្រឡេកទៅមើលក្រាបដែលបង្ហាញពី បុព្វលាភគោលជាមធ្យមប្រចាំឆ្នាវិស័យធានារ៉ាប់រងទាំងមូលវិញយើងឃើញថាមានកើនឡើងបន្តិចម្តងៗចាប់ពីឆ្នាំ ២០០៩ដល់ឆ្នាំ២០១៦ ហើយនៅចន្លោះឆ្នាំ ២០១៦ ដល់ ២០១៧ មានការថយចុះវិញបន្តិចវិញលើសពីនេះវាមានការធ្លាក់ចុះយ៉ាងខ្លាំងនៅឆ្នាំ ២០១៧ ដល់ ២០១៨។




*ក្រាបទី២ បង្ហាញពី Net Premium របស់ក្រុមហ៊ុនហ្វតតេនិងវិស័យធានារ៉ាប់រងជាមធ្យមនៅក្នុងប្រទេសកម្ពុជា(២០០៩-២០១៨)*

ប្រភព៖ Forte Corporate Profile 2019

## ២.១២. ការវិភាគលើចំណែកទីផ្សាររបស់ក្រុមហ៊ុនហ្វតតេធៀបនិងទីផ្សារទាំងមូល

ក្រាបទាំងពីរ ខាងក្រោមនេះជាការបង្ហាញអំពីការប្រៀបធៀបអំពីចំណែកទីផ្សាររវាង ក្រុមហ៊ុនធានារ៉ាប់រងទូទៅហ្វតតេជាមួយក្រុមហ៊ុនធានារ៉ាប់រងទូទៅផ្សេងៗទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនធានារ៉ាប់រងទូទៅសរុបនៅក្នុងឆ្នាំ២០១៨ មាន ១២ ក្រុមហ៊ុន។ ហើយលើសពីនេះទៅទៀតក្រុមហ៊ុនធានារ៉ាប់រងទូទៅហ្វតតេទទួលបានចំណែកទីផ្សារគិតជាបុព្វលាភដុលចំនួន ៤៥.៦% និង ៥៤.៤% ទៀតជាចំណែកទីផ្សារនៃក្រុម១១ផ្សេងទៀត ។ជាមួយគ្នានេះដែរ ចំណែកទីផ្សារគិតជាបុព្វលាភគោលក្នុងក្រុមហ៊ុនធានារ៉ាប់រងហ្វតតេទទួលបាន ៥៧% និង ៤៣%ទៀតជាចំណែកទីផ្សារនៃក្រុម ១១ផ្សេងទៀត។ ក្រាបចំណែកទីផ្សារគោលនៅឆ្នាំ ២០១៨ បានបង្ហាញអោយឃើញថាក្រុមហ៊ុនធានារ៉ាប់រងទូទៅទទួលបានចំណែកទីផ្សារច្រើនជាងគេនិងទទួលបានលេខមួយបើធៀបនិងក្រុមហ៊ុនធានារ៉ាប់រងទទូទៅផ្សេងៗទៀតនៅក្នុងឆ្នាំ២០១៨។




*ក្រាបទី៣ ចំណែកទីផ្សាររបស់ក្រុមហ៊ុនហ្វតតេធៀបនឹងវិស័យនេះទាំងមូលក្នុងឆ្នាំ២០១៨ផ្អែកលើ* Gross Premium

ប្រភព៖ ***Forte Corporate Profile*** 2019




*ក្រាបទី៤ ចំណែកទីផ្សាររបស់ក្រុមហ៊ុនហ្វតតេធៀបវិស័យនេះទាំងមូលក្នុងឆ្នាំ២០១៨ ផ្អែលើ NetPremium*

ប្រភព៖ ***Forte Corporate Profile*** 2019

## ២.១៣. ការវិភាគអំពីចំណាត់ថ្នាក់បុព្វលាភរបស់ផលិតផលនីមួយៗ

តារាងខាងក្រោមនេះ ជាតារាងដែលបង្ហាញអំពី ចំណាត់ថ្នាក់របស់ផលិតផលក្នុងក្រុមហ៊ុនដែលបានបែងចែកជា ៧ ធំៗ ដែលបានបង្ហាញពីចំនួនបុព្វលាភទទួលបានប្រចាំឆ្នាំចាប់តាំងពីឆ្នាំ ២០០៩ រហូតដល់ ២០១៨។

| Product Class/Year | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
|---|---|---|---|---|---|---|---|---|---|---|
| Automobile | $1,173,981 | $1,321,494 | $1,590,617 | $1,860,565 | $2,219,231 | $2,649,792 | $3,099,393 | $3,442,684 | $3,997,451 | $5,038,324 |
| Casualty | $1,673,615 | $1,999,396 | $2,323,743 | $2,832,445 | $3,538,851 | $4,237,711 | $5,960,240 | $5,676,644 | $5,942,229 | $6,776,313 |
| Engineering | $-508,902 | $964,991 | $870,789 | $1,126,824 | $1,250,232 | $4,014,080 | $1,767,745 | $3,518,117 | $2,665,312 | $3,076,001 |
| Marine | $342,130 | $320,030 | $347,894 | $415,214 | $445,354 | $1,106,421 | $1,301,380 | $1,342,712 | $1,584,912 | $1,530,183 |
| Medical | $942,835 | $922,899 | $1,243,712 | $1,571,517 | $2,005,316 | $2,717,641 | $4,263,146 | $5,379,223 | $6,434,488 | $8,870,121 |
| Oil & Gas | | $226,372 | $349,203 | $111,645 | $26,193 | | | | $35,742 | $39,841 |
| Property | $2,151,105 | $2,489,529 | $3,029,544 | $4,360,357 | $6,391,689 | $9,150,552 | $11,706,140 | $12,911,528 | $13,356,926 | $14,849,791 |

*តារាងទី៦ តារាងបុព្វលាភនៃផលិតផលនីមួយៗនៅក្នុងក្រុមហ៊ុនហូតតេពីឆ្នាំ( ២០០៩ដល់២០១៨ )*

ប្រភព ៖ Forte Corporate Profile 2019

ក្រាបខាងក្រោមនេះជាក្រាបដែលបង្ហាញអំពី ចំណាត់ថ្នាក់របស់ផលិតផលក្នុងក្រុមហ៊ុនដែលបានបែងចែកជា ៦ធំៗ ដែលបានបង្ហាញអំពីចំនួនបុព្វលាភជាភាគរយទទួលបានប្រចាំឆ្នាំ ២០១៨។ក្នុងនោះ ផលិតផលធានារ៉ាប់រងលើទ្រព្យសម្បត្តិ (Property) មានចំនួន ៣៧% , ធានារ៉ាប់រងសុខភាព (Medical) មានចំនួន ២២% , ធានារ៉ាប់រងគ្រោះថ្នាក់បុគ្គល (Casualty) មានចំនួន១៧% , ធានារ៉ាប់រងលើយានយន្ត (Automobile) មានចំនួន១២% , ធានារ៉ាប់រងលើសំណង់(Engineering) មានចំនួន៨% ធានារ៉ាប់រងលើការដឹកជញ្ជូន(Marine)មានចំនួន៤%។នេះជាសញ្ញាបង្ហាញឲ្យឃើញថា ផលិតផលធានារ៉ាប់រងលើទ្រព្យសម្បត្តិគឺជាចំណែកមួយយ៉ាងសំខាន់ក្នុងការរកប្រាក់ចំណូលរបស់ក្រុមហ៊ុន។




*ក្រាបទី៥ ការផ្តល់សេវាកម្មពេញនិយមនៅក្នុងក្រុមហ៊ុនក្នុងឆ្នាំ២០១៨*, ប្រភព៖ Forte Corporate Profile 2019

# ជំពូកទី៣
# ដំណើរការនៃការផ្តល់សេវា
# កម្មធានារ៉ាប់រងលើ
# ផលិតផលអគ្គីភ័យ

# ជំពូកទី៣

# ដំណើរការនៃការផ្តល់សេវាកម្មធានារ៉ាប់រងលើផលិតផលអគ្គីភ័យ

## ៣.១. គោលបំណងនៃការផ្តល់សេវាកម្មធានារ៉ាប់រងលើអគ្គីភ័យ

ក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ បានបង្កើតនូវសេវាធានារ៉ាប់រងលើអគ្គីភ័យនេះឡើងក្នុងគោលបំណងមានដូចជាដើម្បីចូលរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមតាមរយៈការផ្តល់ការងារដល់ប្រជាជន មិនថាក្នុងនិងក្រៅប្រទេសជួយផ្ទេរនូវហានិភ័យដោយចែជន្យពីសំណាកប្រជាជនដោយបាន សម្រួលទៅលើផ្នែកហិរញ្ញវត្ថុហើយដើម្បីនិរន្តរភាពប្រតិបត្តការរបស់ក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ ដើម្បីចូលរួមលើកកម្ពស់ជីវភាពប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជាអោយកាន់តែប្រសើរឡើង។

## ៣.២. ប្រភេទនៃធានារ៉ាប់រងលើអគ្គីភ័យ

ក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ បានផ្តល់នូសេវាធានារ៉ាប់រងជាច្រើនប្រភេទជូនទៅតាមតម្រូវការរបស់អតិថិជនដែលក្នុងនោះសេវាធានារ៉ាប់រងលើអគ្គីភ័យ គឺជាប្រភេទសេវាធានារ៉ាប់រងមួយដែលសំខាន់ក្នុងការរួមចំណែកប្រាក់ចំណូលឬបុព្វលាភដល់ក្រុមហ៊ុន។ សេវាធានារ៉ាប់រងលើអគ្គីភ័យត្រូវបានបែងចែកជាពីរប្រភេទរួមមានដូចជាៈធានារ៉ាប់រងលើអគ្គីភ័យផ្ទាល់ខ្លួន និងធានារ៉ាប់រងលើអគ្គីភ័យសំរាប់អាជីវកម្ម ។

### ៣.២.១. ធានារ៉ាប់រងលើអគ្គីភ័យផ្ទាល់ខ្លួន (Fire Domestic)

ធានារ៉ាប់រងលើអគ្គីភ័យផ្ទាល់ខ្លួន (Fire Domestic) គឺជាប្រភេទធានារ៉ាប់រងដែលធានាទៅលើសំណង់អគារក្នុងការប្រើប្រាស់ជាលក្ខណៈផ្ទាល់ខ្លួនសម្រាប់ស្នាក់នៅនិងមិនបានស្វែង រកប្រាក់ចំណូលនៅក្នុងអគារ។

### ៣.២.២. ធានារ៉ាប់រងលើអគ្គីភ័យសំរាប់អាជីវកម្ម (Fire Commercial )

ធានារ៉ាប់រងលើអគ្គីភ័យសំរាប់អាជីវកម្ម (Fire Commercial ) គឺជាប្រភេទធានារ៉ាប់រងដែលធានាលើការប្រើប្រាស់សំណង់អគារឬទ្រព្យផ្សេងៗសម្រាប់ធ្វើអាជីវកម្មដែលស្វែងរកប្រាក់ចំណេញគ្រប់ប្រភេទ។

ជាឧទាហរណ៍ ៖ ការប្រើប្រាស់សំណង់អគារឬទ្រព្យក្នុងគោលបំណងដូចជា ហាងកាហ្វេ រោងចក្រសណ្ឋាគារ ភោជនីយដ្ឋាន ហាងកាត់សក់ ផ្សារជាដើម.....។

## ៣.៣. នីតិវិធីនៃការផ្តល់សេវាកម្មធានារ៉ាប់រងលើអគ្គីភ័យ

### ៣.៣.១ ពត៌មានបឋម




*រូបទី៤ ដំណើរការរបស់ផលិតផលធានារ៉ាប់រងអគ្គីភ័យ*

ដើម្បីអាចមានសិទ្ធក្នុងការទិញធានារ៉ាប់រងលើអគ្គីភ័យ នៅក្នុងក្រុមហ៊ុនធានារ៉ាប់រងហ្វតតេបានក្រុមហ៊ុនតម្រូវអោយអតិថិជនបំពេញបែបបទក្រុមហ៊ុនដើម្បីបង្ហាញពីភស្តុតាងអោយឃើញនូវលក្ខណៈស្របច្បាប់ដែលបានផ្តល់និងបង្ហាញពី អត្តសញ្ញាណរបស់ខ្លួនជាមុនសិន និង ត្រូវប្រាកដថាគ្រប់ពត៌មានដែលផ្តល់ក្រុមហ៊ុនពិតប្រាកដគ្មានការខ្លែងបន្លំឬលាក់បាំងពត៌មាននោះទេ។ ក្រុមហ៊ុនធានារ៉ាប់រង ហ្វតតេ មាននីតិវិធីនិងលក្ខខណ្ឌក្នុងការផ្តល់សេវាកម្មធានារ៉ាប់រងលើអគ្គីភ័យដល់អតិថិជនដូច ដែលបានរៀបរាប់ខាងក្រោម ៖

- ដំណាក់កាលទី១ ព័ត៌មានបឋម

១. ឈ្មោះអ្នកដែលត្រូវបានធានា

២. ការប្រើប្រាស់អគារ

៣. ប្រភេទនៃសំណង់អគារ( ថ្មសុទ្ធ class ១, ថ្មលាយឈើ class ២, ឈើសុទ្ធ class ៣)

៤. ទឹកប្រាក់ធានារ៉ាប់រង (ដោយរាយទៅតាមប្រភេទនៃទ្រព្យដែលដាក់ធានា)

៥. អាស័យដ្ឋាននៃទ្រព្យដែលដាក់ធានា

៦. ប្រវត្តិធានារ៉ាប់រង និង បទពិសោធន៍ទាមទារសំណង

៧. ព័ត៌មានអំពីអគារនិងស្ថានភាពជុំវិញទ្រព្យដែលដាក់ធានា

៨. ទំរង់បែបបទសុំទិញធានារ៉ារងលើអគ្គីភ័យ

៩. អត្តសញ្ញាណបណ្ណ័ថតចំម្លង

១០. លិខិតផ្ទេរសិទ្ធថតចម្លង

១១. រូបថតអគារ

- ដំណាក់កាលទី២ ការវាយតម្លៃ

ក្រុមហ៊ុនធ្វើការវាយតម្លៃទៅលើតម្រូវការរបស់អតិថិជនជាមួយនិងស្ថានភាពជាក់ស្តែងទៅតាម ទ្រព្យដែលត្រូវបានដាក់ធានារបស់អតិថិជន។

- ដំណាក់កាលទី៣ ការសម្រេចចិត្ត

ក្រោយពីការផ្តល់ព័ត៌មាន និង ធ្វើការវាយតម្លៃរួចមកក្រុមហ៊ុនធានារ៉ាប់រងនិងធ្វើការពិភាក្សាគ្នាថាតើតម្រូវការធានារ៉ាប់រងរបស់អតិថិជនមានកម្រិតណា គួរសម្រេចចិត្តផ្តល់ធានារ៉ាប់រងទៅដល់អតិជនឬអត់ ហើយតម្លៃប៉ុន្មានដើម្បីឲ្យសមស្របនិងការវាយតម្លៃនិងការធានា។

- ដំណាក់កាលទី៤ ផ្តល់ការធានានិងបញ្ជាក់ពីតម្លៃបុព្វលាភ

បន្ទាប់ពីធ្វើការសម្រេចចិត្តថាគួរ ផ្តល់ការធានាឬមិនផ្តល់ការធានាអោយនោះ បុគ្គលិកដែលពាក់ពន្ធ័និងធ្វើការជូនដំណឹងភ្លាមៗ។ ប្រសិនបើក្រុមហ៊ុនធានារ៉ាប់រងសម្រេចចិត្តថានិងផ្តល់ធានារ៉ាប់រងហើយនោះ បុគ្គលិកដែលពាក់ពន្ធ័និងបញ្ជាក់ពីតម្លៃបុព្វលាភ និងរៀបចំឯកសារផ្សេងៗទៅតាមដំណាក់កាលនីមួយ។

ចំពោះទម្រង់បែបបទដែលត្រូវបានចេញជូនចំពោះអតិថិជនមានទម្រង់ដូចជា ៖

១. លេខបណ្ណ័ (Policy no.)

២. ឈ្មោះអ្នកដែលត្រូវបានធានា ( Insured )

៣. អាសយដ្ឋាន ( Address )

៤. មុខរបររបស់អ្នកត្រូវបានធានា ( Business)

៥. រយៈពេលដែលត្រូវបានធានា ( Period of insurance )

៦. អាសយដ្ឋាននៃទ្រព្យដែលដាក់ធានា ( Situation of risk )

៧. ប្រភេទអជីវកម្ម( Occupation of the building )

៨. ប្រភេទសំណង់អគារ (Construction class )

៩. លេខសំគាល់ ( Code )

១០. តម្លៃជាភាគរយ ( Basic rate )

១១. តម្លៃភាគរយនៃហានិភ័យបន្ថែម ( Additional peril )

១២. ពត៌មានអំពីទ្រព្យដែលបានដាក់ធានា( Interest insured )

១៣. ទំនួលខុសត្រូវរបស់អតិថិជន ( Deductible )

១៤. តម្លៃបុព្វលាភ និងហត្ថលេខា ( Premium And Signature )

### ៣.៣.២. ហានិភ័យជាមូលដ្ឋានដែលត្រូវបានធានា

ដូចដែលយើងបានឃើញហើយថាហានិភ័យកើតឡើងដោយសារ អគ្គីភ័យ អាចកើតឡើងគ្រប់ពេលវេលាគ្រប់ទីកន្លែង នឹងជារៀងរាល់ឆ្នាំហេតុនេះហើយទើប ផលិតផលធានារ៉ាប់រងអគ្គីភ័យមានហានិភ័យមូលដ្ឋានដែលធ្វើការធានាចំពោះអតិថិជនជា ៣៖

- អគ្គីភ័យ : ចំពោះចំណុចអគ្គីភ័យនេះមិនថាការឆាបឆេះដោយការដុតទៀនធូបចោល ការផ្ទុះសេខ្សែភ្លើងនិងការឆេះរាលដាលពីអ្នកជិតខាង ក្រុមហ៊ុននឹងទទួលខុសត្រូវចំពោះការខូចខាតលំនៅដ្ឋានរបស់អ្នកដែលបានទិញផលិតផលមួយនេះទៅតាមកិច្ចសន្យាដែលបានចែងនៅក្នុងបណ្ណ័កិច្ចសន្យា។
- រន្ទះ : ចំពោះការកើតឡើងដោយគ្រោះធម្មជាតិដោយសាររន្ទះអាចនឹងកើតឡើងគ្រប់ពេលវេលាដូច្នេះហើយហានិភ័យដោយរន្ទះក្រុមហ៊ុន នឹងធ្វើការទទួលខុសត្រូវចំពោះការខូចខាតលំនៅដ្ឋានរបស់អ្នកដែលបានទិញ ផលិតផលមួយនេះទៅតាមកិច្ចសន្យាដែលបានចែងនៅក្នុងបណ្ណ័កិច្ចសន្យា។
- ការផ្ទុះ : ដោយសារតែបច្ចេកវិទ្យានាពេលបច្ចុប្បន្នមានភាពរីកចម្រើនយ៉ាងខ្លាំងក្លា ដូច្នេះហើយការប្រើប្រាស់ សម្ភារៈទំនើបៗក៏មានការកើនឡើងដូចគ្នា បើសិនណាមានហានិភ័យណាមួយដែលបណ្តាលមកពីការចំអិនអាហារប្រចាំថ្ងៃក្រុមហ៊ុននឹងទទួលខុសត្រូវចំពោះ ការខូចខាតលំនៅដ្ឋានរបស់អ្នកដែលបានទិញផលិតផលមួយនេះទៅតាម កិច្ចសន្យាដែលបានចែងនៅក្នុងបណ្ណ័កិច្ចសន្យា។

លើសពីនេះទៅទៀត អតិថិជនដែលបានទិញធានារ៉ាប់រងលើអគ្គីភ័យ អាចនិងធ្វើការធានាក្រៅពីសំណង់អគារដែលមានដូចជា ៖ សម្ភារៈការិយាល័យ ឧបករណ៍ប្រើប្រាស់ក្នុងការធ្វើជំនួញ សម្ភារៈក្នុងផ្ទះរាប់បញ្ចូលទាំងសំភារៈផ្ទាល់ខ្លួន (ប៉ុន្តែមិនរាប់បញ្ចូល គ្រឿងអលង្ការផ្សេងៗ) ម៉ាស៊ីនភ្លើង គ្រឿងសង្ហារឹម ឧបករណ៍ប្រើប្រាស់ ក្នុងការធ្វើជំនួញនិងម៉ាស៊ីនដែលអាចធ្វើការរុញចុះឡើងបានការធានាទៅលើស្តុកនៃវត្ថុធាតុដើមផលិតផលមិនទាន់សម្រេចនិងផលិតផលសម្រេច និងផ្សេងៗទៀតទៅតាមតម្រូវការរបស់អតិថិជន។

### ៣.៣.៣. អត្រាបុព្វលាភហានិភ័យបន្ថែម

- ការខូចខាតដោយយន្តហោះ ( Aircraft )

ក្រុមហ៊ុនមានការធានាបន្ថែមលើការខូចខាតទ្រព្យសម្បត្តិដែលបានធានាដែលបណ្តាលមកពី យន្តហោះ ឬឧបករណ៍ផ្លូវអាកាសផ្សេងៗដែលបានធ្លាក់មកប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់អតិថិជន។ប៉ុន្តែក្រុមហ៊ុនមិនធានាចំពោះករណីណាមួយដែលម្ចាស់ទ្រព្យសម្បត្តិអនុញ្ញាតឲ្យមានការចុះចត របស់យន្តហោះនោះឡើយ។

- ការខូចខាតដោយរញ្ជួយផែនដី និង ការផ្ទុះភ្នំភ្លើង (Earthquake )

ក្រុមហ៊ុនហ្វតេធានាចំពោះទ្រព្យសម្បត្តិដែលត្រូវបានខូចខាតដោយអគ្គីភ័យផ្ទាល់ ឬ តាមរយៈការរញ្ជួយផែនដី និង ការផ្ទុះភ្នំភ្លើងផងដែរ។

- ការខូចខាតដោយការផ្ទុះ ( Explosion )

អតិថិជន និង ត្រូវបានធានាដោយសារអគ្គីភ័យផ្ទាល់ឬការផ្ទុះផ្សេងៗប៉ុន្តែមិនរាប់បញ្ចូលការខាតបង់ទ្បើងដោយចំហ៊ុយ ម៉ាស៊ីន និងប្រដាប់ផ្ទុកវត្ថុរាវផ្សេងៗ នោះទេ។ ប៉ុន្តែយើងមិនធានាចំពោះការផ្ទុះដោយករណីភេរវកម្មណាមួយឡើយ។

- ការខូចខាតដោយទឹកជំនន់ ( Flood )

ចំពោះករណីនេះក្រុមហ៊ុនធ្វើការធានាចំពោះអគារ ដែលបានធានាត្រូវរងការខូចខាតដោយ សារតែទឹកជំនន់ដោយធម្មជាតិក្តីឬសប្បនិមិត្តក្តី។តែមិនធានាចំពោះការបាក់ស្រុតដីនោះទេ។

- ការខូចខាតដោយការធ្លាក់ដំព្រុល ( Hail )

ក្រុមហ៊ុន នឹងធានាលើការខូចខាតដោយការធ្លាក់ដុំព្រុលប្រសិនបើអតិថិជនបានទិញ កញ្ចប់ធានារ៉ាប់រងដោយមានការបន្ថែមចំពោះករណីនេះ។

- ការខូចខាតដោយព្យុះ Hurricane, Cyclone, Typhoon Windstorm

ក្រុមហ៊ុននឹង ធានាលើការខូចខាតដោយព្យុះ ប្រសិនបើអតិថិជនបានទិញកញ្ចប់ធានារ៉ាប់រងដោយមានការបន្ថែមចំពោះករណីខូចខាតដោយព្យុះ។ ប៉ុន្តែការធានានេះគឺធានាតែទ្រព្យសម្បត្តិនៅក្នុងអាគារដែលដែលបានខូចខាតដោយសារមាន ទឹកហូរចូល ដោយសារការរបើកដំបូល ឬ ជញ្ជាំងអាគារដែលបានធានាតែប៉ុណ្ណោះ។

- ការខូចខាតដោយរងផលប៉ះពាល់ (Impact Damage)

ចំណុចនេះសំដៅទៅលើ ករណីដែលទ្រព្យសម្បត្តិដែលបានធានាត្រូវរងការខូចខាតដោយសារយាន្តយន្តចរាចរណ៍ផ្លូវគោករួមទាំងសត្វពាហនៈផងដែរ។

- ការខូចខាតដោយបាតុកម្ម និងកូដកម្ម (Riot & Strike)

ចំនុចនេះក្រុមហ៊ុនមានការធានាចំពោះការខូចខាតទ្រព្យសម្បត្តិ ដោយសារសកម្មភាពរបស់ពួកក្រុមបាតុករ ឬ ក្រុមកូដករ ដែលពួកគេធ្វើសកម្មភាពរបស់ពួកគេក្នុងគោលបំណងប្រឆាំងនឹងការមិនចូលធ្វើការនិងការបង្ករដោយក្រុមបាតុករ ឬ ក្រុមកូដកររបស់ក្រុមអជ្ញាធរស្របច្បាប់។ ក្រុមហ៊ុមមិនធ្វើការធានាចំពោះ ការបាត់បងប្រាក់ចំណូល ការពន្យាពេល ការបាត់បង់ទីផ្សារ នោះទេ។

- ការខូចខាតដោយផ្សែង (Smoke)

ការខូចខាតដោយផ្សែងសំដៅទៅលើ ការខាតបង់ទ្រព្យសម្បត្តិដែលបណ្តាលមកពីអគ្គីភ័យកើតឡើងនៅក្នុងបរិវេណឬនៅទីជិតខាងបរិវេណជិតខាងបរិវេណដែលហានិភ័យត្រូវបានធានា។

- ការខូចខាតដោយការឆេះដោយឯកឯង ( Spontaneous Combustion )

ចំពោះហានិភ័យបន្ថែមនៃការខូចខាតដោយការឆេះដោយឯកឯងនេះ បណ្តាលមកពីការងំបន្តិចម្តងៗនៃការកើនឡើងកំដៅដែលបណ្តាលអោយមានអគ្គីភ័យឆាបឆេះកើតមានឡើង។

- ការខូចខាតដោយការស្រុតនិងបាក់ដី ( Subsidence & Landslip )

ចំពោះហានិភ័យបន្ថែមនៃការខូចខាតដោយការបាក់ស្រុតដីនិង ការបាក់ដីភាគច្រើនអាចកើតឡើងចំពោះអគារដែលនៅក្បែរច្រាំងទន្លេឬការរៀបចំប្លង់ឬគ្រឹះមិនបានល្អ។

- ការខូចខាតដោយអ្នកព្យាបាទ និងអ្នកបំផ្លាញ ( Vandalism & Malicious Damage )

ក្រុមហ៊ុននឹងធានាលើទ្រព្យសម្បត្តិដែលដាក់ធានាដែលខូចខាតបណ្តាលមកពី ការព្យាបាទបំផ្លិចបំផ្លាញដោយបុគ្គលណាម្នាក់ដោយចេតនា ឬអចេតនា។តែមិនរាប់បញ្ចូលសង្គ្រាម កុប្បកម្ម ឬសកម្មភាពភេរវកម្មណាមួយឡើយ។

- ការខូចខាតដោយទឹក ( Water Damage)

ក្រុមហ៊ុននឹងធានាបន្ថែមចំពោះករណីមានការផ្ទុះបែកអាងទឹក ទុយោទឹក ឬ ការបែកឧបករណ៍ពន្លត់អគ្គីភ័យស្វ័យប្រវត្តិ។តែបើករណីដែលក្រុមហ៊ុនដឹងថា អតិថិជនដឹងថាវាខូចហើយតែមិនជុសជុលទេនោះក្រុមហ៊ុនមិនធ្វើការធានាទេ។

### ៣.៣.៤. សម្ភារៈពន្លត់អគ្គីភ័យ

អត្រាបញ្ចុះតម្លៃធានារ៉ាប់រងសំរាប់បម្រើបម្រាស់ឧបករណ៍ពន្លត់អគ្គីភ័យ ដើម្បីទទួលបាននូវអត្រាបញ្ចុះតម្លៃ សម្រាប់ សេវាកម្មធានារ៉ាប់រងលើអគ្គីភ័យអតិថិជនត្រូវតែមាននូវ ឧបករណ៍ពន្លត់អគ្គីភ័យដែលត្រូវទៅតាមស្តង់ដារនិងប្រភេទផ្សេងនិងត្រូវមានការថែទាំល្អនិងការត្រួតពិនិត្យជាប្រចាំផងដែរ ។ ឧបករណ៍មួយចំនួនដូចដែលបានរៀបរាប់ខាងក្រោម៖

- ប្រព័ន្ធផ្តល់សញ្ញានិងតាមដានសញ្ញាអគ្គីភ័យដោយស្វ័យប្រវត្តិ
- ផែនទុយោបាញ់ទឹកក្នុងអគារ
- ឡានទឹកពន្លត់អគ្គីភ័យ
- បំពង់ពន្លត់អគ្គីភ័យនិងក្បាលម៉ាស៊ីនទឹកក្នុងអគារ

**៣.៣.៤ .១ ឧបករណ៍ពន្លត់អគ្គីភ័យ ( Portable Extinguishers)**

អ្នកត្រូវបានធានាអះអាងថាក្នុងកំឡុងពេលនៃសុពលភាពរបស់បណ្ណសន្យារ៉ាប់រងនេះ បញ្ញត្តិដែលបានចែងក្នុងលក្ខខណ្ឌតម្រូវជាទូទៅនិងលក្ខខណ្ឌតម្រូវឲ្យមានការថែទាំនិង ត្រូវអនុវត្តតាមដូចមានចែងខាងក្រោមៈ

- ត្រូវបំពាក់បំពង់អគ្គីភ័យចល័តឲ្យបានតាមច្បាប់មូលដ្ឋានស្តីពីអគារឬស្តង់ដាឬ វិធានពាក់ព័ន្ធដទៃផ្សេងទៀតស្តីពីការបំពាក់បំពង់ពន្លត់អគ្គីភ័យចល័ត។
- ត្រូវតែថែរក្សាបំពង់ពន្លតអគ្គីភ័យចល័តអោយមានបរិមាណសមស្រប នឹង អាចប្រើប្រាស់បានហើយត្រូវទុកនៅកន្លែងដែលបានកំណត់នៅពេលដែលមិនមាន ការប្រើប្រាស់។
- មិនត្រូវដាក់បំពង់ពន្លត់អគ្គីភ័យនៅទីកំបាំងពីការមើលឃើញនោះទេ។ ប្រសិនបើមិនអាចជៀសផុតពីទីកំបាំងទេត្រូវប្រើសញ្ញាបង្ហាញទៅកាន់ទីតាំងដែលមានបំពង់នេះ។
- អាចបំពាក់បំពង់ពន្លត់អគ្គីភ័យដែលអាចយួរបានត្រូវព្យួរបំពង់ពន្លត់អគ្គីភ័យចល័តទៅនឹង ប្រដាប់ព្យួរ ឬកែងទ្រដែលដាក់ក្នុងទូរ ហើយទូមិនត្រូវចាក់សោទេ និងកន្លែងដែលងាយយកមកប្រើប្រាស់។

- **លក្ខខណ្ឌតម្រូវឲ្យមានការថែទាំ**

  – ត្រូវតែមានការត្រួតពិនិត្យ បំពង់អគ្គីភ័យចល័តជាប្រចាំសប្តាហ៍ដើម្បីធានាបានថាបានអនុវត្តតាមលក្ខខណ្ឌតម្រូវទូទៅចំពោះបំពង់នេះ។

  – ត្រូវតែមានសេវាថែទាំបំពង់ពន្លត់អគ្គីភ័យចល័តយ៉ាងហោចមួយឆ្នាំម្តង។

  – ត្រូវតែរក្សាទុកកំណត់ហេតុស្តីពីការសាកល្បង ការត្រួតពិនិត្យដែលបានធ្វើឡើងកំហុសដែលបានរកឃើញ និងសេចក្តីលំអិតនៃការផ្លាស់ប្តូរគ្រឿងផ្សេងៗ។

**៣.៣.៤.២. ផែនទុយោបាញ់ទឹកក្នុងអគារ( Hose Reels Or Internal Hydrants)**

អ្នកត្រូវធានាអះអាងថាក្នុងកំឡុងពេលនៃសុពលភាពរបស់បណ្ណសន្យារ៉ាប់រងនេះ បញ្ញតិដែលចែងនៅក្នុងលក្ខខណ្ឌតម្រូវទូទៅនិង លក្ខខណ្ឌតម្រូវឲ្យមានការថែទាំត្រូវអនុវត្តតាមដូចតទៅៈ

- ត្រូវបំពាក់ផែនទុយោទឹក ឬ ក្បាលម៉ាស៊ីនទឹកខាងក្នុងអាគារនៅក្នុងទីតាំងដែលអាច យកមកប្រើបានងាយស្រួលនៅគ្រប់ជាន់នីមួយៗ ដោយមិនមានផ្ទៃកណាមួយមានចំងាយលើសពី៦ម៉ែត្រគិតពីក្បាលទុយោទឹក នៅពេលដែលទុយោទឹកលាតសន្ធឹងពេញលេញ។
- ទុយោទឹកសម្រាប់ក្បាលម៉ាស៊ីនខាងក្នុងអគារត្រូវផលិតពីកៅស៊ូ។ ទុយោទឹកត្រូវមានអង្កត់ផ្ចិតមិនតូចជាង១៩.០៥មីលីម៉ែត្រ និងមិនធំជាង៣១៧.៥មីលីម៉ែត្រ និងមិនអាចមានប្រវែងលើសពី៤៥ម៉ែត្រទេ។

- ត្រូវភ្ជាប់ផែនទុយោទឹកឬក្បាលម៉ាស៊ីនទឹកខាងក្នុងអាគារជាមួយប្រភពទឹកជានិច្ច។
- ប្រសិនបើប្រើផែនទុយោទឹកភ្ជាប់ជាមួយនឹងធុងទឹកមួយ ធុងនោះត្រូវមានទឹកពេញជាប្រចាំ ហើយត្រូវមានចំណុះអប្បបរិមា៣,៦០០លីត្រ។
- ត្រូវដាក់ម៉ាស៊ីនបូមទឹកនីមួយៗនៅកន្លែងដែលងាយយកមកប្រើ និងមិនខូចខាតដោយអគ្គីភ័យ។
- ត្រូវតែមានប្រេងឥន្ធនៈ ឲ្យបានគ្រប់គ្រាន់ជាប្រចាំដើម្បីដំណើរការម៉ាស៊ីនបូមទឹកសម្រាប់រយៈពេលមិនតិចជាង ៤ម៉ោង និងថាមពលត្រូវតែមានជានិច្ចសម្រាប់ម៉ាស៊ីនបូមទឹកដែលនៅតាមកន្លែង។

- **លក្ខខណ្ឌតម្រូវឲ្យមានការថែទាំ**

- ត្រូវត្រួតពិនិត្យផែនទុយោបាញ់ឬក្បាលម៉ាស៊ីនទឹកខាងក្នុងអាគារដើម្បីធានាបានថា ឧបករណ៍ទាំងនេះមិនមានបញ្ហា ហើយអាចយកមក ប្រើប្រាស់បានងាយស្រួលគ្រប់ពេលវេលា។
- ត្រូវតែធ្វើការសាកល្បងដំណើរការម៉ាស៊ីនបូមទឹកដោយស្វ័យប្រវត្តិ ឬ ដោយដៃ។ ម៉ាស៊ីន ទាំងនេះត្រូវតែដំណើរការបានតាមរយៈពេលដែលកំណត់មួយដែលអាចធានាដំណើរការក្នុងពេល ប្រតិបត្តិការ។ ក្នុងករណីម៉ាស៊ីនដែលប្រើម៉ាស៊ីនបូមនោះត្រូវតែដំណើរការអោយបានយ៉ាងតិច៥ នាទីនៅពេលធ្វើការសាក ល្បង។
- ត្រូវតែត្រួតពិនិត្យទៅលើ ឧបករណ៍ផ្គត់ផ្គង់ថាមពលអាគុយ និង ប្រដាប់សាកអាគុយដើម្បីធានាបានថាឧបករណ៍ទាំងនេះមានលក្ខណៈល្អ ហើយត្រូវតែថែមទឹកអាគុយតាមកម្រិត។
- ត្រូវធ្វើការសាកល្បងចរន្តទឹកដើម្បីធានាបានថាយ៉ាងហោចណាស់ទឹកមាន ល្បឿន២៤លីត្រក្នុងមួយនាទី។ ប្រសិនបើមិនមានលទ្ធភាពធ្វើការសាកល្បងគ្រប់ផែនទុយោឬក្បាលម៉ាស៊ីនទឹកខាងក្នុងនោះទេយ៉ាងហោចណាស់ត្រូវសាកល្បងផែនទុយោ និង ក្បាលម៉ាស៊ីនទឹកខាងក្នុងអគារដែលនៅឆ្ងាយបំផុតនៃប្រព័ន្ធទឹកសម្រាប់ពន្លត់អគ្គីភ័យនេះ។
- យោងលើការធានាអះអាងនេះ ការបញ្ចុះតម្លៃលើ អត្រាបុព្វលាភធានារ៉ាប់រងលើអគ្គីភ័យមូលដ្ឋានត្រូវបានអនុញ្ញាត។ប្រសិនបើលក្ខខណ្ឌនៃការធានាអះអាងនេះមិនត្រូវបានអនុវត្តនោះគ្មានការទទួលខុសត្រូវចំពោះបណ្ណសន្យារ៉ាប់រងនេះទេ។

**៣.៣.៤.៣. ក្បាលម៉ាស៊ីនទឹកក្នុងអគារ** (Sprinkler Installations)

អ្នកត្រូវអះអាងថាក្នុងកំឡុងពេលនៃសុពលភាពរបស់ប័ណ្ណសន្យារ៉ាប់រងនេះអ្នកត្រូវអនុវត្តតាមបញ្ញត្តិនិងលក្ខខណ្ឌដូចខាងក្រោម៖

- ត្រូវបំពាក់បំពង់បញ្ចោរទឹកប្រភេទមានទឹកនៅគ្រប់ជាន់នៃអគារចាប់ពីជាន់ទី១

- ត្រូវតែមានច្រកទឹកចូលដែលមានអង្កត់ផ្ចិតយ៉ាងតិច ១៥០ មីលីម៉ែត្រនិងត្រូវមានច្រកទឹកចេញត្រូវមាន អង្កត់ផ្ចិតយ៉ាងតិច ៦៣.៥ មីលីម៉ែត្រ។
- ត្រូវបំពាក់ម៉ាស៊ីនបូមទឹកនីមួយៗនៅទីតាំងាយស្រួលណាដែលមិនរងការខូចខាតដោយអគ្គីភ័យ និងដំណើរការដោយស្វ័យប្រវត្តិឬដំណើរការដោយនរណាម្នាក់។

- **លក្ខខណ្ឌឲ្យមានការថែទាំ**

– ត្រូវតែត្រួតពិនិត្យឧបករណ៍ផ្គតផ្គង់ថាមពល អាគុយ និងប្រដាប់បញ្ចូលអាគុយដើម្បីឲ្យធានាបានថាឧបករណ៍ទាំងនោះមានលក្ខខណៈល្អ។
– ត្រូវត្រួតពិនិត្យក្បាលរ៉ូប៊ីនេបំពង់បញ្ជាទឹកនិងសន្ទះបិទបើកដើម្បីធានាថា ឧបករណ៍មិនមានបញ្ហា
– ត្រូវត្រួតពិនិត្យមើលធុងទឹកដើម្បីឲ្យច្បាស់ថាទឹកស្អាតល្អនិងគ្មានកម្ទេចសំរាម

### ៣.៣.៤.៤. ប្រព័ន្ធផ្តល់សញ្ញានិងតាមដានសញ្ញាអគ្គីភ័យដោយស្វ័យប្រវត្តិ

ឧបករណ៍ផ្តល់សញ្ញាត្រូវភ្ជាប់ទៅនឹងកន្លែងត្រួតពិនិត្យអគ្គីភ័យកណ្តាល ត្រូវតែច្បាស់ថាឧបករណ៍នេះមិនមានការបិតបាំងឬការលាបថ្នាំពីខាងលើធ្វើឲ្យដំណើរការមិនបាន

- ត្រូវច្បាស់ថាឧបករណ៍ផ្តល់សញ្ញាត្រូវបានការពារពីការខូចខាតដែលបណ្តាលមកពីឥទ្ធិពលមេកានិច
- ត្រូវធ្វើការសាកល្បងជាប្រចាំខែនូវឧបករណ៍ផ្តល់សញ្ញាដើម្បីធានាថាឧបករណ៍មានដំណើរការធម្មតា
- ត្រូវថែរក្សាកំណត់ហេតុអំពីការសាកល្បង និង ការត្រួតពិនិត្យដែលមានកំហុសឆ្គងដែលបានរកឃើញ និងសេចក្តីលំអិតនៃការផ្លាស់ប្តូរ។

### ៣.៣.៥. តារាងអត្រាបុព្វលាភនិងចំណាត់ថ្នាក់ប្រភេទអាជីវកម្ម

តារាងអត្រាបុព្វលាភគឺជាតារាងដែលបានចេញដោយក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលត្រូវបានអនុញ្ញាតអោយប្រើប្រាស់ក្នុងវិស័យធានារ៉ាប់រងទូទៅ ទៅលើផលិតផលអគ្គីភ័យដែលមានការបែងចែកអំពីប្រភេទនៃអាជីវកម្ម កម្រិតភាគរយនៃតម្លៃទៅតាមសំណង់អគារ បើសំណង់អគារឬទ្រព្យសម្បត្តិនោះក្នុងចំណាត់ថ្នាក់ A បានន័យថាអគារនោះថ្មសុទ្ធ សំណង់អគារនោះក្នុងចំណាត់ថ្នាក់ B បានន័យថាអគារនោះថ្មលាយឈើសំណង់អគារនោះក្នុងចំណាត់ថ្នាក់ Cបានន័យថាអគារនោះ ឈើសុទ្ធ។ហើយលើសពីនេះទៅទៀតកម្រិតនៃការធានាមានតម្លៃត្រឹមតែ ដប់លានដុល្លារអាមេរិកតែប៉ុណ្ណោះក្រុមហ៊ុនត្រូវតែគោរពតាមតារាងនៃអត្រាបុព្វលាភខាងក្រោមនេះ។ បើក្នុងករណីតម្លៃនៃ ទ្រព្យសម្បត្តិ ឬ អគារលើសដប់លានដុល្លាអាមេរិកក្រុមហ៊ុនអាចធ្វើការចេញតម្លៃបុព្វលាភទៅអោយអតិថិជនដោយខ្លួនឯងបាន។

**Tariff Rate:**

| Category | Code | Occupation/Trade | Hazard | Class | | |
|---|---|---|---|---|---|---|
| | | | | A | B | C |
| **RESIDENTIAL PROPERTIES** | 10101 | Apartment/Condominium | Low | 0.116 | 0.160 | 0.239 |
| | 10102 | Dormitory Or Flat | Low | 0.116 | 0.160 | 0.239 |
| | 10103 | Dwelling House | Low | 0.123 | 0.168 | 0.253 |
| **COMMERCIAL SERVICE** | 11101 | Botanic And Zoological Garden | Low | 0.118 | 0.163 | 0.244 |
| | 11102 | Church | Low | 0.125 | 0.172 | 0.258 |
| | 11103 | Clinic / Dental Clinic | Low | 0.130 | 0.179 | 0.268 |
| | 11104 | College / School / University / Educational Facility | Low | 0.123 | 0.168 | 0.253 |
| | 11105 | Hospital / Animal Hospital | Low | 0.130 | 0.179 | 0.268 |
| | 11106 | Hotel | Low | 0.140 | 0.193 | 0.289 |
| | 11107 | Nursing Home | Low | 0.130 | 0.179 | 0.268 |
| | 11108 | Office | Low | 0.109 | 0.150 | 0.225 |
| | 11209 | Guest House | Medium | 0.214 | 0.294 | 0.442 |
| | 11210 | Science Laboratory | Medium | 0.236 | 0.324 | 0.486 |
| | 11211 | Temple | Medium | 0.228 | 0.314 | 0.471 |
| | 11212 | Crematorium | Medium | 0.264 | 0.363 | 0.545 |
| **RETAIL TRADING** | 12101 | Auction House | Low | 0.144 | 0.198 | 0.297 |
| | 12102 | Cellular Telephone Stores | Low | 0.160 | 0.220 | 0.330 |
| | 12103 | Flower Shop | Low | 0.134 | 0.184 | 0.277 |
| | 12104 | Fresh FISH & SEAFOOD DEALERS | Low | 0.130 | 0.179 | 0.268 |
| | 12105 | Jewelry Stores | Low | 0.153 | 0.210 | 0.315 |
| | 12106 | Market In Open Air | Low | 0.202 | 0.277 | 0.416 |
| | 12107 | Pawn Shop | Low | 0.138 | 0.189 | 0.284 |
| | 12108 | Pharmacy Or Drug Store | Low | 0.142 | 0.195 | 0.292 |
| | 12109 | Photo Shop | Low | 0.140 | 0.193 | 0.289 |
| | 12110 | Shoe Store | Low | 0.176 | 0.242 | 0.363 |
| | 12111 | Sporting Goods Store | Low | 0.171 | 0.235 | 0.352 |

| | | | | | | |
|---|---|---|---|---|---|---|
| | 12112 | Toy And Hobby Stores | Low | 0.162 | 0.222 | 0.333 |
| | 12213 | BOOKSTORE Or Stationary Stores | Medium | 0.267 | 0.367 | 0.550 |
| | 12214 | Bridal Store | Medium | 0.253 | 0.347 | 0.521 |
| | 12215 | Clothing Shop | Medium | 0.245 | 0.337 | 0.505 |
| | 12216 | Electrical Selling & Repairing / Electrical Appliance Repair Shop | Medium | 0.254 | 0.349 | 0.524 |
| | 12217 | Grocery Store/ Mini Mart | Medium | 0.243 | 0.335 | 0.502 |
| | 12218 | Hardware Store | Medium | 0.254 | 0.349 | 0.524 |
| | 12219 | Home Furniture Store | Medium | 0.283 | 0.390 | 0.584 |
| | 12220 | Laundry Or Dry Cleaning | Medium | 0.257 | 0.353 | 0.529 |
| | 12221 | Liquor Store | Medium | 0.271 | 0.372 | 0.559 |
| | 12222 | Market | Medium | 0.268 | 0.369 | 0.553 |
| | 12223 | Motor Vehicle Parts And/Or TYRE DEALERS | Medium | 0.263 | 0.362 | 0.543 |
| | 12224 | Retail Stores Not Other Specified | Medium | 0.251 | 0.345 | 0.517 |
| | 12225 | Silk Screen Shop | Medium | 0.252 | 0.346 | 0.519 |
| | 12226 | Supermarket / Department Store | Medium | 0.253 | 0.347 | 0.521 |
| | 12227 | Tailor | Medium | 0.258 | 0.355 | 0.533 |
| **FOOD AND BEVERAGE** | 13201 | Bakery Shop/Confectionary | Medium | 0.253 | 0.347 | 0.521 |
| | 13202 | Coffee Shop | Medium | 0.240 | 0.330 | 0.495 |
| | 13203 | Restaurant | Medium | 0.263 | 0.361 | 0.541 |
| **RECREATION SERVICE** | 14104 | Amusement Park (Outdoor) | Low | 0.155 | 0.213 | 0.319 |
| | 14105 | Barber Shop/Beauty Saloon | Low | 0.153 | 0.211 | 0.316 |
| | 14106 | Billiard Saloon | low | 0.155 | 0.213 | 0.319 |
| | 14107 | Bowling Hall | Low | 0.155 | 0.213 | 0.319 |
| | 14108 | Gymnasium | Low | 0.121 | 0.166 | 0.249 |
| | 14209 | Bath And Massage Parlour | Medium | 0.269 | 0.370 | 0.555 |
| | 14310 | Night Club/ Bar/ Karaoke | High | 0.340 | 0.468 | 0.701 |
| **CINEMAS, STUDIOS** | 15101 | TV Broadcasting Station | Low | 0.152 | 0.209 | 0.313 |
| **& EXHIBITION HALLS** | 15102 | Movie Film/Photo Graphic Studio/Sound Recording Studio | Low | 0.185 | 0.254 | 0.382 |
| | 15103 | Radio Broadcasting Station | Low | 0.152 | 0.209 | 0.313 |
| | 15204 | Cinema/Theatre | Medium | 0.278 | 0.383 | 0.574 |
| | 15205 | Exhibition Hall Or Showroom/Wedding Hall | Medium | 0.253 | 0.348 | 0.523 |
| **TRANSPORTATION** | 16201 | Air Transport Premises Including Hangar | Medium | 0.258 | 0.355 | 0.533 |
| | 16202 | Bus Terminal/Station | Medium | 0.252 | 0.346 | 0.519 |
| | 16203 | Piers, Wharves, Port, Jetty, Water Transport Premises | Medium | 0.245 | 0.337 | 0.505 |
| | 16204 | Railway Station | Medium | 0.251 | 0.345 | 0.517 |

| | | | | | | |
|---|---|---|---|---|---|---|
| **GENERAL STORAGE** | 17201 | WAREHOUSE KEEPING B) Non-Hazardous GOODS | Medium | 0.263 | 0.361 | 0.541 |
| | 17302 | Cold Storage | High | 0.355 | 0.488 | 0.732 |
| | 17303 | GOODS IN OPEN AIR A) Non-Hazardous Goods | High | 0.355 | 0.488 | 0.732 |
| | 17304 | GOODS IN OPEN AIR B) Hazardous Goods | High | 0.543 | 0.747 | 1.121 |
| | 17305 | WAREHOUSE KEEPING A) HAZARDOUS GOODS | High | 0.645 | 0.887 | 1.330 |
| **CONSTRUCTION** | 18101 | Unoccupied/Vacant Risk (Other Section) | low | 0.159 | 0.219 | 0.328 |
| | 18202 | Building In Course Of Construction (Full Value) | medium | 0.251 | 0.345 | 0.517 |
| | 18203 | Silent Industrial Risk (Remark) (Other Section) | medium | 0.258 | 0.355 | 0.533 |
| **FOOD PROCESSING INDUSTRIES** | 19101 | Egg Product/Preserved Egg | Low | 0.139 | 0.191 | 0.287 |
| | 19102 | Slaughter House & Bone Crushing Fty | Low | 0.164 | 0.226 | 0.339 |
| | 19203 | Animal Farm Not Otherwise Specified | Medium | 0.251 | 0.345 | 0.517 |
| | 19204 | Bakery/Biscuit Fty. | Medium | 0.264 | 0.363 | 0.545 |
| | 19205 | Bean Curd Fty | Medium | 0.246 | 0.338 | 0.507 |
| | 19206 | Chili/Flavouring Powder Fty Without Heating Process | Medium | 0.239 | 0.329 | 0.493 |
| | 19207 | Confectionary/Candy Fty. | Medium | 0.264 | 0.363 | 0.545 |
| | 19208 | Dry Fruit Preservation Without Heat Processing | Medium | 0.247 | 0.339 | 0.509 |
| | 19209 | Food Processing Not Otherwise Specified | Medium | 0.283 | 0.390 | 0.584 |
| | 19210 | Ice Product Fty. | Medium | 0.263 | 0.361 | 0.541 |
| | 19211 | Ice-Cream Fty | Medium | 0.263 | 0.361 | 0.541 |
| | 19212 | Meat And Seafood Processing | Medium | 0.246 | 0.338 | 0.507 |
| | 19213 | Noodle Fty | Medium | 0.257 | 0.353 | 0.529 |
| | 19214 | Pig Farm | Medium | 0.251 | 0.345 | 0.517 |
| | 19215 | Poultry Farm | Medium | 0.251 | 0.345 | 0.517 |
| | 19216 | Sauce And Pickle Fty | Medium | 0.252 | 0.346 | 0.519 |
| | 19317 | Animal Feed Meal | High | 0.367 | 0.504 | 0.756 |
| | 19318 | Chili/Flavouring Powder Fty With Heating Process | High | 0.363 | 0.498 | 0.748 |
| | 19319 | Cooking Oil Fty | High | 0.385 | 0.529 | 0.794 |
| | 19320 | Dry Fruit Preservation With Heat Processing | High | 0.353 | 0.485 | 0.727 |
| | 19321 | Peanut Mill Excluding Peanut Oil Production | High | 0.358 | 0.492 | 0.737 |
| **BEVERAGES PROCESSING** | 20101 | Non Alcohol Beverage / Drinking Water | Low | 0.162 | 0.222 | 0.333 |
| | 20202 | Brewery | Medium | 0.268 | 0.368 | 0.552 |
| | 20303 | Alcohol/Liquor/Wine | High | 0.421 | 0.579 | 0.868 |

| | | | | | | |
|---|---|---|---|---|---|---|
| **TOBACCO** | 21301 | Tobacco/CIGAR / CIGARETTE / Smoke House Fty. | High | 0.495 | 0.681 | 1.021 |
| **TEXTILES** | 22301 | Cotton Mill | High | 0.380 | 0.523 | 0.784 |
| | 22302 | Fabric Printing And Dyeing | High | 0.356 | 0.489 | 0.734 |
| | 22303 | Garment Factory | High | 0.372 | 0.511 | 0.767 |
| | 22304 | Knitting Mill | High | 0.380 | 0.523 | 0.784 |
| | 22305 | Silk Thread Fty | High | 0.343 | 0.472 | 0.708 |
| | 22306 | Silk Weaving | High | 0.343 | 0.472 | 0.708 |
| | 22307 | Textile Factory/Spinning Mill And Thread Maker | High | 0.387 | 0.532 | 0.798 |
| **LEATHER AND FIBRE PRODUCTS INDUSTRIES** | 23301 | Brush Manufacturing | High | 0.290 | 0.399 | 0.598 |
| | 23302 | Carpet Rug And Mat Fty | High | 0.450 | 0.619 | 0.928 |
| | 23303 | Leather Or Fiber Product Fty Not Otherwise Specified Excl Plastic | High | 0.388 | 0.534 | 0.801 |
| | 23304 | Leather Product Fty Including Boot, Shoes | High | 0.413 | 0.568 | 0.853 |
| | 23305 | Net Factory Excluding Plastic | High | 0.345 | 0.474 | 0.712 |
| | 23306 | Tannery Fty | High | 0.382 | 0.525 | 0.787 |
| **WOOD WORKING AND TIMBER** | 24301 | Plywood/Laminated Wood And The Likes Manufacturing | High | 0.770 | 1.059 | 1.588 |
| | 24302 | Saw Mill | High | 0.917 | 1.260 | 1.891 |
| | 24303 | Wood, Bamboo, Rattan Or Similar Natured Product Manufacturing | High | 0.595 | 0.818 | 1.227 |
| **PAPER AND PRINTING** | 25201 | News Paper, Magazine, Book Printing | Medium | 0.286 | 0.393 | 0.590 |
| | 25202 | Printing Not Otherwise Specified | Medium | 0.297 | 0.408 | 0.612 |
| | 25303 | Carton Paper/Box Manufacturing | High | 0.545 | 0.749 | 1.124 |
| | 25304 | Paper / Tissue Mfg With Recyling | High | 0.675 | 0.928 | 1.392 |
| | 25305 | Paper/Tissues Manufacturer Without Recycling | High | 0.588 | 0.808 | 1.212 |
| **CHEMICALS** | 26201 | Paint And Varnish Without Alcohol Or Oil | Medium | 0.278 | 0.382 | 0.572 |
| | 26202 | Toothpaste Fty. | Medium | 0.251 | 0.345 | 0.517 |
| | 26303 | Poly Foam Fty. | High | 0.525 | 0.722 | 1.083 |
| | 26304 | Candle Works | High | 0.607 | 0.834 | 1.251 |
| | 26305 | Chalk Fty. | High | 0.355 | 0.488 | 0.732 |
| | 26306 | Costmetic Factory | High | 0.371 | 0.510 | 0.765 |
| | 26307 | Detergent Factory | High | 0.370 | 0.509 | 0.763 |
| | 26308 | Dry Ice Fty. | High | 0.359 | 0.493 | 0.740 |
| | 26309 | Fertilizer Fty. | High | 0.445 | 0.612 | 0.918 |
| | 26310 | Glue Fty. | High | 0.520 | 0.715 | 1.073 |
| | 26311 | Ink And Color Fty. | High | 0.373 | 0.512 | 0.768 |

| | | | | | | |
|---|---|---|---|---|---|---|
| | 26312 | Joss Stick Work | High | 0.617 | 0.848 | 1.272 |
| | 26313 | Match Fty. | High | 0.620 | 0.853 | 1.279 |
| | 26314 | Mosquito Coil Fty. | High | 0.470 | 0.646 | 0.969 |
| | 26315 | Manufacturing Of Chemical Product Not Otherwise Specified | high | 0.470 | 0.646 | 0.969 |
| | 26316 | Paint And Varnish Otherwise | High | 0.692 | 0.951 | 1.427 |
| | 26317 | Pharmaceutical Fty. | High | 0.367 | 0.504 | 0.756 |
| | 26318 | Soap Fty. | High | 0.380 | 0.523 | 0.784 |
| **GAS, OIL AND PETROLEUM** | 27301 | Bio Energy Product | High | 0.448 | 0.615 | 0.923 |
| | 27302 | Lubricate Fyt | High | 0.432 | 0.594 | 0.890 |
| | 27303 | Oil And Gas Refinery On Shore | High | 0.670 | 0.921 | 1.382 |
| | 27304 | Oil And Oil Refinery Off Shore | High | 0.917 | 1.260 | 1.891 |
| | 27305 | Oil Storage Without Process | High | 0.492 | 0.676 | 1.014 |
| | 27306 | Palm Oil | High | 0.425 | 0.584 | 0.877 |
| | 27307 | Petro Station | High | 0.500 | 0.688 | 1.031 |
| **RUBBER** | 28201 | RUBBER SMOKE HOUSE (Without Heating And Drying) | Medium | 0.284 | 0.391 | 0.586 |
| | 28302 | Rubber Goods Mfg Not Otherwise Specified | High | 0.450 | 0.619 | 0.928 |
| | 28303 | RUBBER SMOKE HOUSE With Heating And Drying | High | 0.620 | 0.853 | 1.279 |
| | 28304 | Tyre Manufacturing Fty. | High | 0.546 | 0.751 | 1.126 |
| | 28305 | Tyre Retreading Fty. | High | 0.650 | 0.894 | 1.341 |
| **PLASTICS** | 29201 | Assembly Or Manufacture Of Plastic Goods From Ready Made Plastic Not Involving Plastic Resins Or Compounds Of Extrusion, Blowing Or Injection Moulding | Medium | 0.292 | 0.401 | 0.602 |
| | 29302 | Plastic Goods Manufacture Involving The Process Of Resins Or Compounds Of Extrusion, Blowing Or Injection Moulding | High | 0.508 | 0.699 | 1.048 |
| | 29303 | Plastic Recycling Plants | High | 0.502 | 0.690 | 1.035 |
| **NON-METALLIC MINERALS** | 30101 | Cement Plant | Low | 0.188 | 0.258 | 0.387 |
| | 30102 | Marble Workshop | Low | 0.170 | 0.234 | 0.351 |
| | 30103 | Precious And Semi-Precious Stones Work Shop | Low | 0.185 | 0.254 | 0.382 |
| | 30104 | Quarry | Low | 0.165 | 0.227 | 0.340 |
| | 30105 | Stone Workshop | Low | 0.170 | 0.234 | 0.351 |
| | 30206 | Brick And Baked Clay | Medium | 0.260 | 0.358 | 0.536 |
| | 30207 | Enamel Ware And Ceramic Manufacturing | Medium | 0.263 | 0.362 | 0.543 |
| | 30208 | Glass Cutting Workshop | Medium | 0.231 | 0.317 | 0.476 |
| | 30209 | Glass Product Manufacturing | Medium | 0.275 | 0.378 | 0.567 |

| | | | | | | |
|---|---|---|---|---|---|---|
| | 30210 | Manufacturing Of Non-Metallic Product Not Otherwise Specified | Medium | 0.252 | 0.346 | 0.519 |
| | 30211 | Mirror Fty | Medium | 0.247 | 0.339 | 0.509 |
| **METAL WORKING ;ENGINEERING** | 31201 | Aluminum Product Fty. | Medium | 0.257 | 0.353 | 0.529 |
| | 31202 | BATTERY OR DRYCELL Fty./Workshop | Medium | 0.258 | 0.354 | 0.531 |
| | 31203 | Bicycle Assembly Plants | Medium | 0.230 | 0.316 | 0.474 |
| | 31204 | Blacksmith Work | Medium | 0.280 | 0.385 | 0.578 |
| | 31205 | Cable And Wire Fty. | Medium | 0.268 | 0.368 | 0.552 |
| | 31206 | Electrical Product Manufacturing | Medium | 0.271 | 0.372 | 0.559 |
| | 31207 | Foundry And Smelting Work | Medium | 0.280 | 0.385 | 0.578 |
| | 31208 | Metal Product Mfg Not Otherwise Specified | Medium | 0.268 | 0.368 | 0.552 |
| | 31209 | Motor Vehicle Assembly | Medium | 0.240 | 0.330 | 0.495 |
| | 31210 | Motor Vehicle Manufacturing | Medium | 0.298 | 0.410 | 0.615 |
| | 31211 | Plant And Machinery Manufacturing | Medium | 0.272 | 0.374 | 0.560 |
| | 31212 | Ship Builder | Medium | 0.300 | 0.413 | 0.619 |
| | 31313 | Electronic Component And Semi-Conductor Manufacturing | High | 0.349 | 0.480 | 0.720 |
| **MOTOR TRADE AND RELATED RISKS** | 32101 | Vehicle Garage (Servicing And Car Washing) | Low | 0.177 | 0.243 | 0.364 |
| | 32202 | Vehicle Garage With Panel Repair Shop With Spraying | Medium | 0.287 | 0.394 | 0.591 |
| | 32203 | Vehicle Garage With Panel Repair Shop Without Spraying | Medium | 0.244 | 0.336 | 0.504 |
| | 32204 | Vehicle Showroom | Medium | 0.248 | 0.341 | 0.512 |
| **UTILITIES** | 33101 | Water Treatment Plants | low | 0.141 | 0.194 | 0.290 |
| | 33302 | Coal Power plant | High | 0.504 | 0.693 | 1.040 |
| | 33303 | Diesel Power plants | High | 0.475 | 0.653 | 0.980 |
| | 33304 | Electricity Or Tele-Communication Substation | High | 0.428 | 0.589 | 0.883 |
| | 33305 | Hydro Power | High | 0.455 | 0.626 | 0.938 |
| | 33306 | Power Plant Not Otherwise Specified | High | 0.470 | 0.646 | 0.969 |
| | 33307 | Waste And Garbage Disposal | High | 0.478 | 0.658 | 0.987 |
| **RICE AND FLOUR MILLS** | 34201 | RICE And Grain Mill Without Drying Process | Medium | 0.280 | 0.385 | 0.578 |
| | 34302 | Flour Mill | High | 0.411 | 0.565 | 0.847 |
| | 34303 | RICE And Grain Mill With Drying Process | High | 0.446 | 0.613 | 0.920 |
| **SUGAR AND SALT FACTORY** | 35101 | Salt Factory | Low | 0.165 | 0.227 | 0.340 |
| | 35302 | Sugar Factory | High | 0.433 | 0.596 | 0.894 |
| **COCOA, COFFEE & TEA FACTORIES** | 36303 | Coffee, Cocoa Bean And Tea Factory | High | 0.385 | 0.529 | 0.794 |

*រូបទី៥ អត្រាបុព្វលាភនិងចំណាត់ថ្នាក់ប្រភេទអជីវកម្ម*

ប្រភព ៖ General Tariff Rules, Fire & Business Interruption Insurance , Price Rating By Licenced General Insurers Operating In Cambodia

### ៣.៣.៦. កម្រិតមិនធ្វើសំណង

ជាមួយគ្នានេះដែរក្រុមហ៊ុនក៏មានកម្រិតនៃការលើកលែង ឬ ការមិនធានាក្នុងករណីដែលមានហានិភ័យទាបជាងតម្លៃដែលបានបង្ហាញ នៅក្នុងបណ្ណ័កិច្ចសន្យាទៅតាមប្រភេទសំណង់អគារនិងប្រភេទអាជីវកម្មនីមួយៗ។

| ចំណាត់ថ្នាក់ហានិភ័យ | ការខូចខាតដែលមិនបណ្ដាលមកពីគ្រោះមហន្តរាយ | ការខូចខាតបណ្ដាលមកពីគ្រោះមហន្តរាយ | ចំណាំ |
|---|---|---|---|
| កំរិតទាប | ៥០០ ដុល្លារអាមេរិក សម្រាប់ការខូចខាតនីមួយៗ | ៥%នៃតម្លៃខូចខាត ប៉ុន្តែចំនួនអប្បបរមា ១,០០០ដុល្លារអាមេរិក សម្រាប់ការខូចខាតនីមួយៗ | សំរាប់គេហដ្ឋាន និងការិយាល័យ ដែលទឹកប្រាក់ធានារ៉ាប់រងទាបជាង ៥០០,០០០ ដុល្លាអាមេរិក |
| | ១,០០០ ដុល្លារអាមេរិក សម្រាប់ការខូចខាតនីមួយៗ | ៥%នៃតម្លៃខូចខាត ប៉ុន្តែចំនួនអប្បបរមា ៥,០០០ដុល្លារអាមេរិក សម្រាប់ការខូចខាតនីមួយៗ | |
| កំរិតមធ្យម | ២,០០០ដុល្លារអាមេរិក ឬ ២.៥% នៃតម្លៃខូចខាត ដោយយកតម្លៃមួយណាដែលច្រើនជាង សម្រាប់ការខូចខាតនីមួយៗ | | |
| កំរិតខ្ពស់ | ៣,០០០ដុល្លារអាមេរិក ឬ ៥% នៃតម្លៃខូចខាត ដោយយកតម្លៃមួយណាដែលច្រើនជាង សម្រាប់ការខូចខាតនីមួយៗ | | |

*តារាងទី៧ តារាងកម្រិតនៃការមិនធ្វើសំណង*

ប្រភព ៖ General Tariff Rules, Fire & Business Interruption Insurance , Price Rating By Licenced General Insurers Operating In Cambodia

### ៣.៣.៧. ដំណើរការនៃការទាមទារសំណង

ដំបូងនៅពេលដែលមានអគ្គីភ័យកើតឡើង អ្នកដែលត្រូវបានធានាត្រូវទាក់ទងទៅក្រុមពន្លត់ អគ្គីភ័យ ឡានទឹកឬសមត្ថកិច្ចជាដើមដើម្បីជួយធ្វើការពន្លត់អគ្គីភ័យតាមដែលអាចធ្វើទៅបាន។ បន្ទាប់មកអ្នកត្រូវបាន ធានាត្រូវផ្តល់ដំណឹងដល់ក្រុមហ៊ុនធានារ៉ាប់រងភ្លាមៗដើម្បីអោយក្រុមធានារ៉ាប់រងដឹងអំពីហេតុការណ៍អគ្គីភ័យ ដែលបានកើតឡើងដោយទំនាក់ទំនងតាមរយៈលេខទូរស័ព្ទ ០២៣ ៨៨០ ០៨០ ដែលធ្វើការបំរើអតិថិជន២៤ ម៉ោង។ក្រោយពេលអតិថិជនធ្វើការផ្តល់ដំណឹងទៅកាន់ក្រុមហ៊ុនធានារ៉ាប់រង រួចរាល់ហើយក្រុមហ៊ុនធានារ៉ាប់ រងហ្វតតេ បញ្ជូនក្រុមជំនាញ ( Independent International  Loss Adjusters) ដល់ទីកន្លែងផ្ទាល់ដើម្បីធ្វើ ការសិក្សាស្រាវជ្រាវពីហេតុការណ៍ និង ធ្វើការវាស់វែងដើម្បីដឹងពីប្រភពបញ្ហានិងធ្វើការវាយតម្លៃដើម្បីផ្តល់ជា សំណងទៅកាន់អតិថិជន។ អតិថិជនត្រូវធ្វើការសហការជាមួយក្រុមការងាររបស់ក្រុមហ៊ុនដើម្បីផ្តល់ជាភាព ងាយស្រួលដល់ក្រុមហ៊ុននិងឆាប់បានទទួលការដោះស្រាយសំណង។

នៅពេលមានការខាតបង់ ឬ ការខូចខាតកើតឡើងអ្នកដែលបានត្រូវបានធានាត្រូវផ្តល់ដំណឹងទៅ កាន់ក្រុមហ៊ុនធានារ៉ាប់រងទៅតាមដំណាក់កាលដូចខាងក្រោម៖

- ចាត់វិធានការដើម្បីកាត់បន្ថយការខាតបង់ឬការខូចខាតឱ្យដល់កម្រិតអប្បបរិមា។
- ជូនដំណឹងជាលាយលក្ខណ៍អក្សរជូនទៅដល់ក្រុមហ៊ុន
  ក្នុងរយៈពេល១៥ថ្ងៃបន្ទាប់ពីមានការខូចខាតឬយូរជាងនេះដែលយើងអនុញ្ញាតឱ្យផ្តល់ដល់យើងនូវ ៖
- ពាក្យទាមទារសំណងជាលាយលក្ខណ៍អក្សរចំពោះការខាតបង់ ឬការខូចខាតដោយមិនរាប់បញ្ចូល នូវប្រាក់ចំណេញគ្រប់ប្រភេទ។
- ចំនុចពិសេសរបស់ការធានារ៉ាប់រងដទៃផ្សេងទៀតទាំងអស់ប្រសិនបើមាន។
- ប្លង់ លក្ខណៈសំគាល់វត្ថុ វិក័យប័ត្រ ប័ណ្ណទូទាត់ លិខិតចំលងឬឯកសារថតចម្លងអំពីការចំណាយ
- ឯកសារភស្តុតាងនិងព័ត៌មានដែលទាក់ទងនឹងបណ្តឹងទាមទារសំណង
- ពាក្យសម្បថ (declaration of oath) ឬ លិខិតផ្លូវច្បាប់ផ្សេងទៀតដែលបញ្ជាក់អំពីការពិតនៃបណ្តឹង ទាមទារសំណងនិងបញ្ហា ផ្សេងទៀតដែលទាក់ទងនឹងបណ្តឹងទាមទារសំណង ។

### ៣.៣.៨. ដំណើរការនៃការសងសំណង

ការសងសំណង គឺជាការសងទៅលើគ្រោះថ្នាក់ឬហានិភ័យផ្សេងៗ ដែលបានកើតឡើងដែលស្ថិតក្រោមការធានាដែលបានចែងនៅក្នុងបណ្ណ័កិច្ចសន្យា។ ការសងនិងអាចប្រព្រឹត្តិទៅតាមគោលការមួយចំនួនមានដូចជា៖

- លក្ខខណ្ឌពេលចុះកិច្ចសន្យានៅពេលដែលទិញធានារ៉ាប់រង
- ការធ្វើសំណង ជូនទៅតាមកម្រិតនៃការខូចខាតដោយមិនលើសពីតំលៃដែលបានដាក់ព្រមទាំងធ្វើការសងដោយកាត់ជាមួយនិងកម្រិតមិនធ្វើសំណង
- អ្នកដែលត្រូវបានធានាត្រូវគោរពទៅតាមកិច្ចសន្យាដោយមិនល្មើសពីកិច្ចសន្យា
- កម្រិតនៃទំហំការពាររបស់អតិថិជន

រាល់ការធ្វើសំណងដែលក្រុមហ៊ុនបានផ្តល់អោយទៅអតិថិជនគឺ ក្រុមហ៊ុនតម្រូវអោយអតិថិជនមានការទទួលខុសត្រូវចំពោះកម្រិតមិនធ្វើសំណង (Deductible ) ។

1. រូបមន្តនៃការគណនាសំណង( ករណី **Full value Of Property** )

ករណី **Full value Of Property = Sum insured (based on marketvalue) – Deductible**

ជាឧទាហរណ៍ ( ករណី Full value Of Property) ៖ បើអគារ A មួយត្រូវបានខូចខាតដោយ ដែលស្ថិតក្រោមការធានារបស់ក្រុមហ៊ុនដែលអគារឬទ្រព្យនោះត្រូវបានរងការខូចខាតចំនួន ៣,០០០.០០ ដុល្លារ ហើយកម្រិតមិនធ្វើសំណងឬភាពទទួលខុសត្រូវរបស់អតិថិជន ( Deductible ) ចំនួន ៥០០.០០ ដុល្លារ ហើយតម្លៃទីផ្សារនៅពេលនោះមានចំនួន ៣,០០០.០០ ដុល្លារនោះខាងក្រុមហ៊ុននឹងផ្តល់សំណងទៅកាន់អតិថិជនចំនួន ២,៥០០.០០ ដុល្លារដែលការខូចខាតនេះអតិថិជនអាចទទួលបានជាសាច់ប្រាក់ឬក៏ក្រុមហ៊ុនធ្វើការជួសជុលជូនអាស្រ័យទៅលើការសម្រេចចិត្តរបស់អតិថិជនជាក់ស្តែង។

2. រូបមន្តនៃការគណនាសំណង ( ករណីការធានា **Underinsurance** )

ជាឧទាហរណ៍ (ករណីUnder insurance ) បើអគារ B ត្រូវបានរងការខូចខាតអស់ចំនួន USD 500,000.00 ហើយនៅតម្លៃនៃទ្រព្យសរុបនៅពេលដែលខូចខាត មានចំនួន USD10,000,000.00 លើសពីនេះតម្លៃទ្រព្យដែលដាក់ធានាមានចំនួន USD 8,000,000.00។ ដូចនេះយើងអាចគណនាសំណងដូចខាងក្រោម៖

**Claim Amount Payable** = (Sum Insured x loss amount) / Total Suminsured At The Time Of Loss

**Claim Amount Payable** =(USD 8,000,000.00 x USD 500,000.00) / USD10,000,000.00 = USD 400,000.00

**Minus** : Deductible USD 2,500.00 each and every claim

**Net amount payable** : USD 400,000.00 – USD 2,500.00 = USD 397,500.00

### ៣.៣.៩. អត្ថប្រយោជន៍នៃធានារ៉ាប់រងលើអគ្គីភ័យនៅក្នុងក្រុមហ៊ុនហ្វតតេ

- នៅក្រុមហ៊ុនធានារ៉ាប់រង ហ្វតតេ មានក្រុមភ្នាក់ងារជំនាញមានបទពិសោធន៍យូរឆ្នាំ និងមានសមត្ថភាពក្នុងដំណើរការទូទាត់សំណងគ្រប់ប្រភេទ ធានាផ្តល់ជូនអ្នកនូវសំណងបានយ៉ាងឆាប់រហ័ស រួសរាយរាក់ទាក់ មានគុណភាពខ្ពស់ដោយយើងមានសេវាកម្មបម្រើពេញ២៤ម៉ោងក្នុងមួយថ្ងៃ ៧ថ្ងៃក្នុងមួយសប្តាហ៍ ។

- ក្នុងករណីមានការទាមទារសំណងលើហានិភ័យអគ្គីភ័យ ឬការសាងសង់ ក្រុមហ៊ុន ហ្វតតេ នឹងទាក់ទងទៅអ្នកជំនាញវិជ្ជាជីវៈលំដាប់អន្តរជាតិ ( Independent International Loss Adjusters) និងមានបទពិសោធន៍ដើម្បីត្រួតពិនិត្យការបាត់បង់ ខូចខាត ព្រមទាំងណែនាំជូនលោកអ្នកនូវវិធានទាមទាសំណងដើម្បីធានាចំពោះការផ្តល់សំណងបានឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាព។

- ក្រុមហ៊ុនធានារ៉ាប់រងហ្វតតេផ្តោតសំខាន់ទៅលើការទាមទារសំណងរបស់អតិថិជនត្រូវបាន គ្រប់គ្រងក្នុងលក្ខណៈត្រឹមត្រូវ អាចបត់បែនបាន និងយុត្តិធម៌ ក្នុងការប្រើប្រាស់នូវប្រតិបត្តិការទាមទារសំណងដែលត្រូវបានរៀបចំឡើងដើម្បីតម្រូវតាមគោលការណ៍សាជីវកម្ម។

## ៣.៤. ការវិភាគ Swot ចំពោះដំណើរការសេវាកម្ម

### ៣.៤.១. ភាពខ្លាំងរបស់ផលិតផលធានារ៉ាប់រងលើអគ្គីភ័យ

ក្រោយពីបានសិក្សាអំពីទ្រឹស្តីធានារ៉ាប់រងនិងបានចុះទៅសិក្សាស្វែងយល់ពី សេវាកម្មធានារ៉ាប់រងនៅក្នុងក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ ជាពិសេសគឺសេវាកម្មធានារ៉ាប់រងទៅលើអគ្គីភ័យតាមរយៈការសាកសួរផ្ទាល់មាត់ និងការណែនាំក៏ដូចជាពន្យល់ពី សំណាក់បុគ្គលិក នៅក្នុងក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ បានដំណើរការយ៉ាងល្អប្រសើរ ព្រមទាំងទទួលបាននូវការគាំទ្រពីសំណាក់ប្រជាពលរដ្ឋជាច្រើន។ ទន្ទឹមជាមួយគ្នានេះដែរផលិតផលធានារ៉ាប់រងលើអគ្គីភ័យមានចំណុចខ្លាំងដូចជា៖

– តម្លៃបុព្វលាភ ក្នុងការទិញធានារ៉ាប់រងលើអគ្គីភ័យមានភាពសមរម្យនិងសមស្របទៅតាមតារាងតម្លៃនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ (យោងតាមឯកសារជំពូកទី៣ ទំព័រទី៥៣)

– ផលិតផលធានារ៉ាប់រងលើអគ្គីភ័យមានកម្រិតនៃការធានាទូលំទូលាយ និង មានជំរើសជាច្រើនសមស្របជាមួយតម្រូវការរបស់អតិថិជន ក្រៅពីការធានា ទៅលើ អគ្គីភ័យ រន្ទះ ការផ្ទុះ អតិថិជនអាចបន្ថែមការធានាទៅលើហានិភ័យបន្ថែមគឺ ១៣ ករណីផ្សេងទៀត លើទ្រព្យសម្បត្តិរបស់ខ្លួនក្នុងករណីចាំបាច់។ (យោងតាមឯកសារជំពូកទី៣ ទំព័រទី៥២)

– នៅពេលដែលអតិថិជន ជ្រើសរើសផលិតផលធានារ៉ាប់រងលើអគ្គីភ័យក្នុងការធានាលើទ្រព្យសម្បត្តិរបស់ខ្លួន អតិថិជននិងទទួលបាននៅការពន្យល់អំពី កម្រិតការធានា សារៈប្រយោជន៍ផ្សេងៗ កម្រិតការមិន

ធានាពីសំណាក់បុគ្គលិកនិងអង្គភាពពាក់ពន្ធ័ដែលមានវិជ្ជាជីវៈនិង មានការបណ្ដុះបណ្ដាលច្បាស់លាស់ដើម្បីឲ្យអតិថិជនមានអារម្មណ៍កក់ក្ដៅទៅលើសេវាកម្មមួយនេះនៅពេលដែលមានហានិភ័យកើតឡើងអតិថិជននិងទទួលបានក្រុមជំនាញ (Independent International Loss Adjusters) ឬក៏បុគ្គលិកដែលមានជំនាញវិជ្ជាជីវៈច្បាស់លាស់ក្នុងការសិក្សាស្រាវជ្រាវពីហេតុការណ៍ និងធ្វើការវាស់វែងដើម្បីដឹងពីប្រភពបញ្ហា និង ធ្វើការវាយតម្លៃដើម្បីផ្ដល់ជាសំណងទៅកាន់អតិថិជន ។ ក្នុងការដោះស្រាយបញ្ហា និង សំណងទៅកាន់អតិថិជនមានភាពយុត្តិធម៌ដោយផ្អែកលើលក្ខខណ្ឌពេលចុះកិច្ចសន្យាទិញធានារ៉ាប់រងនិងទំហំការខូចខាតជាក់ស្ដែង។ ( យោងតាម Claim In Company Profile ក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ)

– ធ្វើអោយអតិថិជនមានសុវត្ថិភាពលើទ្រព្យសម្បត្តិរបស់ពួកគេដោយចំណាយទៅលើបុព្វលាភបន្តិចបន្តួច (យោងតាមតាមរយៈការចុះសម្ភាសផ្ទាល់)

### ៣.៤.២. ភាពខ្សោយរបស់ផលិតផលធានារ៉ាប់រងលើអគ្គីភ័យ

យោងតាមរយៈការចុះសម្ភាសដោយផ្ទាល់ ជាមួយផ្នែកធានារ៉ាបរងទូទៅលើផលិតផលធានារ៉ាប់រងលើអគ្គីភ័យយើងសង្កេតឃើញមាន ចំណុចខ្សោយមួយចំនួនមានដូចជា ៖

– បើទោះបីជាផលិតផលធានារ៉ាប់រងលើអគ្គីភ័យមានការធានាជាមូលដ្ឋានចំនួន ៣ ធំៗក៏ដោយបើសិនជាមានហានិភ័យណាមួយដែលកើតឡើងដោយហានិភ័យបន្ថែម ហើយអតិថិជនពុំបានទិញទៅលើហានិភ័យនោះទេនិងពុំមានការទទួលខុសត្រូវចំពោះហានិភ័យនោះទេ។ ហើយលើសពីនេះទៅទៀតរាល់ការទិញហានិភ័យបន្ថែមត្រូវចំណាយបុព្វលាភបន្ថែម ជាហេតុធ្វើអោយក្រុមអតិថិជនមានការស្ទាក់ស្ទើរក្នុងការជ្រើសយកហានិភ័យបន្ថែមជាជាងហានិភ័យមូលដ្ឋាន។

– កត្តាបញ្ចុះតម្លៃបុព្វលាភរបស់សេវាកម្មធានារ៉ាប់រងលើអគ្គីភ័យនៅមានកម្រិត។

### ៣.៤.៣. ឱកាសរបស់ក្រុមហ៊ុន

– ដោយសារតែ ប្រទេសកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍន៍ ដូច្នេះហើយមាន សំណង់អាគារ រោងចក្រ សហគ្រាស លំនៅដ្ឋានជាច្រើនបានសាងសង់ឡើងដែលជាឱកាសសំរាប់ក្រុមហ៊ុនក្នុងការផ្ដល់សេវាកម្មរបស់ខ្លួនឲ្យបានកាន់តែច្រើន។

– បច្ចុប្បន្នប្រជាជនកម្ពុជាមានការយល់ដឹងពីរសេវាកម្មធានារ៉ាប់រង និង អត្ថប្រយោជន៍របស់ធានារ៉ាប់រងច្រើនដែលជំរុញឲ្យមានភាពងាយស្រួលដល់ក្រុមហ៊ុនក្នុងការផ្ដល់សេវាកម្មរបស់ខ្លួន។

– មានការបង្កើតអជីវកម្មថ្មីៗ ជាច្រើននាពេលបច្ចុប្បន្ន ដូច្នេះដើម្បីការពារអជីវកម្មនិងទ្រព្យរបស់ខ្លួនម្ចាស់អជីវកម្មចាំបាច់ត្រូវការធានារ៉ាប់រងដើម្បីកាត់បន្ថយហានិភ័យដោយសារឧបទ្ទវហេតុផ្សេងៗ។

– ដើម្បីបង្កើតអជីវកម្ម ឬ ពង្រីកអជីវកម្ម ម្ចាស់អជីវកម្មភាគច្រើនបានទៅខ្ចីទុនពីធនាគារ។ហើយដើម្បីធានាបានថាមិនមានភាពរអាក់រអួលចំពោះប្រាក់កម្ចីរបស់ខ្លួន ធនាគារតម្រូវឲ្យអតិថិជនរបស់ខ្លួនមួយចំនួនទិញធានារ៉ាប់រងសំរាប់ទ្រព្យសម្បត្តិដែលបានដាក់បញ្ចាំអស្រ័យទៅតាមតម្លៃនៃទ្រព្យនោះ។នេះជាឱកាសសំរាប់ក្រុមហ៊ុនក្នុងការ ផ្តល់សេវាកម្មរបស់ខ្លួនឲ្យបានកាន់តែច្រើន។

### ៣.៤.៤. ការគំរាមកំហែងរបស់ក្រុមហ៊ុន

ស្របពេលជាមួយគ្នានេះដែរក្រុមហ៊ុនក៏មានការជួបប្រទះនូវការគំរាមកំហែងផងដែរដោយសារតែះ

– នៅក្នុងប្រទេសកម្ពុជារយៈពេលចុងក្រោយនេះមានក្រុមហ៊ុនធានារ៉ាប់រង ជាច្រើនបានបង្កើតឡើងនិងចូលមកក្នុងទីផ្សារ ធ្វើអោយមានការប្រកួតប្រជែងគ្នាខ្លាំងផ្នែកទីផ្សារ។ កត្តានេះហើយដែលធ្វើឲ្យក្រុមហ៊ុនមានការបាត់បង់ចំណែកទីផ្សារមួយចំនួន។

# សេចក្តីសន្និដ្ឋាន

# និង

# អនុសាសន៍

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

តាមរយៈការសិក្សាបកស្រាយពាក់ព័ន្ធទៅនឹង ដំណើរការនៃការផ្តល់សេវាកម្មធានារ៉ាប់រងលើអគ្គីភ័យនៅក្នុងក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ គឺមានដំណើរការជាច្រើនដំណាក់កាលហើយដំណាក់កាលនីមួយៗសុទ្ធសឹងតែត្រូវបានសិក្សាយ៉ាងច្បាស់លាស់ពីសំណាក់ក្រុមការងារក្នុងក្រុមហ៊ុន។ មួយវិញទៀតយើងឃើញថានៅក្នុងផលិតផលអគ្គីភ័យនេះពិតជាមានអត្ថប្រយោជន៍ជាច្រើន ដែលសមស្របទៅតាមស្ថានភាពក្នុងប្រទេសកម្ពុជា។យ៉ាងណាមិញតាមរយៈការសិក្សាស្រាវជ្រាវមួយនេះបានធ្វើអោយយើងដឹងពីស្ថានភាពរបស់ក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ រួមទាំងវិស័យមួយនេះនៅក្នុងប្រទេសកម្ពុជាផងដែរ។

ជារួមមកដំណើរការនៃការផ្តល់សេវាកម្មធានារ៉ាប់រងលើអគ្គីភ័យរួមមាន៤ ដំណាក់កាល ដោយដំបូងអតិថិជនត្រូវធ្វើការស្នើរសុំទិញសេវាកម្មធានារ៉ាប់រងលើអគ្គីភ័យទៅកាន់ក្រុមហ៊ុន ដោយផ្តល់នូវព័ត៌មានដែលពាក់ព័ន្ធនឹងទ្រព្យសម្បត្តិដែលស្នើរសុំការធានា ដូចដែលបានរៀបរាប់នៅក្នុងចំនុច៣.៣.១ (ដំណាក់កាលទី១) ។ ដំណាក់កាលទី២ ក្រុមហ៊ុននឹងធ្វើការវាយតម្លៃទៅលើសំណង់អាគារ ស្ថានភាពជុំវិញ និងប្រព័ន្ធការពារសុវត្ថិភាពពីអគ្គីភ័យរបស់អាគារដើម្បីងាយស្រួលក្នុងការផ្តល់ការធានាទៅលើអាគារនោះ។បន្ទាប់មកទៀត នៅក្នុងដំណាក់កាលទី៣ ក្រុមហ៊ុន នឹងធ្វើការសម្រេចចិត្តថាតើគួរតែផ្តល់ការធានាអោយអតិថិជននោះឬធ្វើការបដិសេធន៍ក្នុងការធានា ។ និង ដំណាក់កាលចុងក្រោយ ប្រសិនបើក្រុមហ៊ុនទទួលព្រមផ្តល់ការធានា នោះក្រុមហ៊ុននឹងរៀបចំឯកសារ និងលក្ខខ័ណ្ឌផ្សេង ដូចដែលបានរៀបរាប់នៅក្នុងចំណុច ៣.៣.១ ( ដំណាក់កាលទី៤)។

ចំពោះដំណើរការនៃការទាមទារសំណងវិញ ដំបូងនៅពេលមានករណីអគ្គីភ័យកើតឡើងអ្នកត្រូវបានធានាត្រូវទាក់ទងទៅកាន់ក្រុមពន្លត់អគ្គីភ័យ និងប៉ូលីសដើម្បីធ្វើការពន្លត់អគ្គីភ័យតាមដែលអាចធ្វើទៅបាន។ បន្ទាប់មកអតិថិជនត្រូវធ្វើការផ្តល់ពត៌មានមកក្រុមហ៊ុនធានារ៉ាប់រងភ្លាមៗ ដើម្បីឲ្យក្រុមហ៊ុនបញ្ជូនក្រុមជំនាញទៅសិក្សាស្រាវជ្រាវនិង វាស់វែងដើម្បីដឹងពីប្រភពនៃបញ្ហា។ នៅពេលដែលមានការខូចខាត អតិថិជនត្រូវធ្វើការជូនដំណឹងជា លាយលក្ខណ៍អក្សរទៅកាន់ក្រុមហ៊ុន រួមទាំងឯកសាមួយចំនួនដូចដែលបានរៀបរាប់នៅចំនុច៣.៣.៧ ។ដំណើរការនៃការសងសំណង ក្រុមហ៊ុនធ្វើការសងទៅលើការខូចខាតផ្សេងៗស្របទៅតាមលក្ខខ័ណ្ឌនៅក្នុងប័ណ្ណសន្យារ៉ាប់រង។

ហើយលើសពីនេះទៅទៀត អត្ថប្រយោជន៍ដែលអតិថិជននឹងទទួលបានពីសេវាកម្មធានារ៉ាប់រងអគ្គីភ័យរបស់ក្រុមហ៊ុនហ្វតតេមានដូចជា ទទួលបាននូវសេវាកម្មដែលល្អផ្តាច់គេនៅក្រុមប្រទេស មានសេវាកម្មបម្រើពេញ២៤ម៉ោងក្នុង១ថ្ងៃ និង៧ថ្ងៃក្នុងមួយសប្តាហ៍ រួមទាំងក្រុមការងារដែលមានជំនាញនិងបទពិសោធន៍ជាច្រើនឆ្នាំក្នុងការបម្រើសេវាកម្មដល់អតិថិជន។ មិនតែប៉ុណ្ណោះក្រុមហ៊ុនហ្វតតេមានក្រុមដែលមានជំនាញវិជ្ជាជីវៈលំដាប់អន្តរជាតិនិងមានបទពិសោធន៍ ដើម្បីត្រួតពិនិត្យនិងវាយតម្លៃចំពោះការខូចខាតផ្សេងៗនៅពេលមានហានិភ័យកើតឡើង ដើម្បីធ្វើយ៉ាងណាឲ្យការផ្តល់សំណងធ្វើទៅបានឆាប់បំផុតនិងមានប្រសិទ្ធភាព មួយវិញទៀតចំពោះការទាមទារសំណងរបស់អតិថិជនត្រូវបានគ្រប់គ្រងក្នុងលក្ខណៈត្រឹមត្រូវ អាចបត់បែនបាន និងយុត្តិធម៌។

ក្រុមហ៊ុនមានការសហការណ៍ពីភាគីដែលពាក់ព័ន្ធ មានដូចជាអ្នកវិភាគហានិភ័យ ផ្នែកវាយតំលៃ ផ្នែកគណនេយ្យ ផ្នែកគ្រប់គ្រង ព្រមទាំងការផ្តល់សេវាកម្មប្រកបដោយក្រមសីលធម៌ ចំណេះដឹង ជំនាញ បទពិសោធន៍របស់បុគ្គលិកនៅក្នុងស្ថាប័នទាំងមូល។គ្រប់ផ្នែកទាំងអស់នេះហើយដែលធ្វើឲ្យក្រុមហ៊ុនធានារ៉ាប់រងហ្វតតេទទួលបានភាពជោគជ័យមកដល់បច្ចុប្បន្ន។ ព្រមទាំងជួយក្រុមហ៊ុនឲ្យមានការរីកចម្រើនថែមបន្តទៀតទៅថ្ងៃអនាគត ហើយជួយលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាជននិងជួយផ្ទេរហានិភ័យហិរញ្ញវត្ថុនិងជួយឲ្យសេដ្ឋកិច្ចរីកចម្រើន។

## ២. អនុសាសន៍

ដោយយោងទៅតាមការសិក្សាស្រាវជ្រាវដោយផ្ទាល់នៅក្នុងក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ បានបង្ហាញអោយឃើញនូវចំនុចខ្លាំង និង ចំនុចខ្សោយមួយចំនួនរបស់សេវាកម្មធានារ៉ាប់រងលើអគ្គីភ័យ។ សេវាកម្មធានារ៉ាប់រងលើអគ្គីភ័យមានចំណុចខ្លាំងនិងសក្តានុពលជាច្រើនក្នុងការបំពេញតម្រូវការអតិថិជន ។ តែទោះជាយ៉ាងណាក៏សេវាកម្មធានារ៉ាប់រងលើអគ្គីភ័យមួយនេះនៅតែមានចំណុចគួរកែសម្រួល និង ត្រួតពិនិត្យដើម្បីបំពេញតម្រូវការរបស់អតិថិជនក្នុងពេលបច្ចុប្បន្ន។ ហេតុដូចនេះហើយដើម្បីជាមតិយោបល់ដល់ការអភិវឌ្ឍន៍សេវាកម្មនេះអោយកាន់តែមានភាពប្រសើរឡើង ដើម្បីត្រៀមខ្លួនក្នុងការប្រកួតប្រជែងនៅក្នុងទីផ្សារធានារ៉ាប់រងទូទៅនាពេលបច្ចុប្បន្ន និងនាពេលអនាគតដូច្នេះហើយ ក្រុមហ៊ុនគួរតែអនុវត្តនូវគោលការណ៍មួយចំនួនបន្ថែមទៀតដូចចំណុចខាងក្រោមៈ

– បើទោះបីជាផលិតផលធានារ៉ាប់រងលើអគ្គីភ័យមានការធានាជាមូលដ្ឋានចំនួន ៣ ធំៗក៏ដោយបើសិនជាមានហានិភ័យណាមួយដែលកើតឡើងដោយហានិភ័យបន្ថែមហើយអតិថិជនពុំបានទិញទៅលើ ហានិភ័យ

នោះទេនិងពុំមានការទទួលខុសត្រូវចំពោះហានិភ័យនោះទេ។ ដូច្នេះហើយក្រុមហ៊ុននឹងអង្គភាពពាក់ព័ន្ធគួរតែពិចារណាឡើងវិញចំពោះហានិភ័យបន្ថែមនេះ ដោយដាក់បញ្ចូលជាមួយនឹងហានិភ័យមូលដ្ឋាន ដោយ ហានិភ័យបន្ថែមត្រូវតែសមស្របជាមួយនឹងស្ថានភាពក្នុងស្រុក និងមានការកែសម្រួលតម្លៃបុព្វលាភ។

– ក្រុមហ៊ុនធានារ៉ាប់រងហ្វតេ គួរតែបង្កើនគោលការណ៍ឬវិធីសាសន៍ផ្សេងៗទៀតដែលមានលក្ខណៈពិសេសផ្សេងទៀតទៅលើផលិតផលធានារ៉ាប់រងលើអគ្គីភ័យ ដើម្បីទទួលបានអតិថិជនថ្មីបន្ថែមនិងការទុកចិត្តពីអតិថិជនចាស់ផងដែរ។

# ឯកសារយោង


[1] សមាគមធានារ៉ាប់រងកម្ពុជា, Market Statistic Of General Insurance , ត្រូវបានយកមកប្រើប្រាស់នៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០២០ ,http://www.iac.org.kh/images/Media%20Release/Statistics/General/2019/Market%20Statistic%20for%20General-Insurance-2019.pdf

[2] កាសែតVOAដែលចុះផ្សាយនៅថ្ងៃទី២១ខែកុម្ភៈ២០១៩, ត្រូវបានយកមកប្រើប្រាស់នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២០ https://khmer.voanews.com/a/firefighter-official-call-on-people-to-be-more-cautious-of-fire/4798113.html

[3] Difference Between Primary and Secondary data , https://keydifferences.com/difference-between-primary-and-secondary-data.htmlត្រូវបានយកមកប្រើប្រាស់នៅថ្ងៃទី១០ខែមេសា ឆ្នាំ២០២០

[4] What's the Difference between qualitative and quantitative research, ត្រូវបានយកមកប្រើប្រាស់នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០ , https://www.snapsurveys.com/blog/qualitative-vs-quantitative-research/

[5] History Of Insurance , https://en.wikipedia.org/wiki/History_of_insurance , ដែលបានយកមកប្រើប្រាស់នៅក្នុងថ្ងៃទី ០១ ខែមីនា ឆ្នាំ២០២០

[6] History Of Insurance Industry in Cambodia , https://angkornation.com/history-insurance-industry-cambodia/ ដែលបានយកមកប្រើប្រាស់នៅថ្ងៃទី០៣ ខែមីនា ២០២០

[7] សមាគមន៍ធានារ៉ាប់រងកម្ពុជា,របាយការណ៍ស្ថិតិធានារ៉ាប់រងទូទៅ , យកមកប្រើប្រាស់នៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២០ http://www.iac.org.kh/images/Media%20Release/Statistics/General/2020/1Q/Market%20Statistic%20Report%20for%20General%20Insurance%201Q20.pdf

[8] សមាគមធានារ៉ាប់រងកម្ពុជា,ក្រុមហ៊ុនធានារ៉ាប់រងនៅក្នុងប្រទេសកម្ពុជា ,យកមកប្រើប្រាស់នៅថ្ងៃទី ១០ ខែមីនា ឆ្នាំ២០២០http://www.iac.org.kh/

[9] American International Group INC Website ,About us, https://www.aig.com/about-us យកមកប្រើប្រាស់នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០

[10] "AVIVA Plc" ,https://en.wikipedia.org/wiki/Aviva ,យកមកប្រើប្រាស់នៅថ្ងៃទី១០ ខែមេសាឆ្នាំ២០២០

[11] "AXA" , https://en.wikipedia.org/wiki/Axa , យកមកប្រើប្រាស់នៅថ្ងៃ ទី១០ខែមេសា ឆ្នាំ២០២០

[12] “ Baoviet Tokio Marine Company History” , https://www.baoviettokiomarine.com/site/index/pages/name/history/lid/english , យកមកប្រើប្រាស់នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០

[13] “China Taiping Insurance Holdings”https://en.wikipedia.org/wiki/China_Taiping_Insurance_Holdings, យកមកប្រើប្រាស់នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០

[14] “QBE Insurance” https://en.wikipedia.org/wiki/QBE_Insurance , យកមកប្រើប្រាស់នៅថ្ងៃទី១០ ខែ មេសា ឆ្នាំ២០២០

[15] “RSA Insurance Group”, https://en.wikipedia.org/wiki/RSA_Insurance_Group ,យកមកប្រើប្រាស់នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០

[16] “Swiss Re”, https://en.wikipedia.org/wiki/Swiss_Re , យកមកប្រើប្រាស់នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០

[17]“Zurich Insurance Group” , htts://en.wikipedia.org/wiki/Zurich_Insurance_Group ,យកមកប្រើប្រាស់នៅថ្ងៃទី១០ខែមេសាឆ្នាំ២០២០

[18] “About MSH China” https://www.mshasia.com/AboutUs.aspx?key=10002&keyParent=L01 ,យកមកប្រើប្រាស់នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០

[19] “Ping An Insurance” https://en.wikipedia.org/wiki/Ping_An_Insurance , យកមកប្រើប្រាស់នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០

[20] យោងតាម Forte Insurance Corporate Profile ឆ្នាំ២០១៩

គេហទំព័រក្រុមហ៊ុនហ្វតតេ,ផលិតផលធានារ៉ាប់រងសម្រាប់បុគ្គល https://www.forteinsurance.com/km/personal-insurance ,យកមកប្រើប្រាស់នៅថ្ងៃ២០ ខែមេសា ២០២០

គេហទំព័រក្រុមហ៊ុនហ្វតតេ,ផលិតផលធានារ៉ាប់រងសម្រាប់អាជីវកម្ម https://www.forteinsurance.com/km/corporate-insurance/,យកមកប្រើប្រាស់នៅថ្ងៃ២០ខែមេសា ២០២០

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

## កម្រងសំណួរ

1. ចូររៀបរាប់អំពីប្រវត្តិសង្ខេបរបស់ក្រុមហ៊ុន?
2. តើស្លាកសញ្ញាក្រុមហ៊ុនមានលក្ខណៈដូចម្តេច?
3. តើក្រុមហ៊ុនមានមានសាខាចំនួនប៉ុន្មាន? នៅទីណាខ្លះ?
4. តើក្រុមហ៊ុនមានបេសកកម្មនិងចក្ខុវិស័យដូចម្តេច?
5. តើក្រុមហ៊ុនមានរចនាសម្ព័ន្ធដូចម្តេច?
6. តើក្រុមហ៊ុនមានដៃគូរពាណិជ្ជកម្មជាមួយក្រុមហ៊ុនណាខ្លះ?
7. តើក្រុមហ៊ុនបានធ្វើអ្វីខ្លះចំពោះទំនួលខុសត្រូវសង្គម?
8. តើក្រុមហ៊ុនមានការផ្តត់ផ្គង់សេវាកម្មធានារ៉ាប់រងអ្វីខ្លះ?
9. តើគោលបំណងនៃការផ្តល់សេវាកម្មនៃធានារ៉ាប់រងលើអគ្គីភ័យមានអ្វីខ្លះ?
10. តើធានារ៉ាប់រងលើអគ្គីភ័យត្រូវបានបែងចែកជាប៉ុន្មានប្រភេទ?អ្វីខ្លះ?
11. តើនីតិវិធីនៃការនៃការផ្តល់សេវាកម្មធានារ៉ាប់រងលើអគ្គីភ័យមាននដំណាក់កាលដូចម្តេចខ្លះ?
12. តើព័ត៌មានអ្វីខ្លះដែលអតិថិជនត្រូវផ្តល់ជូនក្រុមហ៊ុនដើម្បីទិញធានារ៉ាប់រងលើអគ្គីភ័យ?
13. តើបែបបទដែលក្រុមហ៊ុនផ្តល់ជូនចំពោះអតិថិជនមានទម្រង់និងលក្ខណៈដូចម្តេច?
14. តើហានិភ័យជាមូលដ្ឋានមានអ្វីខ្លះនៅពេលមានបញ្ហាកើតឡើងក្រុមហ៊ុននឹងធ្វើការទទួលខុសត្រូវ?
15. តើផលិតផលធានារ៉ាប់រងលើអគ្គីភ័យក្រៅពីការធានាលើអគារអាចធានាលើអ្វីខ្លះ?
16. បើសិនជាអតិថិជនចង់ធានាក្រៅពីការធានារ៉ាប់រងជាមូលដ្ឋានតើផលិតផលធានារ៉ាប់រងលើអគ្គីភ័យអាចមានការធានាបន្ថែមក្រៅពីនេះដែរឬទេ?
17. បើសិនជាអតិថិជនមានសម្ភារៈពន្លត់អគ្គីភ័យតើពួកគេនិងទទួលបានការបញ្ចុះតម្លៃដែរឬទេ?ហើយសម្ភារៈទាំងនោះមានអ្វីខ្លះ?
18. តើតម្លៃបុលាព្វដែលបានយកពីអតិថិជនក្រុមហ៊ុនមានការគណនាដូចម្តេចខ្លះឬក៏ចេញដោយក្រសួងណាមួយ?
19. ចូររៀបពីការធានាចំពោះផលិតផលធានារ៉ាប់រងលើអគ្គីភ័យ?
20. តើផលិតផលធានារ៉ាប់រងលើអគ្គីភ័យ មានកម្រិនៃការមិនធ្វើសំណងដែរឬទេ?
21. តើដំណើរការនៃទាមទារសំណងមានអ្វីខ្លះនៅពេលដែលមានហានិភ័យកើតឡើង?

22. តើការផ្តល់សំណងចំពោះអតិថិជនមានលក្ខណៈដូចម្តេច?ចូររៀបរាប់?
23. តើអត្ថប្រយោជន៍នៃសេវាកម្មធានារ៉ាប់រងលើអគ្គីភ័យនៅក្នុងក្រុមហ៊ុនធានារ៉ាប់រងហ្វតេមានអ្វីខ្លះ
24. តើក្រុមហ៊ុនធានារ៉ាប់រងហ្វតេទទួលបានចំណែកទីផ្សារប៉ុន្មានភាគរយបើធៀបនិងក្រុមហ៊ុនធានារ៉ាប់ផ្សេងៗ?
25. ចូររៀបរ៉ាប់ពីបុព្វលាភអំពី Gross premium និង Net premium ដែលក្រុមហ៊ុនទទួបាននៅក្នុងឆ្នាំ ២០០៩ ដល់ ២០១៨?
26. តើភាពខ្លាំងរបស់ផលិតផលអគ្គីភ័យមានអ្វីខ្លះ?
27. តើភាពខ្សោយរបស់ផលិតផលអគ្គីភ័យមានអ្វីខ្លះ?
28. តើឱកាសរបស់ក្រុមហ៊ុនក្នុងទីផ្សារព្រះរាជាណាចក្រកម្ពុជាមានអ្វីខ្លះ?
29. តើក្រុមហ៊ុនមានភាពគំរាមកំហែងកំហែងអ្វីខ្លះ?

# ឧបសម្ព័ន្ធទី២

FORTE INSURANCE

# FIRE INSURANCE

Statement Pursuance to Article 20 of the Insurance Law of the Kingdom of Cambodia or any subsequent amendment thereof
YOU ARE TO DISCLOSE IN THIS PROPOSAL FORM, FULLY AND FAITHFULLY, ALL THE FACTS WHICH YOU KNOW OR OUGHT TO KNOW OTHERWISE, THE POLICY ISSUED HEREUNDER MAY BE VOID.

Proposer : ……………………………………………………………………………
អ្នកស្នើសុំ
Correspondence Address : ……………………………………………………………………………
អាសយដ្ឋាន
Occupation / Business Description : ……………………………………………………………………………
មុខរបរ/ពាណិជ្ជកម្ម
Bank Interest (if any) : ……………………………………………………………………………
**Beneficiary to** : ……………………………………………………………………………
ធនាគារអ្នកទទួលផលប្រយោជន៍

Period of Insurance : from……………………………………to……………………………………
រយៈពេលនៃការធានារ៉ាប់រង: ពី……………………………………ដល់……………………………………

Location of Property proposed for Insurance ……………………………………………………………………………
……………………………………………………………………………
ទីតាំងនៃទ្រព្យសម្បត្តិដែលចង់ធានា:……………………………………………………………………………

Purpose for which Building is used……………………………………………………………………………
អគារត្រូវបានប្រើប្រាស់ក្នុងគោលបំណងអ្វី:……………………………………………………………………………

| The property proposed for Insurance<br>ទ្រព្យសម្បត្តិដែលត្រូវបានស្នើសូមធានា | Sum proposed for Insurance<br>ចំនួនទឹកប្រាក់ដែលស្នើ សូមធានា |
|---|---|
| 1. ON BUILDING including Landlord's fixtures and fittings.<br>ទៅលើអគាររួមទាំងសំភារៈភ្ជាប់របស់ម្ចាស់ផ្ទះ | $ ____________ |
| 2. RENT (subject to Rent Clause) Number of months<br>ជួល (ដោយគោរពទៅតាម "ខ" នៃការជួល) ចំនួនខែនៃការជួល | $ ____________ |
| 3. CONTENTS<br>សំភារៈខាងក្នុងផ្ទះ | $ ____________ |
| 4. Other:……………………………………<br>ផ្សេងៗ …………………………………… | $ ____________ |
| Total for the Building and Overall<br>តម្លៃសរុប | $____________ |

Do you require any of the following Additional Perils? Please Tick "Yes" or "No"

1. Aircraft ☐ Yes ☐ No
   ការខូចខាតដោយយន្តហោះ
2. Earthquake and Volcanic Eruption ☐ Yes ☐ No
   ការខូចខាតដោយរញ្ជួយដីនិងការផ្ទុះភ្នំភ្លើង
3. Explosion ☐ Yes ☐ No
   ការខូចខាតដោយផ្ទុះ
4. Flood ☐ Yes ☐ No
   ការខូចខាតដោយទឹកជំនន់
5. Hail ☐ Yes ☐ No
   ការខូចខាតដោយការធ្លាក់ព្រិល
6. Hurricane, Cyclone, Typhoon, Windstorm ☐ Yes ☐ No
   ការខូចខាតដោយព្យុះ
7. Impact Damage ☐ Yes ☐ No
   ការខូចខាតដោយរងផលប៉ះពាល់
8. Riot and Strike ☐ Yes ☐ No
   ការខូចខាតដោយបាតុកម្មនិងកូដកម្ម
9. Smoke ☐ Yes ☐ No
   ការខូចខាតដោយផ្សែង
10. Spontaneous Combustion ☐ Yes ☐ No
    ការខូចខាតដោយការឆេះដោយឯកឯង
11. Subsidence and Landslip ☐ Yes ☐ No
    ការខូចខាតដោយការបាក់ស្រុតនិងបាក់ដី
12. Vandalism and Malicious Damage ☐ Yes ☐ No
    ការខូចខាតដោយអ្នកព្យាបាទនិងអ្នកបំផ្លាញ
13. Water Damage ☐ Yes ☐ No
    ការខូចខាតដោយទឹក

Unofficial Translation

Do you require additional copies of the Policy? show Names and Address
តើអ្នកត្រូវការច្បាប់ចម្លងបន្ថែមនៃប័ណ្ណសន្យាធានារ៉ាប់រងដែរឬទេ? សូមប្រាប់ឈ្មោះ និងអាសយដ្ឋាន
...................... | ...................... | ......................

| Please indicate the following details of the Building<br>សូមបញ្ជាក់នូវចំនុចលម្អិតនៃអគារដូចខាងក្រោម | External Walls<br>ជញ្ជាំងខាងក្រៅ | Internal Walls<br>ជញ្ជាំងខាងក្នុង | Construction<br>ការសាងសង់/សំណង់ | Roof<br>ដំបូល | Floor<br>ក្តារក្រាល/កម្រាល | No. of Storeys<br>ចំនួនជាន់ | Age of Building<br>អាយុនៃអគារ |
|---|---|---|---|---|---|---|---|
| | | | | | | | |

Protecting System:
ឧបករណ៍ពន្លត់អគ្គីភ័យ

Fire Extinguisher: ----------------------------Units    Type: --------------------------------------------------
បំពង់បាញ់ពន្លត់អគ្គីភ័យ..............គ្រឿង    ប្រភេទ.............................................

Hose reel: ----------------------------------------------------------------------------------------------------------------
ក្បាលម៉ាស៊ីនទឹកខាងក្នុងអគារ

Sprinkler: ----------------------------------------------------------------------------------------------------------------
ក្បាលម៉ាស៊ីនទឹកខាងក្នុងអគារដោយប្រើប្រភពទឹកដោយឡែក

Others: ----------------------------------------------------------------------------------------------------------------
ផ្សេងៗ ..........................................................................................

What other Insurances exist on the property now proposed? ...........................................................................
តើមានធានារ៉ាប់រងផ្សេងទៀតទៅលើអគារដែលស្នើសុំទិញធានារ៉ាប់រងដែរឬទេ?.............................................

Have you made any claim(s) or had any accident(s) for the past 3 years? ☐ Yes ☐ No
តើអ្នកធ្លាប់ធ្វើការទាមទារសំណងណាមួយ ឬ ធ្លាប់មានគ្រោះថ្នាក់ណាមួយក្នុងអំឡុងពេលបីឆ្នាំចុងក្រោយ ដែរឬទេ?
មាន ☐ មិនមាន ☐

If yes, please give the details:.......................................................................................................
.......................................................................................................................................
ប្រសិនបើមានសូមផ្តល់ព័ត៌មានលម្អិត........................................................................................

Has any proposal for Insurance of Property now proposed or any part thereof been made to any Office and not been completed by acceptance or has any Insurance been declined or cancelled? ☐ Yes ☐ No
តើអ្នកមានធ្វើការស្នើសុំទិញធានារ៉ាប់រងណាមួយទៅលើទ្រព្យសម្បត្តិដែលកំពុងធ្វើសំណើរនេះឬភាគណា មួយនៃទ្រព្យសម្បត្តិទៅកាន់ក្រុមហ៊ុនធានារ៉ាប់រងណាមួយ និងមិនទាន់ត្រូវបានចប់សព្វគ្រប់ដោយការទទួល យក ឬ ការធានារ៉ាប់រងត្រូវបានបដិសេធ ឬ លុបចោល?
មាន ☐ មិនមែន ☐

If yes, please give the details:.......................................................................................................
ប្រសិនជាមែនសូមផ្តល់ព័ត៌មានលម្អិត........................................................................................

Details of Adjoining Building:
ព័ត៌មានលម្អិតនៃអគារដែលនូវក្បែរ:

Is/ Are any of the neighboring building(s) attached to or detached from your building? ☐ Attached ☐ Detached
តើមានអគារក្បែរណាមួយនៅជាប់ ឬមិនជាប់ជាមួយអគាររបស់អ្នក? ☐ ជាប់ ☐ មិនជាប់

Others:
ផ្សេងៗ៖

Contact number of proposer :.......................................................................................................
លេខទូរស័ព្ទទំនាក់ទំនងរបស់អ្នកស្នើសុំ:..........................................................................................

Person in-charge and branch (banks only) : ..........................................................................................
អ្នកទទួលខុសត្រូវ និងសាខា (សំរាប់ធនាគារតែប៉ុណ្ណោះ)..........................................................................

I/WE DO HEREBY DECLARE AND WARRANT the answers given above in every respect are true and correct, and I/we have not withheld any information likely to affect acceptance of this Proposal, and I/we agree that this Proposal and Declaration shall be the basis of the Contract between the Company and myself/ourselves, and I/we further agree to accept the Company's Policy subject to the terms, exclusions and conditions to be expressed therein endorsed thereon or attached thereto.

I/We further agree that if this Proposal in any particular is filled in by any other person, such person shall be deemed to be my/our Agent(s) and not the Agent of the Company.

ខ្ញុំ/យើងសូមប្រកាសអះអាងនិងធានាថារាល់ចំលើយដែលបានផ្តល់អោយខាងលើគឺពិតនិងត្រឹមត្រូវហើយខ្ញុំ/យើងមិនបានលាក់បាំងនូវព័ត៌មានណាមួយដែលអាចប៉ះពាល់ដល់ការទទួលយកនៃពាក្យស្នើសុំទិញធានារ៉ាប់រងនេះទេហើយខ្ញុំ/យើងយល់ព្រមថាពាក្យស្នើសុំទិញធានារ៉ាប់រងនេះក៏ដូចជារាល់ការប្រកាសអះអាងទាំងអស់ក្នុងនេះនឹងបង្កើតបានជាមូលដ្ឋាននៃកិច្ចសន្យារវាងក្រុមហ៊ុននិងខ្លួនខ្ញុំ/ខ្លួនយើងហើយខ្ញុំ/យើងយល់ព្រមទទួលយកនូវប័ណ្ណសន្យាធានារ៉ាប់រងរបស់ក្រុមហ៊ុនដោយគោរពទៅតាមលក្ខខណ្ឌនិងអញ្ញត្រកម្មដែលមានចែង នូវក្នុងប័ណ្ណសន្យាធានារ៉ាប់រង ឬ លក្ខខណ្ឌបន្ថែមដែលត្រូវបានភ្ជាប់ជាមួយ។

ខ្ញុំ/យើងយល់ព្រមថាប្រសិនបើពាក្យស្នើសុំនេះត្រង់ចំនុចណាមួយត្រូវបានបំពេញដោយបុគ្គលណាមួយនោះបុគ្គលនោះនឹងចាត់ទុកជាភ្នាក់ងាររបស់ខ្ញុំ/យើង និង មិនមែនជាភ្នាក់ងាររបស់ក្រុមហ៊ុននោះទេ។

Signature of Proposer ..........................................................   Date..........................................................

Unofficial Translation

FORTE
INSURANCE
We build confidence

# FIRE INSURANCE

Statement Pursuance to Article 20 of the Insurance Law of the Kingdom of Cambodia or any subsequent amendment thereof
YOU ARE TO DISCLOSE IN THIS PROPOSAL FORM, FULLY AND FAITHFULLY, ALL THE FACTS WHICH YOU KNOW OR OUGHT TO KNOW OTHERWISE, THE POLICY ISSUED HEREUNDER MAY BE VOID.

Proposer : ................................................................................

Correspondence Address : ................................................................................

Occupation / Business Description : ................................................................................

Bank Interest (if any) : ................................................................................

**Beneficiary to** : ................................................................................

Period of Insurance : from................................................................to................................................................

Location of Property proposed for Insurance ................................................................................
................................................................................

Purpose for which Building is used................................................................................

| The property proposed for Insurance | Sum proposed for Insurance |
|---|---|
| 1. ON BUILDING including Landlord's fixtures and fittings. | $ ______________ |
| 2. RENT (subject to Rent Clause) | $ ______________ |
| Number of months | ______________ |
| 3. CONTENTS | $ ______________ |
| 4. Other:................................................................................ ................................................................................ | $ ______________ |
| Total for the Building and Overall | $ ______________ |

Do you require any of the following Additional Perils? Please Tick "Yes" or "No"

| | | | |
|---|---|---|---|
| 1. | Aircraft | ☐ Yes | ☐ No |
| 2. | Earthquake and Volcanic Eruption | ☐ Yes | ☐ No |
| 3. | Explosion | ☐ Yes | ☐ No |
| 4. | Flood | ☐ Yes | ☐ No |
| 5. | Hail | ☐ Yes | ☐ No |
| 6. | Hurricane, Cyclone, Typhoon, Windstorm | ☐ Yes | ☐ No |
| 7. | Impact Damage | ☐ Yes | ☐ No |
| 8. | Riot and Strike | ☐ Yes | ☐ No |
| 9. | Smoke | ☐ Yes | ☐ No |
| 10. | Spontaneous Combustion | ☐ Yes | ☐ No |
| 11. | Subsidence and Landslip | ☐ Yes | ☐ No |
| 12. | Vandalism and Malicious Damage | ☐ Yes | ☐ No |
| 13. | Water Damage | ☐ Yes | ☐ No |

Do you require additional copies of the Policy? show Names and Address

| | | |
|---|---|---|
| ........................................ | ........................................ | ........................................ |
| ........................................ | ........................................ | ........................................ |

| Please indicate the following details of the Building | External Walls | Internal Walls | Construction | Roof | Floor | No. of Storeys | Age of Building |
|---|---|---|---|---|---|---|---|
| | | | | | | | |

Protecting System: Fire Extinguisher: ----------------------------Units Type: --------------------------------------------------

Hose reel: ------------------------------------------------------------------------------------------------------------

Sprinkler: ------------------------------------------------------------------------------------------------------------

Others: --------------------------------------------------------------------------------------------------------------

What other Insurances exist on the property now proposed? ................................................................................

Have you made any claim(s) or had any accident(s) for the past 3 years? ☐ Yes ☐ No
If yes, please give the details:................................................................................
................................................................................

Has any proposal for Insurance of Property now proposed or any part thereof been made to any Office and not been completed by acceptance or has any Insurance been declined or cancelled? ☐ Yes ☐ No
If yes, please give the details:................................................................................
................................................................................

Details of Adjoining Building:

Is/ Are any of the neighboring building(s) attached to or detached from your building? ☐ Attached ☐ Detached

| |
|---|
| <u>Others:</u><br>Contact number of proposer :................................................................<br>Person in-charge and branch (banks only) : ................................................................ |

I/WE DO HEREBY DECLARE AND WARRANT the answers given above in every respect are true and correct, and I/we have not withheld any information likely to affect acceptance of this Proposal, and I/we agree that this Proposal and Declaration shall be the basis of the Contract between the Company and myself/ourselves, and I/we further agree to accept the Company's Policy subject to the terms, exclusions and conditions to be expressed therein endorsed thereon or attached thereto.
I/We further agree that if this Proposal in any particular is filled in by any other person, such person shall be deemed to be my/our Agent(s) and not the Agent of the Company.

Signature of Proposer ................................................................ Date................................................................

# ឧបសម្ព័ន្ធទី៣

**Forte Insurance (Cambodia) Plc.**
**Phnom Penh**
Vattanac Capital, Level 18, No. 66, Monivong blvd
• Phnom Penh • Cambodia
Tel: (855) 023 885 077/066 • Fax: (+855) 023 982 907
Email: info@forteinsurance.com

**Siem Reap**
572 Achar Svar • Krom 20 • Phum Wat Bo
Khum Salakamreuk • SIem Reap • Cambodia
Tel: (+855) 063 963 355 • Fax: (+855) 063 963 610
Email: srp@forteinsurance.com

**www.forteinsurance.com**

# OTHER CLASSES OF INSURANCE CLAIM PROCEDURES

## LOSS OR DAMAGE DUE TO FIRE

Basically the above loss or damage would involve the following Classes of Insurance.

1. All Risks
2. Money
3. Burglary
4. Consequential Loss
5. Contractor's All Risks
6. Erection All Risks
7. Machinery and Equipment
8. House owner's/Householder's

Immediately following such loss damage, you should:
1. Report to the Police Authorities
2. Notify **Forte Insurance (Cambodia) Plc.,** immediately through our 24 hr helplines **023 888 080** or telephone no. **(23) 366 683 / 885 066 / 885 077** by giving circumstances nature and extent of loss or damage.

Follow by the written notice by giving circumstances nature and extent of injury and to be submitted as soon as possible by fax no. **(023) 982 907** or e-mail: **claims@forteinsurance.com** or directly to

**"FORTE INSURANCE (CAMBODIA) PLC.**
**Vattanac Capital, Level 18, No. 66, Moninving Blvd,**
**Sangkat Wat Phnom, Khan Duan Penh, Phnom**
**Penh, Cambodia"**

We may adjust the claim by our Claim Personnel or assign a loss adjuster to investigate into the loss dependant on the circumstance of the claim.

However, if a loss adjuster is appointed we will notify you. In order to have an early settlement of the claim, you are advised to give our claim Personnel or the loss adjuster your full co-operation.

If our claim Personnel is doing the loss adjustment, you are required to supply us the following documents to support your claim.

1. Duly completed claim form (provided by Forte)
2. Police report
3. Estimate and/or receipt of repairs or replacement
4. Sales/purchase invoice
5. Stock records

You must preserve any evidence of loss or damage for investigation purposes.

## CONCLUSION

The foregoing are the basic requirement for you to adhere to in reporting losses with respect to the various Classes of Insurance indicated above. However, should you need further clarification, please feel free to contact us.

# ឧបសម្ព័ន្ធទី៤

# ច្បាប់
# ស្តីពី
# ការធានារ៉ាប់រង

ROYAUME DU CAMBODGE ★ LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងធានានូវ៖

-ការអភិវឌ្ឍប្រកបដោយចីរភាពនៃវិស័យធានារ៉ាប់រង

-ផលប្រយោជន៍សាធារណៈ និងទំនុកចិត្តដល់សេវាធានារ៉ាប់រង

-សង្គតិភាពជាមួយនឹងគោលការណ៍គ្រឹះធានារ៉ាប់រងអន្តរជាតិ

-ផលប្រយោជន៍របស់រូបវន្តបុគ្គល និងនីតិបុគ្គលដែលជាអ្នកត្រូវបានធានារ៉ាប់រង ។

**មាត្រា ២.-**

ច្បាប់នេះមានគោលដៅ៖

-ពង្រឹងការគ្រប់គ្រង និងការត្រួតពិនិត្យអាជីវកម្មធានារ៉ាប់រង

-កំណត់អំពីការគ្រប់គ្រងកិច្ចប្រតិបត្តិការ និងការធ្វើអាជីវកម្មធានារ៉ាប់រង

-ជំរុញការប្រកួតប្រជែង ភាពស្មោះត្រង់ និងតម្លាភាពក្នុងវិស័យធានារ៉ាប់រង ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះសកម្មភាពធានារ៉ាប់រងទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានបទប្បញ្ញត្តិដោយឡែកដូចមានចែងក្នុងជំពូកទី ១២ នៃច្បាប់នេះ ។

**មាត្រា ៤.-**

វាក្យសព្ទដែលប្រើនៅក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ៖

- **ការធានារ៉ាប់រង** សំដៅដល់ការធ្វើកិច្ចសន្យាធានារ៉ាប់រងដែលក្នុងនោះ អ្នកត្រូវបានធានារ៉ាប់រងត្រូវបង់បុព្វលាភធានារ៉ាប់រងទៅឲ្យក្រុមហ៊ុនធានារ៉ាប់រង ហើយក្រុមហ៊ុនធានារ៉ាប់រងត្រូវធ្វើសំណងដល់ការខូចខាត ឬការបាត់បង់ទ្រព្យសម្បត្តិដែលបង្កឡើងដោយហេតុការណ៍គ្រោះថ្នាក់ ឬក៏ធ្វើសំណងនៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងស្លាប់ របួស ពិការ មានជំងឺ ឬនៅពេលដែលបុគ្គលនោះ ឈានដល់កាលកំណត់ណាមួយដែលភាគីទាំងពីរបានព្រមព្រៀងគ្នា ដូចមានចែងក្នុងកិច្ចសន្យាធានារ៉ាប់រង ។

- **ការធានារ៉ាប់រងជាកាតព្វកិច្ច** សំដៅដល់ការធ្វើកិច្ចសន្យាធានារ៉ាប់រង ដែលអ្នកត្រូវបានធានារ៉ាប់រង ត្រូវបំពេញជាកាតព្វកិច្ចតាមការកំណត់នៃច្បាប់ និងបទប្បញ្ញត្តិស្តីពីការធានារ៉ាប់រងក្នុងកាលបំពេញបម្រើ និងការពារផលប្រយោជន៍សាធារណៈ ។

- **កិច្ចសន្យាធានារ៉ាប់រង** សំដៅដល់កិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ ដែលធ្វើឡើងដោយក្រុមហ៊ុនធានារ៉ាប់រង និងអ្នកត្រូវបានធានារ៉ាប់រង ដែលតាមរយៈនោះ ក្រុមហ៊ុនធានារ៉ាប់រងព្រម

ទទួលនូវហានិភ័យជាក់លាក់ណាមួយ ដោយទទួលមកវិញនូវការបង់បុព្វលាភធានារ៉ាប់រងពីអ្នកដែលត្រូវបានធានារ៉ាប់រង ។

- **កំណាត់សំអាង** សំដៅដល់ឯកសារបណ្ដោះអាសន្នដែលចេញដោយក្រុមហ៊ុនធានារ៉ាប់រង ឬភ្នាក់ងារធានារ៉ាប់រង ជំនួសបណ្ណសន្យារ៉ាប់រងស្ថាពរ ។

- **ក្រុមហ៊ុនធានារ៉ាប់រង** សំដៅដល់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច និងក្រុមហ៊ុនធានារ៉ាប់រងបន្ត ។

- **គ្រឹះស្ថានធានារ៉ាប់រង** សំដៅដល់ក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង ជើងសាធានារ៉ាប់រង និងក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង ។

- **បណ្ណសន្យារ៉ាប់រង** សំដៅដល់ឯកសារចងភ្ជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ ដែលចេញដោយក្រុមហ៊ុនធានារ៉ាប់រង ដោយមានកំណត់ពីខ្លឹមសារសំខាន់និងថែងពីលក្ខខណ្ឌលំអិតដែលបានព្រមព្រៀងរវាងក្រុមហ៊ុនធានារ៉ាប់រង និងអ្នកត្រូវបានធានារ៉ាប់រងនៅក្នុងកិច្ចសន្យាធានារ៉ាប់រង ។ បណ្ណសន្យារ៉ាប់រងត្រូវភ្ជាប់មកជាមួយនូវវិញ្ញាបនបត្រធានារ៉ាប់រង ឬឯកសារពាក់ព័ន្ធផ្សេងៗទៀត ។

- **បណ្ណសន្យារ៉ាប់រងគ្រោះថ្នាក់បុគ្គល** សំដៅដល់កិច្ចសន្យាធានារ៉ាប់រងដែលផលប្រយោជន៍របស់វាជាប្រាក់ ឬផលប្រយោជន៍សំណងជាវត្ថុ ឬផលប្រយោជន៍សំណងរួមមានជាប្រាក់និងជាវត្ថុទៅឲ្យអ្នកត្រូវបានធានារ៉ាប់រងនៅពេលមានហានិភ័យកើតឡើង ដើម្បីធានាលើគ្រោះថ្នាក់ទាំងឡាយ ។

- **បុព្វលាភធានារ៉ាប់រង** សំដៅដល់ចំនួនទឹកប្រាក់ដែលអ្នកត្រូវបានធានារ៉ាប់រងត្រូវបង់ទៅឲ្យក្រុមហ៊ុនធានារ៉ាប់រង តាមការកំណត់របស់ក្រុមហ៊ុនធានារ៉ាប់រងនៅក្នុងបណ្ណសន្យារ៉ាប់រង ។

- **ពិន័យអន្តរការណ៍** សំដៅដល់ការផាកពិន័យជាទឹកប្រាក់ចំពោះទង្វើរបស់ក្រុមហ៊ុនធានារ៉ាប់រងដែលអនុវត្តផ្ទុយពីការណែនាំរបស់បញ្ញត្តិករធានារ៉ាប់រង ។

- **ម្ចាស់បណ្ណសន្យារ៉ាប់រង** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសិទ្ធិស្របច្បាប់លើបណ្ណសន្យារ៉ាប់រង ។

- **វិញ្ញាបនបត្រធានារ៉ាប់រង** សំដៅដល់ឯកសារដែលចេញដោយក្រុមហ៊ុនធានារ៉ាប់រងដើម្បីបញ្ជាក់ថាអ្នកត្រូវបានធានារ៉ាប់រងបានទិញការធានារ៉ាប់រងពីក្រុមហ៊ុនធានារ៉ាប់រង ។

- **សំណងធានារ៉ាប់រង** សំដៅដល់សំណងជាប្រាក់ឬជាវត្ថុ ឬសំណងរួមជាប្រាក់និងជាវត្ថុដែលត្រូវសងដោយក្រុមហ៊ុនធានារ៉ាប់រង ។

- **អភិបាលបណ្ដោះអាសន្ន** សំដៅដល់អ្នកគ្រប់គ្រងបណ្ដោះអាសន្ន ដែលតែងតាំងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីបំពេញភារកិច្ចក្រុមហ៊ុនធានារ៉ាប់រងមុនពេលធ្វើការជម្រះបញ្ជីដើម្បីវាយតម្លៃលើស្ថានភាពសាធនភាពរបស់ក្រុមហ៊ុន ។

- **អ្នកដម្រះបញ្ហា** សំដៅដល់រូបវន្តបុគ្គលដែលត្រូវបានតែងតាំងដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬតុលាការ ដើម្បីធ្វើការដោះស្រាយទូទាត់បំណុលនៅពេលដែលក្រុមហ៊ុនធានារ៉ាប់រងត្រូវជម្រះបញ្ជី ។

- **អ្នកត្រូវបានធានារ៉ាប់រង** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលទិញបណ្ណសន្យារ៉ាប់រង ក្នុងករណីមួយចំនួនអាចជាម្ចាស់បណ្ណសន្យារ៉ាប់រងផង និងអាចជាអ្នកត្រូវបានធានារ៉ាប់រងផង ។

- **អ្នកទទួលផល** សំដៅដល់តតិយជននៃកិច្ចសន្យា ដែលត្រូវបានកំណត់ថាមានសិទ្ធិស្របច្បាប់ក្នុងការទទួលផលប្រយោជន៍ពីកិច្ចសន្យាទាំងឡាយណាដែលទាក់ទង នឹងការធានារ៉ាប់រងលើអាយុជីវិតតែប៉ុណ្ណោះ ។

- **អ្នកស្នើសុំធានារ៉ាប់រង** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលអាចនឹងក្លាយជាអ្នកត្រូវបានធានារ៉ាប់រងនាពេលអនាគត ដែលបំពេញនិងចុះហត្ថលេខាលើទម្រង់បែបបទជាលាយលក្ខណ៍អក្សររបស់ក្រុមហ៊ុនធានារ៉ាប់រងអំពីស្ថានភាពផ្ទាល់របស់បុគ្គលនោះ ។

- **យានយន្ត** សំដៅដល់យានដែលធ្វើចរាចរណ៍ដោយម៉ាស៊ីនលើផ្លូវគោក និងផ្លូវទឹក ។

## ជំពូកទី ២
## ស្ថាប័នមានសមត្ថកិច្ច

### មាត្រា ៥.-

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសមត្ថកិច្ចក្នុងការចេញបទប្បញ្ញត្តិ គ្រប់គ្រងនិងត្រួតពិនិត្យការធ្វើអាជីវកម្មធានារ៉ាប់រង ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

### មាត្រា ៦.-

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសមត្ថកិច្ចបង្កើតនិងគ្រប់គ្រងមូលនិធិអភិវឌ្ឍវិស័យធានារ៉ាប់រង ដើម្បីជំរុញការអភិវឌ្ឍ ការទ្រទ្រង់ និងការលើកកម្ពស់ការផ្សព្វផ្សាយអំពីសារប្រយោជន៍នៃការធានារ៉ាប់រងដល់សាធារណជន ។